# ការធ្វើជាឧបជ្ឈាយ៍

## មគ្គុទេសក៍សម្រាប់អ្នកសម្របសម្រួល

ស្វាគមន៍មកកាន់ការហ្វឹកហ្វឺនអំពីការធ្វើជាឧបជ្ឈាយ៍ ។ នៅក្នុងវគ្គសិក្សាដែលមានបួនម៉ោងនេះ លោកអ្នកនឹងរៀនអំពីមូលដ្ឋានគ្រឹះនៃអ្វីដែលជាកម្មវិធីហ្វឹកហ្វឺនជាឧបជ្ឈាយ៍មានលក្ខណៈបែបណា ។ ទោះបីជាអ្វីដែលបានបង្រៀននៅក្នុងម៉ោងទាំងបួននេះ អាចត្រូវបានអនុវត្តនៅក្នុងបរិបទផ្សេងៗ ក្នុងក្រុមជំនុំបានក៏ដោយ ការហ្វឹកហ្វឺនជាឧបជ្ឈាយ៍ដ៏ជាក់លាក់នេះ មានគោលបំណងសម្រាប់តែគ្រូគង្វាលរបស់ក្រុមជំនុំមេ ដែលនឹងណែនាំអ្នកដាំក្រុមជំនុំ ដែលកំពុងស្ថិតនៅក្នុងដំណើរការដាំក្រុមជំនុំរបស់ខ្លួនគេផ្ទាល់ ។ វគ្គសិក្សានេះក៏នឹងផ្តល់នូវឧបករណ៍ដ៏ចាំបាច់ ដើម្បីធានាបានថា ការវិនិយោគបុគ្គលិក ពេលវេលា និងធនធានទទួលបានជោគជ័យនៅក្នុងការដាំក្រុមជំនុំដែលថ្វាយសិរីល្អដល់ព្រះ ។ ការដាំក្រុមជំនុំដែលមានសុខភាពល្អប្រកបដោយជោគជ័យ តែងតែពង្រីកក្រុមជំនុំសម្រាប់ព្រះរាជ្យរបស់ព្រះ ។ តម្រានេះប្រមូលផ្តុំប្រធានបទនីមួយៗ និងបំពេញមុខងារជាមគ្គុទេសន៍មួយសម្រាប់គ្រូបង្ហាត់ ។ មានផ្នែកបន្ថែមមួយ ដែលដាក់បញ្ចូលកំណត់សម្គាល់មកពីអ្នកនិពន្ធផ្សេងៗ ដើម្បីជួយគ្រូបង្ហាត់ក្នុងការរៀបចំសម្រាប់ប្រធានបទនីមួយៗ ។

multiplication network

*more churches, stronger churches*

Received April 4, 2020

# មាតិកា

**ម៉ោងទី ១**
តើការធ្វើជាឧបជ្ឈាយ៍ ជាអ្វី? ............ ៤

**ម៉ោងទី ២**
ការធ្វើជាឧបជ្ឈាយ៍ដល់សិស្សពេញវ័យ ............ ១៣

**ម៉ោងទី ៣**
ទំនាក់ទំនងឧបជ្ឈាយ៍ ............ ២០

**ម៉ោងទី ៤**
ការបាប់ផ្ដើមទំនាក់ទំនងឧបជ្ឈាយ៍ ............ ២៦

ទិន្នានុប្បវត្តសម្រាប់ឧបជ្ឈាយ៍ ............ ៣៦

សេណារីយ៉ូសម្រាប់ពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ............ ៣៩

របាយការណ៍ដាំក្រុមជំនុំ កខគ ............ ៤១

កំណត់សម្គាល់មកពីពួកអ្នកនិពន្ធ ............ ៤២

**កំណាត់សម្គាល់:** គ្រប់មេរៀនទាំងអាចបង្រៀននៅក្នុងរយៈពេល ៦០ ទៅ ៩០ នាទីបាន ។ មេរៀននីមួយៗមិនគួរប្រើពេលលើសពី ១២០ នាទីទេ ។

**ព័ន្ធកិច្ចបណ្ដាញពហុគុណ | ២០១៤**
សំណៅចុងក្រោយ ៨/១៦/២០១៦

លើកលែងតែបានបញ្ជាក់ប្រាប់ បើមិនដូច្នោះទេ បទគម្ពីរទាំងអស់ដកស្រង់ចេញព្រះគម្ពីរបរិសុទ្ធកែសម្រួល ២០១៦ ។

វគ្គសិក្សានេះផ្អែកលើសៀវភៅ ***ភាពស្ទាត់ជំនាញក្នុងការធ្វើជាឧបជ្ឈាយ៍*** និង ***មូលហេតុដែលយើងត្រូវធ្វើជាឧបជ្ឈាយ៍ដល់អ្នកដាំក្រុមជំនុំ*** ។ សៀវភៅទីមួយ លោកអ្នកអាចទាញយកបានដោយឥតគិតថ្លៃនៅលើគេហទំព័ររបស់យើងដែលមានអាសយដ្ឋាន www.multiplicationnetwork.org ។

សៀវភៅនេះ ជាសំណៅកែសម្រួល និងសង្ខេបពីតម្រាដើមសម្រាប់គ្រូបង្ហាត់ ។ មានកំណត់សម្គាល់ពន្យល់បន្ថែមនៅក្នុងផ្នែកដែលមានចំណងជើងថា «កំណត់សម្គាល់មកពីពួកអ្នកនិពន្ធ» ដែលនៅប៉ុន្មានទំព័រចុងក្រោយ ។

# ម៉ោងទី ១
# តើការធ្វើជាឧបដ្ឋាយ៍ ជាអ្វី?

## កម្មវត្ថុៈ

- រកឃើញឧទាហរណ៍នៅក្នុងព្រះគម្ពីរអំពីការធ្វើជាឧបដ្ឋាយ៍
- ពណ៌នាអំពីពាក្យគន្លឹះពាក់ព័ន្ធនឹងការធ្វើជាឧបដ្ឋាយ៍

## គំរូនៅក្នុងព្រះគម្ពីរអំពីការធ្វើជាឧបដ្ឋាយ៍

រឿងជាច្រើននៅក្នុងបទគម្ពីរបង្ហាញប្រាប់ដំណើរការឧបដ្ឋាយ៍ជាផែនការរបស់ព្រះ ដែលត្រូវបានសម្រេចតាមរយៈមនុស្សដែលព្រះវិញ្ញាណបានដឹកនាំ និងបានប្រទានអំណាចឲ្យ ។ ជំនាន់មួយបម្រើជំនាន់មួយទៀត ។ ឪពុកម្ដាយបង្រៀនចំណេះដឹងរបស់ពួកគេអំពីព្រះដល់កូនរបស់ខ្លួន ដើម្បីបង្កើតមរតកដែលគោរពកោតខ្លាចព្រះ ។ អ្នកដឹកនាំណែនាំអ្នកស្នងវេនបន្តពីខ្លួនអំពីមាគ៌ារបស់ព្រះ និងភាពជាអ្នកដឹកនាំ ។ មានរឿងជាច្រើន ប៉ុន្តែយើងនឹងផ្ដោតលើទំនាក់ទំនងមួយចំនួនតូចរវាងឧបដ្ឋាយ៍ និងសទ្ធិវិហារិក ដែលពន្យល់ប្រាប់អំពីគ្រឹះនៅក្នុងព្រះគម្ពីរទាក់ទងនឹងការធ្វើជាឧបដ្ឋាយ៍ ។

## លោកម៉ូសេជាគ្រូឧបដ្ឋាយ៍

ជាលក្ខណៈរៀងៗខ្លួន ឬជាក្រុម ចូរអានខគម្ពីរទាំងនេះ ។ វាប្រហែលជាមានប្រយោជន៍ដោយចាត់តាំងឲ្យមានការអានតាមក្រុម និងចែកចាយចម្លើយនៅចុងបញ្ចប់ ។

និក្ខមនំ ១៧:៩-១៤, ២៤:១៣-១៨, ៣២:១៧-១៨, ៣៣:១១ ជនគណនា ១១:២៤-២៩, ១៤:៦-៩, ៣០, ៣៨, ២៧:១៨-២៣, ៣២:១២, ៣៤:១៧ ចោទិយកថា ១:៣៨, ៣:២១-២២, ២៨, ៣១:៣, ៧-៨, ១៤, ២៣, ៣២:៤៤-៤៦, ៣៤:៩, យ៉ូស្វេ ១:១-១៨, ២៤:៣១ ចៅហ្វាយ ២:៧-១១ ។

មានតួអង្គសំខាន់ៗជាច្រើននៅក្នុងប្រវត្តិអំពីការតាំងទីលំនៅក្នុងទឹកដីសន្យា ។

១. ចូរពណ៌នាអំពីរបៀបដែលទំនាក់ទំនងរវាងលោកម៉ូសេ និងលោកយ៉ូស្វេបានកើតឡើង ។

___________________________________________________________________________

___________________________________________________________________________

២. តើលោកម៉ូសេមានចំណេះដឹង ឬបទពិសោធន៍អ្វីដែលលោកយ៉ូស្វេត្រូវការ?

____________________________________________________________________________
____________________________________________________________________________

៣. តើលោកម៉ូសេបានផ្ទេរចំណេះដឹង និងបទពិសោធន៍នោះទៅឲ្យលោកយ៉ូស្វេយ៉ាងដូចម្តេច?

____________________________________________________________________________
____________________________________________________________________________

៤. តើលោកយ៉ូស្វេបានអភិវឌ្ឍ ឬរីកចម្រើនដូចម្តេច ដោយព្រោះតែលោកមានទំនាក់ទំនងជាមួយលោកម៉ូសេ?

____________________________________________________________________________
____________________________________________________________________________

៥. តើលោកម៉ូសេបានពង្រឹងលោកយ៉ូស្វេដូចម្តេច?

____________________________________________________________________________
____________________________________________________________________________

៦. តើអ្វីជាលទ្ធផលចុងក្រោយសម្រាប់ប្រជារាស្ត្ររបស់ព្រះ?

____________________________________________________________________________
____________________________________________________________________________

## លោកបាណាបាសជាឧបជ្ឈាយ៍

ជាលក្ខណៈរៀងៗខ្លួន ឬជាក្រុម ចូរអានខគម្ពីរទាំងនេះ ។ វាប្រហែលជាមានប្រយោជន៍ដោយចាត់តាំងឲ្យមានការអានតាមក្រុម និងចែកបាយចម្លើយនៅចុងបញ្ចប់ ។

កិច្ចការ ៩:២៧-២៩, ១១:២៥-២៦, ១៥:៣៦-៤១, កូឡុស ៤:១០, ១ ពេត្រុស ៥:១៣, កិច្ចការ ១២:២៥, ១៣:៤-៥, ១៣:១៣, ភីលេម៉ូន ១:២៤ ។

## ជាមួយលោកសុលអ្នកស្រុកតើសុស | លោកប៉ុល

បីឆ្នាំក្រោយពីការប្រែចិត្តរបស់លោកនៅក្រុងដាម៉ាសមក សុលអ្នកស្រុកតាសុស បានធ្វើដំណើរទៅក្រុងយេរូសាឡិម ដើម្បីជួបជាមួយពួកសាវក (កាឡាទី ១:១៨) ។ ទោះបីយ៉ាងណាក៏ដោយ ពួកអ្នកជឿនៅទីនោះស្ទាក់ស្ទើរមិនហ៊ានជឿថា អ្នកបៀតបៀនពួកគេកាលពីមុនឥឡូវនេះជាអ្នករួមជំនឿនៅក្នុងព្រះគ្រិស្តទេ ។ លោកបាណាបាសបានប្រថុយកិត្តិយសរបស់លោកដើម្បីធ្វើជាអ្នកសម្រុះសម្រួល ដែលតាមរយៈលោក នោះលោកសុលជាអ្នកជឿត្រូវបានទទួលចូលមកក្នុងការប្រកបគ្នារបស់ពួកសាវក និងអ្នកជឿ ។ ក្រោយមក ពួកសាវកបានចាត់លោកបាណាបាសឲ្យទៅសង្កេតមើល លើកទឹកចិត្ត និងពង្រឹងក្រុមជំនុំថ្មីដែលជាសាសន៍ដទៃនៅក្រុងអាន់ទីយ៉ូក ។ ភ្លាមនោះ លោកបានឃើញឱកាសដើម្បីអភិវឌ្ឍព័ន្ធកិច្ចរបស់លោកសុលថែមទៀត ដូច្នេះ លោកបាននាំលោកសុលពីក្រុងតើសុសធ្វើដំណើរទៅក្រុងអាន់ទីយ៉ូក ។ នៅទីនោះ ដោយមានលោកបាណាបាសជាឧបជ្ឈាយ៍របស់លោក លោកសុលបានចាប់ផ្តើមរីកចម្រើននៅក្នុង

ព័ន្ធកិច្ចរបស់លោក ។ លោកបាណាបាសបង្ហាញប្រាប់ជំហានដ៏សំខាន់នៅក្នុងដំណើរការឧបជ្ឈាយ៍ ដោយអនុញ្ញាតឲ្យលោកសុល (ឥឡូវនេះគឺជាលោកប៉ុល) មានតួនាទីថ្មីធ្វើជាអ្នកដឹកនាំ ។ នៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណ លោកបានបញ្ចេញសទ្ធិវិហារិករបស់លោកឲ្យទៅបំពេញតួនាទីតាមការដែលព្រះបានត្រាស់ហៅលោកប៉ុល ។

- បាណាបាសគឺជាឈ្មោះដែលពួកសាវកបានដាក់ឲ្យ ដែលមានន័យថា «កូននៃការលើកទឹកចិត្ត» (កិច្ចការ ៤:៣៦) ។
- ទំនាក់ទំនងឧបជ្ឈាយ៍ត្រូវបានលោកបាណាបាសជាអ្នកផ្តួចផ្តើមឡើង (កិច្ចការ ៩:២៧) ។
- លោកបានឃើញ ឬបានយល់អំពីសក្តានុពលរបស់លោកសុលសម្រាប់ព្រះរាជ្យរបស់ព្រះ (កិច្ចការ ៩:២៧-២៩) ។
- លោកបានរកឃើញកន្លែងធ្វើព័ន្ធកិច្ចសម្រាប់លោកសុល និងចែករម្លែកព័ន្ធកិច្ចជាមួយលោក (កិច្ចការ ១១:២៥-២៦) ។
- លោកបានធ្វើជាគំរូ ដែលក្រោយមកលោកប៉ុលអាចត្រាប់តាមនៅក្នុងព័ន្ធកិច្ចរបស់លោកផ្ទាល់ (១ កូរិនថូស ១១:១, ២ ធីម៉ូថេ ២:២) ។
- លោកអាចអនុញ្ញាតឲ្យលោកប៉ុលមានតួនាទីដឹកនាំ (កិច្ចការ ១៣:៧-៤៦) ។
- លោកបាណាបាសក៏បានធ្វើជាឧបជ្ឈាយ៍ដល់លោកយ៉ូហាន ម៉ាកុស ដែលរួមជាមួយលោកប៉ុល បានសរសេរមួយភាគបីនៃសញ្ញាថ្មី ។

១. ចូរពណ៌នាអំពីរបៀបដែលទំនាក់ទំនងរវាងលោកបាណាបាស និងលោកសុល (លោកប៉ុល) បានកើតឡើង ។

______________________________________________________________________

______________________________________________________________________

២. តើលោកបាណាបាសមានចំណេះដឹង ឬបទពិសោធន៍អ្វីដែលលោកប៉ុលត្រូវការ?

______________________________________________________________________

______________________________________________________________________

៣. តើចំណេះដឹង និងបទពិសោធន៍នោះត្រូវបានផ្ទេរទៅឲ្យលោកប៉ុលដោយរបៀបណា?

______________________________________________________________________

______________________________________________________________________

៤. តើលោកប៉ុលបានអភិវឌ្ឍ ឬរីកចម្រើនដូចម្តេច ដោយព្រោះតែទំនាក់ទំនងរបស់លោកជាមួយនឹងលោកបាណាបាស?

______________________________________________________________________

______________________________________________________________________

៥. តើលោកបាណាបាសបានពង្រឹងលោកប៉ុលដូចម្តេច?

______________________________________________________________________

______________________________________________________________________

៦. តើលោកបាណាបាសធ្វើជាឧបជ្ឈាយ៍ដល់លោកប៉ុលមានលទ្ធផលវិជ្ជមានដូចម្តេច?

______________________________________________________________________

______________________________________________________________________

## ជាមួយលោកយ៉ូហាន ម៉ាកុស

១. ហេតុអ្វីបានជាលោកប៉ុលលែងចង់បន្តធ្វើការជាមួយលោកយ៉ូហាន ម៉ាកុសទៀត?

______________________________________________________________________

______________________________________________________________________

២. តើលោកបាណាបាស និងលោកប៉ុលបានសម្រេចចិត្តដូចម្តេច?

______________________________________________________________________

______________________________________________________________________

៣. តើលោកប៉ុល និងលោកបាណាបាសនឹងធ្វើជាឧបជ្ឈាយ៍ដល់នរណា?

______________________________________________________________________

______________________________________________________________________

៤. តើការធ្វើជាឧបជ្ឈាយ៍របស់លោកប៉ុល និងលោកបាណាបាសមានលទ្ធផលដូចម្តេច?

______________________________________________________________________

______________________________________________________________________

## លោកប៉ុលជាឧបជ្ឈាយ៍

លោកប៉ុលបានត្រាប់តាមការធ្វើជាឧបជ្ឈាយ៍ដែលលោកបានទទួលពីលោកបាណាបាសនៅក្នុងដំណើរបេសកកម្មក្រោយមកទៀតរបស់លោក ។ នៅក្នុងកណ្ឌគម្ពីរកិច្ចការ និងនៅក្នុងពួកសំបុត្ររបស់លោកប៉ុល មនុស្សដប់ប្រាំមួយនាក់ត្រូវបានលើកឡើងថាបានធ្វើការរួមគ្នាជាមួយលោកប៉ុល ។ លោកលូកាប្រាប់ឈ្មោះមនុស្សដប់ប្រាំពីរនាក់ទៀតថាជាគូកនរបស់លោកប៉ុលនៅក្នុងដំណើរបេសកកម្មមួយលើក ឬច្រើនលើករបស់លោក ។ មិនមានការលើកឡើងថា អ្នកទាំងអស់នេះបានទទួលផលប្រយោជន៍ចេញពីការណែនាំរបស់លោក និងពីទំនាក់ទំនងរបស់លោកជាមួយពួកគេទេ ។ សេចក្តីស្រឡាញ់ដែលលោកបង្ហាញចេញចំពោះពួកគេនៅក្នុងសំបុត្ររបស់លោកបញ្ជាក់ប្រាប់អំពីការនេះ ។ ពួកបាសទុំដែលបានដឹកនាំក្រុមជំនុំនៅក្រុងអេភេសូរគឺជាផលកើតចេញពីការធ្វើជាឧបជ្ឈាយ៍របស់លោកប៉ុល ក៏មានអ្នកដឹកនាំក្រុមជំនុំទាំងប្រាំពីរនៅស្រុកអាស៊ីផងដែរ (កិច្ចការ ១៩:១០ វិវរណៈ ២:៣) ។ ក្រោយមក លោកប៉ុលបានសរសេរសំបុត្ររៀបរាប់អំពីខ្លឹមសារនៅក្នុងការណែនាំផ្ទាល់ខ្លួនរបស់លោកទៅមនុស្សពីរនាក់ជាពិសេស—លោកធីម៉ូថេ និងលោកទីតុស ។ លោកប៉ុលហៅពួកគេទាំងពីរនាក់ថាជា «កូនខាងឯជំនឿ» ប្រហែលជាបង្ហាញប្រាប់ថា ពួកគេគឺ

ជាអ្នកប្រែចិត្តរបស់លោក ។ ចូរពិនិត្យមើលកណ្ឌគម្ពីរកិច្ចការ ពួកសំបុត្ររបស់លោកប៉ុល និងសំបុត្រទៅលោកធីម៉ូថេ និងលោកទីតុស ដើម្បីរកមើលលក្ខណៈនៃការយកចិត្តទុកដាក់របស់លោកប៉ុលក្នុងនាមជាឧបជ្ឈាយ៍ចំពោះសទ្ធិវិហារិកដ៏ល្បីល្បាញរបស់លោក ។

ជាលក្ខណៈរៀងៗខ្លួន ឬជាក្រុម ចូរអានខគម្ពីរទាំងនេះ ។ វាប្រហែលជាមានប្រយោជន៍ដោយចាត់តាំងឲ្យមានការអានតាមក្រុម និងចែកចាយចម្លើយនៅចុងបញ្ចប់ ។

**កិច្ចការ ១៦:១-៥**, ១៧:១៤, ១៩:២២, ២០:៤, ១ កូរិនថូស ៤:១៧, ២ កូរិនថូស ១:១, ១៩, **៧:៥-១៦**, ៨:៦, **១៦-២៤**, ១២:១៨ **កាឡា**ទី ២:១-៣ ភីលីព ២:១៩-២២, ២ ថែស្សា**ឡូ**នីច ៣:១-៣, ៦, ១ ធីម៉ូថេ ១:២, ១៨-២០, ២ ធីម៉ូថេ ៤:១០ ទីតុស ១:៤-៥។

១. ចូរពណ៌នាអំពីរបៀបដែលលោកប៉ុលបានប្រើទំនាក់ទំនងជាមួយយុវជនទាំងនេះ ដើម្បីអភិវឌ្ឍពួកគេឲ្យទៅជាអ្នកដឹកនាំ ។

______________________________________________________________________________

______________________________________________________________________________

២. តើលោកប៉ុលចេះអ្វីខ្លះ និងមានបទពិសោធន៍អ្វីខ្លះ ដែលលោកធីម៉ូថេ និងលោកទីតុសត្រូវការចេះ?

______________________________________________________________________________

______________________________________________________________________________

៣. តើចំណេះដឹង និងបទពិសោធន៍អ្វីខ្លះដែលបានផ្ទេរទៅឲ្យលោកធីម៉ូថេ និងលោកទីតុស?

______________________________________________________________________________

______________________________________________________________________________

៤. តើលោកធីម៉ូថេ និងលោកទីតុសបានអភិវឌ្ឍ និងរីកចម្រើនដូចម្តេច ដោយព្រោះតែទំនាក់ទំនងរបស់ពួកគេជាមួយលោកប៉ុល?

______________________________________________________________________________

______________________________________________________________________________

៥. តើលោកប៉ុលបានពង្រឹងសទ្ធិវិហារិករបស់លោកដូចម្តេច?

______________________________________________________________________________

______________________________________________________________________________

៦. តើការធ្វើជាឧបជ្ឈាយ៍របស់លោកប៉ុលមានលទ្ធផលជាវិជ្ជមានដូចម្តេច?

______________________________________________________________________________

______________________________________________________________________________

## ការឲ្យនិយមន័យ « ការធ្វើជាឧបជ្ឈាយ៍»




## ហេតុអ្វីបានជាយើងគួរតែមានចេតនា ?

> *ការធ្វើជាឧបជ្ឈាយ៍គឺជា «បទពិសោធន៍ទំនាក់ទំនងដែលក្នុងនោះ មនុស្សម្នាក់ពង្រឹងមនុស្សម្នាក់ទៀតដោយចែករំលែកធនធានដែលព្រះបានប្រទានឲ្យ» – ស្តិនលី និងគ្លីនតុន ។*

និយមន័យមួយផ្សេងទៀតដែលស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងនិយមន័យទីមួយ:
*«សម្រាប់ចេតនា និងគោលបំណងទាំងអស់...**ការធ្វើជាឧបជ្ឈាយ៍**គឺជាសកម្មភាពជួយមនុស្សម្នាក់ទៀតឲ្យរីកចម្រើននៅក្នុងជំនាញ អត្តចរិត និងចំណេះដឹងរបស់គេនៅផ្នែកណាមួយនៃជីវិត ។ ជាធម្មតា **ការធ្វើជាឧបជ្ឈាយ៍**ប្រាប់ដោយប្រយោលថា ម្នាក់ក្នុងចំណោមអ្នកទាំងពីរមានបទពិសោធន៍ច្រើនជាង មានចំណេះដឹងច្រើនជាង ដូច្នេះហើយមានសេចក្តីដែលស័ក្តិសមនឹងផ្ទេរទៅឲ្យអ្នកដែលក្មេងជាង មានបទពិសោធន៍តិចជាង និងមានចំណេះដឹងទាបជាង ។ ប្រព័ន្ធផ្គត់ផ្គង់សម្រាប់«**ការផ្ទេរ**»យ៉ាងដូច្នេះ គឺជាអ្វីដែលយើងកំពុងហៅថា**ការធ្វើជាឧបជ្ឈាយ៍**» ។*
–អូស្ទ័រហាយស៍ និង តេចា (Osterhouse and Teja) ។

១. **ការធ្វើជាឧបជ្ឈាយ៍**គឺជាដំណើរការ**<u>ទំនាក់ទំនង</u>** ។
២. ឧបជ្ឈាយ៍មានបទពិសោធន៍ដើម្បី**<u>ចែករំលែក</u>** ។
៣. មានអ្វីផ្ទេរឲ្យ (ធនធាន ព័ត៌មាន)
៤. ឧបជ្ឈាយ៍**<u>សម្របសម្រួលឲ្យមានការអភិវឌ្ឍន៍</u>** ។
៥. ឧបជ្ឈាយ៍**<u>ពង្រឹង</u>** ។

លោកអ្នកប្រហែលជាចង់សួរសំណួរបន្ថែមមួយចំនួន ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីធាតុជាក់លាក់របស់និយមន័យទាំងនេះ:

**ទំនាក់ទំនង – ចេតនា – ចែករំលែក – សម្របសម្រួលឲ្យមានការអភិវឌ្ឍន៍ - ពង្រឹង**

- តើ« ដំណើរការទំនាក់ទំនង »មានន័យដូចម្ដេច?
- តើដំណើរការធ្វើជាឧបជ្ឈាយ៍មានគោលបំណងអ្វី?
- តើផ្នែកណាខ្លះ និងបទពិសោធន៍អ្វីខ្លះពាក់ព័ន្ធនៅក្នុងការធ្វើជាឧបជ្ឈាយ៍?
- តើឃ្លា «សម្របសម្រួលឲ្យមានការអភិវឌ្ឍន៍ ឬការពង្រឹង» មានន័យដូចម្ដេច?
    ១. ចែកចាយបទពិសោធន៍អំពីពេលដែលលោកអ្នកមានឧបជ្ឈាយ៍ណែនាំ ។
    ២. ប្រសិនបើលោកអ្នកចាំថាជានរណា ចូរនិយាយអំពីការនោះ ។
    ៣. តើការមានឧបជ្ឈាយ៍កើតឡើងដោយឯកឯង ឬដោយរៀបចំផែនការ?

## និយមន័យ « *ឧបជ្ឈាយ៍* »

លោក **MENTOR** (ដែលប្រែថា ឧបជ្ឈាយ៍) ជាតួអង្គមួយនៅក្នុងកំណាព្យ *អូឌីស៊ី* ដែលជាអ្នកមើលខុសត្រូវលើកូនប្រុសរបស់អូឌីស៊ុស ឈ្មោះ តេលេម៉ាគូស ។ *ម៉ិនធ័រ* បានធ្វើជាទីប្រឹក្សា និងជាគ្រូរបស់គាត់ ។

ពាក្យ «ម៉ិនធ័រ» មានប្រភពនៅក្នុងកំណាព្យវីរកថារបស់លោកហូម័រ ដែលមានចំណងជើងថា អូឌីស៊ី ។ នៅពេលដែលអូឌីស៊ុសបានចាកចេញទៅធ្វើចម្បាំងត្រូចាន់ គាត់បានប្រគល់កូនប្រុសរបស់គាត់ឈ្មោះ តេលេម៉ាគូស ឲ្យអ្នកបម្រើដ៏វៃឆ្លាត និងដ៏ទុកចិត្តម្នាក់ឈ្មោះ មិនធ័រ ជាអ្នកមើលថែ ។ លោក មិនធ័រ ទទួលខុសត្រូវណែនាំការអភិវឌ្ឍន៍ខាងសង្គម ការអប់រំ និងការរៀបចំសម្រាប់ជីវិតរបស់អ្នកកំឡោះនេះ ។ ដូច្នេះហើយ មិនធ័រ ឬឧបជ្ឈាយ៍ត្រូវបានឲ្យនិយមន័យជាទូទៅថាជាទីប្រឹក្សា និងជាគ្រូដ៏វៃឆ្លាត និងដ៏ជាទីទុកចិត្ត ។ និយមន័យនេះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងនិយមន័យតាមវចនានុក្រមបទដ្ឋាន: «មគ្គុទេសន៍ ឬទីប្រឹក្សាដ៏ជាទីទុកចិត្ត» ។ ឧបជ្ឈាយ៍គឺជាអ្នកដ៏មានបទពិសោធន៍ដែលមានទំនាក់ទំនងបែបអភិវឌ្ឍជាមួយបុគ្គលដែលមានបទពិសោធន៍តិចជាង ដោយមានគោលបំណងបង្កើនសមត្ថភាព ជំនាញ ទស្សនៈ និងភាពពេញវ័យខាងវិញ្ញាណរបស់បុគ្គលនោះពាក់ព័ន្ធនឹងព័ន្ធកិច្ច ។

## និយមន័យ « *សទ្ធិវិហារិក* »

*សទ្ធិវិហារិក និង_អ្នកហាត់ការ* ត្រូវបានប្រើជាទូទៅដើម្បីពណ៌នាអំពីបុគ្គលទីពីរនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ។ ពាក្យនីមួយៗនេះ បង្ហាញប្រាប់អត្ថន័យនៃការពឹងអាងលើ និងការគ្រប់គ្រង ឬការការពារពីឧបជ្ឈាយ៍ ដែលជួយឲ្យយល់អំពីគោលគំនិតពាក់ព័ន្ធនឹងព័ន្ធកិច្ចដាំក្រុមជំនុំ ។

១. សទ្ធិវិហារិក គឺជាអ្នករៀនសូត្រ**<u>ដែលសកម្ម</u>** ដែលស្ម័គ្រចិត្តធ្វើដំណើរដែលជួយដល់ការអភិវឌ្ឍន៍ខ្លួន ។

សទ្ធិវិហារិក គឺជាអ្នកចូលរួមដែលសកម្ម ឬអកម្ម? ហេតុអ្វី?

________________________________________________________________________

________________________________________________________________________

ដែលសកម្ម

២. សទ្ធិវិហារិកខិតខំប្រឹងប្រែងដើម្បី**<u>វាយតម្លៃ</u>** **<u>យកដាក់ក្នុងខ្លួន</u>** និង**<u>ប្រើ</u>**ចំណេះដឹង ជំនាញ **ការ**យល់ដឹង ទស្សនៈ ឬប្រាជ្ញាដែលបានផ្តល់ឲ្យនោះយ៉ាងមានប្រសិទ្ធភាព ។

ហេតុអ្វីបានជាសំខាន់ដែលសទ្ធិវិហារិកត្រូវវាយតម្លៃ ឬយកដាក់ក្នុងខ្លួននូវអ្វីដែលគេបានទទួលមកពីឧបជ្ឈាយ៍?

______________________________________________________________________________

______________________________________________________________________________

## អ្នកបង្កើតសិស្ស ឧបជ្ឈាយ៍ គ្រូបង្វឹក

| | | |
|---|---|---|
| យើងបង្កើតសិស្ស | **<u>អ្នកជឿ</u>**ថ្មី | គ្រឹះ |
| *ចាក់គ្រឹះ* | | |
| យើងធ្វើជាឧបជ្ឈាយ៍ | **<u>អ្នកដឹកនាំ</u>**ដែលកំពុងលេចធ្លោ | **ការ**ផ្ទេរ |
| *ផ្តល់**ការ**ផ្ទេរអំពីភាពជា**អ្នកដឹកនាំ*** | | |
| យើងបង្វឹក | **<u>ប្រតិបត្តិករ</u>**ព័ន្ធកិច្ច | **ការ**សម្របសម្រួល |
| *ជួយពួកគេបង្កើតផលផ្លែ* | | |

នៅត្រង់ចំណុចនេះ វាប្រហែលជាចាំបាច់ដែលត្រូវតែបញ្ជាក់ឲ្យច្បាស់អំពីគោលគំនិតមួយចំនួនដែលអាចភាន់ច្រឡំនៅក្នុង**ការ**ពិភាក្សាដ៏ពេញនិយមអំពី**ការ**ធ្វើជាឧបជ្ឈាយ៍ ។ នៅក្នុងបញ្ញត្តិចុងក្រោយរបស់ព្រះយេស៊ូ ព្រះអង្គបានបង្គាប់**អ្នក**ដើរតាមព្រះអង្គឲ្យបង្កើតសិស្សនៅគ្រប់ទាំងសាសន៍ ។ តើ**ការ**បង្កើតសិស្ស និង**ការ**ធ្វើជាឧបជ្ឈាយ៍មានន័យតែមួយ និងសម្រេចគោលដៅតែមួយដែរឬទេ? **អ្នក**និពន្ធមួយចំនួនចាត់ទុក**ការ**បង្កើតសិស្សជាដំណើរពេញមួយជីវិតដែលនាំឲ្យរីកចម្រើនខាងវិញ្ញាណ ខណៈពេលដែល**អ្នក**និពន្ធខ្លះទៀតចាត់ទុក**ការ**បង្កើតសិស្សជា**ការ**ហ្វឹកហ្វឺនដំបូងនៅក្នុង**ការ**រស់នៅជាគ្រិស្តបរិស័ទ ។ **អ្នក**ខ្លះទៀតបានយោងទៅរក**ការ**ធ្វើជាឧបជ្ឈាយ៍ថាជា**ការ**បង្កើតសិស្សកម្រិតខ្ពស់ ។ តើ**ការ**បង្កើតសិស្សជំនួសដោយ**ការ**ធ្វើជាឧបជ្ឈាយ៍នៅត្រង់ចំណុចណា? តើ**ការ**ធ្វើជាឧបជ្ឈាយ៍ខុសពីគោលគំនិតពាក់ព័ន្ធអំពី**ការ**បង្កើតសិស្ស និង**ការ**បង្វឹកយ៉ាងដូចម្តេច?

## សេចក្តីបញ្ចប់

នៅក្នុងការធ្វើជាឧបដ្ឋាយ៍ តើផ្នែកអ្វីខ្លះដែលធ្វើឲ្យលោកអ្នកផ្ទាល់រំភើបចិត្តបំផុត?

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

នៅក្នុងការធ្វើជាឧបដ្ឋាយ៍ តើលោកអ្នកគិតថា ផ្នែកអ្វីខ្លះដែលពិបាកជាងគេបំផុត?

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

តាមពាក្យរបស់លោកអ្នក តើឧបដ្ឋាយ៍ជាអ្វី?

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

តាមពាក្យរបស់លោកអ្នក តើសទ្ធិវិហារិកជាអ្វី?

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

# ម៉ោងទី ២
# ការធ្វើជាឧបជ្ឈាយ៍ដល់សិស្សពេញវ័យ

*«អ្នកមិនអាចបង្រៀនអ្វីដល់មនុស្សទេ ។ អ្នកគ្រាន់តែអាចជួយគេឲ្យរកការនោះនៅក្នុងខ្លួនគេប៉ុណ្ណោះ»-ហ្កាលីលីអូ ហ្កាលីឡេ*

## កម្មវត្ថុ

- ដើម្បីញែកគរុកោសល្យកុមារចេញពីគរុកោសល្យមនុស្សពេញវ័យ ។
- ដើម្បីបង្ហាញថា អ្នកដាំក្រុមជំនុំគឺជាសិស្សពេញវ័យ ។
- ដើម្បីស្វែងយល់អំពីរបៀបរៀនសូត្ររបស់មនុស្សពេញវ័យ ។
- ដើម្បីរកឲ្យឃើញបញ្ហាប្រឈមដែលសិស្សពេញវ័យជួបប្រទះ ។
- ដើម្បីកត់ត្រាផលប្រយោជន៍របស់ការធ្វើជាឧបជ្ឈាយ៍ សម្រាប់ឧបជ្ឈាយ៍ និងសទ្ធិវិហារិក ។

ចូរពិភាក្សាអំពីការខុសប្លែកគ្នារវាងការបង្រៀនមនុស្សពេញវ័យ និងការបង្រៀនកុមារ ។

*គរុកោសល្យកុមារ* ត្រូវបានប្រើជាទូទៅដើម្បីយោងទៅរកវិធីសាស្ត្រ និងយុទ្ធសាស្ត្រសម្រាប់ការបង្រៀន ។ ទោះបីជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនៅពេលថ្មីៗខាងការអប់រំសម្រាប់មនុស្សពេញវ័យបានបង្ហាញឲ្យឃើញថា វិធីរៀនរបស់មនុស្សពេញវ័យខុសប្លែកច្រើនពីរបៀបរៀនរបស់កុមារ និងយុវជន ។ ការសិក្សាទាំងនេះបាននាំទៅរកការណែនាំអំពីវិធីសាស្ត្រថ្មីដែលមានលក្ខណៈជាយុទ្ធសាស្ត្រសម្រាប់ការអប់រំរបស់មនុស្សពេញវ័យហៅថា *គរុកោសល្យមនុស្សពេញវ័យ* ។

| គរុកោសល្យកុមារ | គរុកោសល្យមនុស្សពេញវ័យ |
|---|---|
| ពាក្យក្រិក π αιδος «ផេហ្តូស» កុមារ និង γωγος «ហ្គូហ្គូស» ដឹកនាំ | ពាក្យ ἀνήρ មនុស្ស និង ἀγωγή ជួយ ឬណែនាំ |
| វិទ្យាសាស្ត្រ និងសិល្បៈនៃ**<u>ការបង្រៀនកុមារ</u>** | វិទ្យាសាស្ត្រ និងសិល្បៈនៃ**<u>ការជួយមនុស្សពេញវ័យរៀន</u>** |

**កំណត់សម្គាល់:** ទោះបីជាសិក្ខាកាមជាច្រើននឹងឲ្យនិយមន័យគរុកោសល្យមនុស្សពេញវ័យថាជា «ការបង្រៀនមនុស្សពេញវ័យ»ក៏ដោយ ចម្លើយពិតប្រាកដគឺថា គរុកោសល្យមនុស្សពេញវ័យគឺជា*សិល្បៈ និងវិទ្យាសាស្ត្រនៃការជួយមនុស្សពេញវ័យរៀន*។ ការខុសប្លែកគ្នានេះមានសារៈសំខាន់យ៉ាងខ្លាំង ហើយគួរតែត្រូវបានសង្កត់ធ្ងន់ឲ្យបានញឹកញាប់ ។

## លក្ខណៈរបស់សិស្សពេញវ័យ

សទ្ធិវិហារិកគឺជាសិស្សពេញវ័យ ។ ម្នាក់ៗមានបទពិសោធន៍ពេញមួយជីវិតដែលមានប្រយោជន៍ដើម្បីវិភាគ ហើយវាយតម្លៃព័ត៌មានថ្មីៗ និងធ្វើការសម្រេចចិត្ត ។ ទោះបីយ៉ាងណាក៏ដោយ ពួកគេភាគច្រើនខ្វះបទពិសោធន៍នៅក្នុងព័ន្ធកិច្ចដាំក្រុមជំនុំ និងព័ន្ធកិច្ចគ្រូគង្វាល ។ យ៉ាងណាមិញ សទ្ធិវិហារិកបានជ្រើសរើសចូលទៅក្នុងដំណាក់កាលថ្មីនៃការហ្វឹកហ្វឺនសម្រាប់ព័ន្ធកិច្ច ។ ពួកគេស្វែងរកជំនួនដីវៃឆ្លាតដើម្បីសម្របសម្រួលដល់ការអភិវឌ្ឍន៍របស់ពួកគេ ។ អ្នកដែលធ្វើជាឧបជ្ឈាយ៍របស់ពួកគេត្រូវចូលទៅក្នុងទំនាក់ទំនងដោយយល់អំពីរបៀបដែលមនុស្សពេញវ័យរៀនបានល្អបំផុត ។

១. ពួកគេ**ស្វ័យដឹកនាំ** ។
២. ពួកគេធ្វើ**ការសម្រេចចិត្ត** និងទទួលយកការទទួលខុសត្រូវ ។
៣. ពួកគេនាំយក**បទពិសោធន៍**មកក្នុងដំណើរការរៀនសូត្រ ។
៤. ពួកគេ**ផ្តោត**លើបញ្ហាប្រឈមដែលពួកគេចង់ដោះស្រាយ ។
៥. ពួកគេ**ស្វ័យបណ្តាលចិត្ត** ត្រៀមខ្លួនរួចជាស្រេចដើម្បីរៀន ។
៦. ពួកគេទាមទារ**ការអនុវត្តន៍ភ្លាមៗ** ។

## ហេតុអ្វីបានជាចាំបាច់ត្រូវដឹងអំពីលក្ខណៈរបស់សិស្សពេញវ័យ?

ចូរពន្យល់ប្រាប់សិក្ខាកាមថា នៅក្នុងមេរៀននេះ លោកអ្នកនឹងស្វែងយល់អំពីការធ្វើជាឧបជ្ឈាយ៍ពាក់ព័ន្ធនឹងលក្ខណៈសេចក្តីត្រូវការ និងសមត្ថភាពរបស់សិស្សពេញវ័យ ។ ការនេះបង្កើតជាសំណួរពាក់ព័ន្ធមួយផ្សេងទៀត៖ តើការធ្វើជាឧបជ្ឈាយ៍ខុសពីការហ្វឹកហ្វឺន និងការអភិវឌ្ឍន៍មនុស្សពេញវ័យដោយប្រើវិធីអប់រំពីបុរាណយ៉ាងដូចម្តេច?

១. សិស្សពេញវ័យស្វ័យដឹកនាំ ។ ឧបជ្ឈាយ៍គួរតែសង្កត់ធ្ងន់លើរបៀបវារៈរបស់សទ្ធិវេហារិក មិនមែនដាក់ចេញរបៀបវារៈរបស់ខ្លួនឯងទេ ។ តើមានអ្វីអាចកើតឡើង ប្រសិនបើឧបជ្ឈាយ៍ដាក់ចេញរបៀបវារៈរបស់ខ្លួនឯង?

___
___
___

២. ពួកគេធ្វើការសម្រេចចិត្តខ្លួនឯង ។ ឧបជ្ឈាយ៍គួរតែណែនាំសទ្ធិវិហារិកនៅក្នុងការសម្រេចចិត្តដ៏ត្រឹមត្រូវដោយខ្លួនឯង មិនមែនប្រាប់ចម្លើយទេ ។ តើមានអ្វីកើតឡើង ប្រសិនបើឧបជ្ឈាយ៍ធ្វើការសម្រេចចិត្តជំនួសសទ្ធិវិហារិក? តើនោះគឺជាការសម្រេចចិត្តរបស់អ្នកណា?

___
___
___

**ស្វ័យដឹកនាំ – ការសម្រេចចិត្ត – បទពិសោធន៍ – ផ្តោតអារម្មណ៍ – ស្វ័យបណ្តាលចិត្ត – ការអនុវត្តន៍ភ្លាមៗ**

៣. ពួកគេមានបទពិសោធន៍យ៉ាងច្រើន ។ ចំណុចនេះគួរតែយកមកធ្វើ**ការ**ពិចារណា ដើម្បីជួយដល់**ការ**ធ្វើជាឧបជ្ឈាយ៍ ។ បទពិសោធន៍ដ៏ច្រើនរបស់សទ្ធិវិហារិកផ្តល់ឲ្យពួកគេមានសមត្ថភាពវាយតម្លៃ និងប្រមូលផ្តុំព័ត៌មាន និងបទពិសោធន៍ថ្មីៗ ។ តើបទពិសោធន៍ក្រៅព័ន្ធកិច្ចអាចជួយពួកគេដោះស្រាយបញ្ហានៅក្នុងព័ន្ធកិច្ចបានយ៉ាងដូចម្តេច?

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

៤. ពួកគេផ្តោតលើបញ្ហាប្រឈមរបស់ពួកគេ ។ ឧបជ្ឈាយ៍គួរតែផ្អែក**ការ**ធ្វើជាឧបជ្ឈាយ៍របស់ខ្លួនលើ**ការ**ជួយសទ្ធិវិហារិកស្វែងរកវិធីផ្សេងៗដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ពួកគេ ។ **ការ**ស្វែងរកដំណោះស្រាយជាក់ស្តែង មិនមែនគ្រាន់តែទ្រឹស្តី ដែលអាច ឬមិនអាចអនុវត្តបាននោះទេ ។ តើបទពិសោធន៍របស់សទ្ធិវិហារិកអាចជាឧបករណ៍ដើម្បីស្វែងរកដំណោះស្រាយជាក់ស្តែងនៅក្នុង**ការ**ដាំក្រុមជំនុំបានយ៉ាងដូចម្តេច?

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

៥. ពួកគេស្វ័យបណ្តាលចិត្ត ។ ឧបជ្ឈាយ៍មិនត្រូវបង្ខំសទ្ធិវិហារិករបស់ខ្លួនឲ្យរៀនទេ ។ គ្រឿងបណ្តាលចិត្តដ៏មានអំណាចបំផុតគឺជាសំពាធខាងក្នុងឲ្យសម្រេចគោលដៅរបស់ពួកគេ ។ តើពួកគេបានរៀនមេរៀនដ៏មានតម្លៃនៅពេលណា? តើសេចក្តីនោះចេញមកពី**ការ**បណ្តាលចិត្តផ្ទាល់ខ្លួននៅពេលណា ឬតាមរយៈ**ការ**បណ្តាលចិត្តរបស់គ្រូនៅពេលណា?

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

៦. ពួកគេទាមទារ**ការ**អនុវត្តន៍ភ្លាមៗ ។ ដោយប្រៀបធៀបទៅនឹងកុមារ សិស្សពេញវ័យត្រូវ**ការ**អនុវត្តភ្លាមៗនូវអ្វីដែលពួកគេកំពុងរៀន បើមិនដូច្នោះទេ គ្មានតម្លៃឡើយ ។ ពួកគេនឹងឈប់ចូលរួម ប្រសិនបើពួកគេមិនឃើញរបៀបអនុវត្តអ្វីដែលពួកគេកំពុងរៀនមកក្នុងជីវិតរបស់ពួកគេទេនោះ ។

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

## របៀបរៀន

សទ្ធិវិហារិកដែលដាំក្រុមជំនុំតំណាងឲ្យក្រុមមនុស្សផ្សេងគ្នា ដែលម្នាក់ៗមានសមត្ថភាព និងសេចក្តីត្រូវ**ការ**រៀនៗខ្លួន ។ យើងប្រើពាក្យ របៀបរៀន ដើម្បីពណ៌នាអំពីវិធីដែលមនុស្សម្នាក់ៗទទួលបានព័ត៌មានថ្មី ។ មិនមែនមនុស្សគ្រប់គ្នាសុទ្ធតែរៀនតាមរបៀបតែមួយទេ—របៀបរៀនមានមកពីកំណើតសម្រាប់មនុស្សម្នាក់ៗ ។ បទពិសោធន៍នៅក្នុង**ការ**រៀនសូត្រអាចត្រូវបង្កើនប្រសិទ្ធភាពជាអតិបរិមា តាមរយៈ**ការ**កែឆ្នៃ**ការ**ផ្តល់ព័ត៌មានថ្មីតម្រូវតាមអ្នករៀនសូត្រម្នាក់

ៗ ដោយប្រើវិធីសាស្ត្រផ្សេងៗដើម្បីសម្របសម្រួលឲ្យមានការយល់ដឹង និងការស្រូបយកចំណេះដឹង ។ របៀបដែលបានរៀបរាប់ខាងក្រោមតំណាងឲ្យវិធីដែលពួកអ្នកស្រាវជ្រាវបានទទួលស្គាល់ជាទូទៅ ។ ការពណ៌នាទាំងនេះជួយសទ្ធិវិហារិកឲ្យរកឃើញរបៀបរៀនរបស់ពួកគេ ដើម្បីបង្កើតតម្លៃនៃទំនាក់ទំនងឧបជ្ឈាយ៍ជាអតិបរិមា ។

**១. <u>សោតវិញ្ញាណ</u>** អ្នករៀនតាមសោតវិញ្ញាណ ឬតាមផ្ទាល់មាត់រៀនបានយ៉ាងល្អបំផុត នៅពេលដែលព័ត៌មានត្រូវបានផ្តល់មកតាមទម្រង់ជាសំឡេង ។ ពួកគេចងចាំ និងស្រូបបានច្រើនសម្រាប់ការបង្រៀន និងការពិភាក្សា ។

**២. <u>ចក្ខុវិញ្ញាណ:</u>** នៅពេលដែលព័ត៌មានត្រូវបានអាន ឬមើលឃើញ អ្នករៀនតាមចក្ខុវិញ្ញាណធ្វើបានយ៉ាងល្អ ។ ពួកគេចងចាំបានច្រើនបំផុតចេញពីក្រាហ្វិច រូបភាព និងរូបពន្យល់ ។

**៣. <u>កាយវិញ្ញាណ:</u>** អ្នករៀនតាមកាយវិញ្ញាណក៏ត្រូវបានហៅថាអ្នករៀនតាមការប៉ះពាល់ផងដែរ ។ ពួកគេគឺជាអ្នករៀនបែបរុករក ដែលសមត្ថភាពរៀនរបស់គេត្រូវបានបង្កើនឡើងតាមរយៈការប៉ះពាល់ និងការពិសោធន៍ ។

**៤. <u>បរិដ្ឋានជុំវិញ:</u>** ជាសុកភាពដែលព័ទ្ធជុំវិញ ពន្លឺ និងកម្រិតសីតុណ្ហភាពត្រឹមត្រូវបង្កើតសមត្ថភាពរបស់អ្នករៀនផ្អែកលើបរិដ្ឋានដើម្បីវិភាគ និងទទួលបានព័ត៌មានថ្មី ។

តើរបៀបរៀនរបស់លោកអ្នកគឺជាមួយណាក្នុងចំណោមរបៀបទាំងនេះ? ចូរចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន ដើម្បីគាំទ្រចម្លើយនេះ ។

___

___

___

តើលោកអ្នកអាចជួយសទ្ធិវិហារិករបស់លោកអ្នកឲ្យរកឃើញរបៀបរៀនរបស់គេបានដោយរបៀបណា?

___

___

___

តើលោកអ្នកអាចកែសម្រួលរបៀបធ្វើជាឧបជ្ឈាយ៍របស់លោកអ្នកឲ្យត្រូវតាមរបៀបរៀនរបស់សទ្ធិវិហារិករបស់លោកអ្នកបានយ៉ាងដូចម្តេច?

___

___

___

**បញ្ហាប្រឈមដែលអ្នកដាំក្រុមជំនុំជួបប្រទះ**

សទ្ធិវិហារិកគឺជាសមាជិកក្រុមមនុស្សផ្សេងៗគ្នាដែលមានការត្រាស់ហៅរួម ។ ពួកគេមកពីប្រជាសាស្ត្រផ្សេងៗគ្នា មានសេដ្ឋកិច្ច និងវិជ្ជាជីវៈផ្សេងៗគ្នា ។ កម្រិតអប់រំរបស់ពួកគេផ្សេងគ្នា សមត្ថភាពចំណេះដឹង និងសមត្ថភាពសតិ

**សោតវិញ្ញាណ – ចក្ខុវិញ្ញាណ – កាយវិញ្ញាណ – បរិដ្ឋានជុំវិញ**

បញ្ហាគឺផ្សេងគ្នាដែរ ដោយឆ្លុះបញ្ចាំងទៅនឹងបទពិសោធន៍របស់ពួកគេ ។ ពួកគេមានចាប់តាំងពីអ្នកដឹកនាំកម្រិតដំបូងរហូតដល់អ្នកដឹកនាំព័ន្ធកិច្ចដែលពេញវ័យខាងវិញ្ញាណ ។ មិនមានមនុស្សពីរនាក់ដែលមានល្បាយទេពកោសល្យ ជំនាញ សមត្ថភាព ឬអំណោយទានខាងវិញ្ញាណដូចគ្នាទេ ។ ដូច្នេះហើយ ត្រូវតែមានការផ្តោតអារម្មណ៍ឲ្យបានត្រឹមត្រូវលើការបំពាក់បំប៉នសទ្ធិវិហារិក ដើម្បីបំពេញតួនាទីដែលព្រះអម្ចាស់បានត្រាស់ហៅពួកគេឲ្យធ្វើ ដោយមិនពាក់ព័ន្ធនឹងប្រវត្តិ ឬដំណាក់កាលជីវិតដែលពួកគេចូលមកក្នុងដំណើរការហ្វឹកហ្វឺននេះទេ ។ ដំណើរការហ្វឹកហ្វឺនដ៏ចាំបាច់សម្រាប់ព័ន្ធកិច្ច និងការចូលមកក្នុងវិជ្ជាជីវៈនេះបង្ហាញប្រាប់បញ្ហាប្រឈមថ្មីដល់អ្នកដាំក្រុមជំនុំថ្មី ។ សទ្ធិវិហារិកអាចជាអ្នករកស៊ីចិញ្ចឹមគ្រួសារផង ជាព័ន្ធការីផង និងជាសិស្សផងក្នុងពេលតែមួយ ។ នេះគឺជាការបន្ថែមពីលើការទទួលខុសត្រូវ និងកាតព្វកិច្ចជាប្រចាំរបស់គេ ។

- ចូរសុំសិក្ខាកាមឲ្យប្រាប់ឧទាហរណ៍អំពីមនុស្សម្នាក់ដែលមានប្រវត្តិមិនល្អ តែក្រោយមកបានជឿលើព្រះគ្រិស្ត ហើយតាមរយៈឥទ្ធិពល និងការធ្វើជាឧបជ្ឈាយ៍របស់គ្រូគង្វាល និងអ្នកជឿដទៃទៀត គាត់បានពេញវ័យក្លាយជាអ្នកដឹកនាំគ្រិស្តបរិស័ទ ។

- ចូរសុំសិក្ខាកាមឲ្យរកឃើញបញ្ហាប្រឈមមួយដែលសទ្ធិវិហារិកទំនងជាជួបប្រទះនៅក្នុងការដាំក្រុមជំនុំ ។

១. <u>ការរក្សាតុល្យភាព</u> ការទទួលខុសត្រូវដែលមានស្រាប់

- គ្រួសារ
- ការងារ
- ការអប់រំ ការហ្វឹកហ្វឺនព័ន្ធការី
- ការរីកចម្រើន និងសុខភាពខាងវិញ្ញាណ
- ការទទួលខុសត្រូវខាងសង្គមដទៃទៀត
- ការគ្រប់គ្រងពេលវេលា

## ២. ការគ្រប់គ្រង<u>ហិរញ្ញវត្ថុ</u>

- គ្រួសារ
- ការអប់រំ
- ព័ន្ធកិច្ច
- ការងារ (អ្នកដាំក្រុមជំនុំពាក់កណ្តាលវិជ្ជាជីវៈ)

## ៣. ការទទួលបាន<u>ទំនុកចិត្ត</u>

- បញ្ហាប្រឈមនៅក្នុងការអប់រំពាក់ព័ន្ធនឹងថ្នាក់រៀន និងកិច្ចការផ្ទះដែលនៅខាងក្រៅ
- ការភ័យខ្លាចការបរាជ័យ
- សមត្ថភាពបម្រើព័ន្ធកិច្ច

## ៤. ការបង្កើតប្រព័ន្ធគាំទ្រ

- មិត្តភក្តិ និងសាច់ញាតិដែលនឹងផ្តល់ការគាំទ្រខាងអារម្មណ៍សម្រាប់គ្រួសារ
- ដៃគូអធិស្ឋាន និងក្រុមអធិស្ឋានទូលអង្វរ
- ឧបជ្ឈាយ៍

ចូរបែកសិក្ខាកាមទៅជាក្រុម ហើយសុំឲ្យក្រុមនីមួយៗផ្តល់យោបល់សម្រាប់ជួយសទ្ធិវិហារិកដោះស្រាយបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមទាំងឡាយដែលបានកត់ត្រា ។

## គុណសម្បត្តិ និងរង្វាន់មកពីដំណើរការឧបជ្ឈាយ៍

## ផលប្រយោជន៍របស់ការធ្វើជាឧបជ្ឈាយ៍:

សម្រាប់សទ្ធិវិហារិក:

- គាត់នឹងមានអ្នកជួយទុក្ខធុរៈ ។
- គាត់នឹងមានលទ្ធភាពប្រសើរជាងមុននៅក្នុងការទទួលបានជោគជ័យ ។
- គាត់នឹងមានអ្នកដែលគាត់ត្រូវមានគណនេយ្យភាពចំពោះ ។
- គាត់នឹងមើលឃើញការរីកចម្រើនលឿនជាងមុន និងធំជាងមុននៅក្នុងក្រុមជំនុំថ្មី ។
- គាត់នឹងពេញវ័យតាមរយៈការមានទំនាក់ទំនងជាមួយអ្នកដែលមានបទពិសោធន៍ច្រើនជាង ។
- គាត់មានលទ្ធភាពងាយទទួលបានជំនួននានដ៏ឈ្លាសវៃ ។
- គាត់នឹងបង្កើតទំនាក់ទំនងខាងវិញ្ញាណដែលមានសុខភាពល្អដើម្បីធ្វើគំរូនៅក្នុងព័ន្ធកិច្ចនាពេលអនាគត ។
- គាត់នឹងមានគំរូដ៏ត្រឹមត្រូវដើម្បីធ្វើជាឧបជ្ឈាយ៍ដល់អ្នកដទៃទៀត ។

ឧបជ្ឈាយ៍នឹង:

- សម្រាប់ឧបជ្ឈាយ៍:
- គាត់នឹងទទួលបានអំណរនៅក្នុងការចែកចាយបទពិសោធន៍ និងនិមិត្តរបស់គាត់ ។
- គាត់នឹងជួយនៅក្នុងការពង្រីកព្រះរាជ្យរបស់ព្រះ ។
- គាត់នឹងបានកើនឡើងតាមរយៈទំនាក់ទំនងឧបជ្ឈាយ៍ ។
- គាត់នឹងមើលឃើញឥទ្ធិពល និងប្រសិទ្ធភាពព័ន្ធកិច្ចរបស់គាត់ចម្រើនឡើងជាពហុគុណ ។
- គាត់នឹងចៀសផុតពីភាពនៅទ្រឹង និងការខ្ជះខ្ជាយពេលវេលារបស់គាត់ ។
- គាត់នឹងបន្សល់ទុកកេរ្តិ៍ដំណែលដ៏នៅយូរអង្វែង ។
- គាត់នឹងរៀន ។ អ្នកដែលបង្រៀន រៀនកាន់តែប្រសើរ ។
- គាត់នឹងរួមចំណែកនៅក្នុងការសង់សម្រាប់ព្រះរាជ្យរបស់ព្រះ ។

ប្រព័ន្ធគាំទ្រ

## សេចក្ដីបញ្ចប់

តើចំណេះដឹងរបស់លោកអ្នកអំពីសទ្ធិវិហារិក ជួយលោកអ្នកឲ្យស្គាល់របៀបជួយអ្នកដាំក្រុមជំនុំ ឲ្យរៀនបានកាន់តែប្រសើរយ៉ាងដូចម្ដេច?

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

តើម៉ោងនេះបានផ្លាស់ប្ដូរវិធីសាស្ត្រធ្វើជាឧបជ្ឈាយ៍របស់លោកអ្នកយ៉ាងដូចម្ដេច? តើលោកអ្នកនឹងធ្វើជាឧបជ្ឈាយ៍ដល់អ្នកក្រុមជំនុំយ៉ាងដូចម្ដេច ដោយព្រោះតែអ្វីដែលលោកអ្នកបានរៀនអំពីលក្ខណៈរបស់សទ្ធិវិហារិក?

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

# ម៉ោងទី ៣
# ទំនាក់ទំនងឧបជ្ឈាយ៍

«សរុបមក ដំណើរជារបស់អ្នកទេសចរណ៍ មិនមែនមគ្គុទេសន៍ទេ» ជាឡូស

កម្មវត្ថុ

- ដើម្បីកត់ត្រាលក្ខណៈមួយចំនួនរបស់ឧបជ្ឈាយ៍ដ៏ល្អ និងឧបជ្ឈាយ៍ដែលនាំឲ្យពុល ។
- ដើម្បីកត់ត្រាលក្ខណៈមួយចំនួនរបស់សទ្ធិវិហារិកដ៏ល្អ និងសទ្ធិវិហារិកដ៏អាក្រក់ ។
- ដើម្បីស្គាល់គ្រោះថ្នាក់មួយចំនួននៅក្នុងការធ្វើជាឧបជ្ឈាយ៍ ។
- ដើម្បីស្គាល់សារៈសំខាន់នៃការទុកចិត្ត និងការរក្សារឿងសម្ងាត់ ។

ចូរសុំអ្នកនៅក្នុងក្រុមឲ្យគិតត្រឡប់ទៅក្រោយវិញនៅក្នុងជីវិតរបស់ពួកគេទៅរកពេលមួយដែលមានអ្នកធ្វើជាឧបជ្ឈាយ៍ដល់ពួកគេ ។ តើបុគ្គលនេះជាឧបជ្ឈាយ៍ដ៏ល្អដែរឬទេ? ប្រសិនបើល្អ តើអ្វីបានធ្វើឲ្យបុគ្គលនេះក្លាយទៅជាឧបជ្ឈាយ៍ដ៏ល្អ? តើពួកគេគិតថា លក្ខណៈសម្បត្តិរបស់ឧបជ្ឈាយ៍ដ៏ល្អមានអ្វីខ្លះ?

## លក្ខណៈសម្បត្តិរបស់ឧបជ្ឈាយ៍ល្អ

ចូរឲ្យសិក្ខាកាមឆ្លុះបញ្ចាំងលក្ខណៈសម្បត្តិខាងក្រោម ហើយសម្រេចថាតើពួកគេមានអារម្មណ៍ថា ពួកគេមានលក្ខណៈសម្បត្តិចាំបាច់ទាំងនេះដែរឬអត់ តាមការវាយតម្លៃផ្ទាល់ខ្លួនរបស់ពួកគេ ។

១. ឧបជ្ឈាយ៍ល្អ គឺជា**<u>អ្នកស្តាប់ល្អ</u>** ។
សុភាសិតមួយរបស់អេស្ប៉ាញនិយាយយ៉ាងនេះថាៈ «យើងត្រូវបានបង្កើតមកឲ្យមានត្រចៀកពីរ និងមាត់មួយប៉ុណ្ណោះ ។ ដូច្នេះហើយ យើងត្រូវស្តាប់ឲ្យបានច្រើនជាងយើងនិយាយពីរដង» ។ ឧបជ្ឈាយ៍ដ៏ល្អស្តាប់ច្រើនជាងនិយាយ ។ នៅពេលដែលពួកគេនិយាយ ពួកគេសួរសំណួរដើម្បីស្តាប់ឮចម្លើយពីសទ្ធិវិហារិករបស់ពួកគេ ។

២. ឧបជ្ឈាយ៍ល្អ ដោះស្រាយកាលៈទេសៈ«**<u>ត្រូវចំពេល</u>**»នៅក្នុងជីវិត ។
នៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ យើងកំពុងដោះស្រាយជាមួយការល្អ និងការអាក្រក់នៅក្នុងជីវិត ជាមួយកាលៈទេសៈដែលសទ្ធិវិហារិកកំពុងជួបប្រទះនៅពេលបច្ចុប្បន្ននេះ ។ ដូចជានៅក្នុងបរិបទផ្នែកអប់រំ «ការរៀនសូត្រត្រូវចំពេល»—គឺការចែកចាយអំពីអ្វីមួយនៅពេល«ដែលអាចបង្រៀនបាន» —មានប្រសិទ្ធភាពជាងការបង្រៀនដែលហាក់បីដូចជាមិនពាក់ព័ន្ធនឹងតថៈភាពជាក់ស្តែងនៅពេលបច្ចុប្បន្នរបស់សទ្ធិវិហារិក ។

៣. ឧបជ្ឈាយ៍ល្អ ប្រៀបបីដូចជា**<u>ឆ្នប</u>** ។
ឧបជ្ឈាយ៍ជួយ«មនុស្សដទៃទៀត»នៅក្នុងការសម្រាលចេញគំនិតថ្មី ជំនាញថ្មី ការប្រៀបធៀបថ្មី និងវិធីថ្មីនៅក្នុងការធ្វើជា និងការធ្វើ ។ ពួកគេជួយអ្នករៀនសូត្រនៅក្នុងការសម្រាលចេញគំនិត និមិត្ត និងគោលដៅរបស់ខ្លួនគេផ្ទាល់ -រ៉ូហ្គែល

អ្នកស្តាប់ល្អ – ត្រូវចំពេល – ឆ្មប

៤. ឧបជ្ឈាយ៍ល្អជួយសិទ្ធិវិហារិកមើលឃើញ**ជម្រើសផ្សេងៗ** ។
នៅពេលដែលប្រឈមមុខជាមួយនឹងស្ថានភាពដ៏លំបាក មនុស្សអាច«ជាប់គាំង» ហើយមើលឃើញដំណោះស្រាយតែមួយ លទ្ធផលតែមួយ និងដំណើរសកម្មភាពតែមួយប៉ុណ្ណោះ ។ នៅពេលដែលសិទ្ធិវិហារិកពិភាក្សាបញ្ហាជាមួយឧបជ្ឈាយ៍របស់ពួកគេ ឧបជ្ឈាយ៍អាចជួយពួកគេមើលឃើញជម្រើសដទៃទៀត ។

៥. ឧបជ្ឈាយ៍ល្អ គឺជា**អ្នកលើកទឹកចិត្ត** ។
យើងត្រូវការអ្នកជឿលើយើង ។ យើងត្រូវការបាណាបាសដែលអាចលើកទឹកចិត្តយើង នៅពេលដែលយើងបាក់ទឹកចិត្ត និងមានអារម្មណ៍ដូចជាបរាជ័យនៅក្នុងព័ន្ធកិច្ច ។

៦. ឧបជ្ឈាយ៍ល្អ គឺជា**អ្នកគិតបែបត្រិះរិះពិចារណា** ។
ក្នុងនាមជាឧបជ្ឈាយ៍ យើងត្រូវជួយសិទ្ធិវិហារិកឲ្យគិតបែបត្រិះរិះពិចារណា និងបែបវិភាគ—បញ្ហាជាច្រើនមិនស្រួលសម្រេចថាខុស ឬត្រូវទេ ។ នៅពេលដែលឧបជ្ឈាយ៍ឈោងចាប់ដំណោះស្រាយ ពួកគេត្រូវវិភាគស្ថានភាពបច្ចុប្បន្ន ដើម្បីជួយសិទ្ធិវិហារិករបស់ពួកគេឆ្លងផុតស្ថានភាពនោះ ។

៧. ឧបជ្ឈាយ៍ល្អ គឺជា**មគ្គុទេសក៍** ។

ចូរឲ្យពេលសិក្ខាកាម ៥ នាទី ដើម្បីឆ្លុះបញ្ចាំងរៀងខ្លួនអំពីលក្ខណៈសម្បត្តិទាំងនេះ ។ បន្ទាប់មក ចូរសុំឲ្យពួកគេបែកជាក្រុមដែលមានគ្នា ២ ឬ ៣ នាក់ ចែកចាយប្រាប់គ្នាទៅវិញទៅមករយៈពេល ១០-១៥ នាទី អំពីលក្ខណៈណាខ្លះដែលពួកគេមាន និងលក្ខណៈដែលពួកគេមានអារម្មណ៍ថា ពួកគេត្រូវអភិវឌ្ឍដើម្បីធ្វើជាឧបជ្ឈាយ៍ដ៏ល្អ ។

តើមួយណាខ្លះក្នុងចំណោមលក្ខណៈទាំងនេះដែលពណ៌នាអំពីលោកអ្នក? តើលោកអ្នកចង់អភិវឌ្ឍលក្ខណៈណាខ្លះ?

ដើម្បីជួយសិទ្ធិវិហារិកវិភាគស្ថានភាព នេះគឺជាយោបល់មួយចំនួន:
- ចូររកឲ្យឃើញព័ត៌មានសំខាន់ រួមបញ្ចូលទាំងប្រវត្តិ ។
- ចូរឆ្លុះបញ្ចាំងអំពីស្ថានភាពដោយឥតលម្អៀង ។
- ចូររកឲ្យឃើញគំនិតប៉ាន់ស្មានរបស់សិទ្ធិវិហារិក ។
- ចូរពិចារណាទស្សនៈដទៃទៀត ។
- ចូរពិចារណាឥទ្ធិពលរបស់បរិបទខាងវប្បធម៌មកលើមនុស្សដែលពួកគេកំពុងបម្រើ ។

## លក្ខណៈសម្បត្តិរបស់ឧបជ្ឈាយ៍ដែលនាំឲ្យពុល
ទាំងនេះគឺជាលក្ខណៈសម្បត្តិនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ដែលអាចរារាំងដល់ការរៀនសូត្រ ។ សូមមើលបញ្ជីខាងក្រោម ដោយមិនបាច់ចំណាយពេលច្រើនពេកទេ ។

**ជម្រើសផ្សេងៗ – អ្នកលើកទឹកចិត្ត – អ្នកគិតបែបត្រិះរិះពិចារណា – មគ្គុទេសក៍**

១. ឲ្យ**<u>ដំបូន្មាន</u>**សេរីពេក
២. **<u>រិះគន់</u>**
៣. **<u>ជួយសង្គ្រោះ</u>**សិទ្ធិវិហារិកញឹកញាប់ពេក
៤. **<u>គាំទ្រ</u>**សិទ្ធិវិហារិកដោយមិនត្រឹមត្រូវ
៥. សង់**<u>រនាំង</u>**
៦. **<u>មិនឲ្យតម្លៃ</u>**សិទ្ធិវិហារិក និងគំនិតរបស់គេ

តើលោកអ្នកកំពុងមានគ្រោះថ្នាក់បំផុតនៅក្នុងការបង្ហាញចេញអាកប្បកិរិយាមួយណាខ្លះក្នុងចំណោមអាកប្បកិរិយាទាំងនេះ? តើលោកអ្នកអាច«បោះបោល»អាកប្បកិរិយាទាំងនេះបានយ៉ាងដូចម្ដេច?

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

លក្ខណៈសម្បត្តិរបស់សិទ្ធិវិហារិកល្អ(សិស្សល្អ)

១. សិទ្ធិវិហារិកល្អមាន **<u>ការទទួលខុសត្រូវ</u>**សម្រាប់ការរៀនសូត្ររបស់ខ្លួន ។
សិទ្ធិវិហារិកដឹងល្អកំណត់សេចក្ដីត្រូវការ និងបំណងប្រាថ្នារបស់ខ្លួននៅក្នុងផ្នែកមួយចំនួន ។ សិទ្ធិវិហារិករួមជាមួយឧបជ្ឈាយ៍របស់ខ្លួនគួរតែសម្រេចពេលដែលពួកគេនឹងជួបគ្នា ពួកគេនឹងជួបគ្នាញឹកញាប់ប៉ុនណា និងការជួបគ្នាមានរយៈពេលយូរប៉ុនណា ។ ពួកគេថែមទាំងអាចកំណត់ប្រធានចម្បងដែលត្រូវពិភាក្សានៅក្នុងពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ដោយផ្អែកលើព្រឹត្តិការណ៍បច្ចុប្បន្ននៅក្នុងជីវិតរបស់ពួកគេ ។ ការធ្វើដំណើរនេះជារបស់អ្នកទេសចរណ៍ ។ ឧបជ្ឈាយ៍គ្រាន់តែជាមគ្គុទេសន៍ប៉ុណ្ណោះ ។

២. សិទ្ធិវិហារិកល្អ គឺជា**<u>អ្នកស្ដាប់ដោយយកចិត្តទុកដាក់</u>** ។
សិទ្ធិវិហារិក ក៏ដូចជាឧបជ្ឈាយ៍ដែរ ត្រូវតែជា«អ្នកស្ដាប់ដោយយកចិត្តទុកដាក់» ។ សិទ្ធិវិហារិកត្រូវស្ដាប់អ្វីដែលឧបជ្ឈាយ៍របស់ពួកគេកំពុងនិយាយ បន្ទាប់មក កំណត់ថាត្រូវធ្វើដូចម្ដេចជាមួយដំបូន្មាននោះ ។

៣. សិទ្ធិវិហារិកល្អ គឺជាអ្នករៀនសូត្រ**<u>ដែលសង្វាត</u>** ។
- ស្វែងរកយោបល់ដ៏មានប្រយោជន៍ និងបង្ហាញចេញការអរគុណចំពោះយោបល់នោះ ។
- មិនខ្លាចនឹងសុំអ្វីក៏ដោយដែលខ្លួនត្រូវការដើម្បីរីកចម្រើន ។
- មិនខ្លាចនឹងសួរសំណួរ ។
- ចូលរួមយ៉ាងសកម្មនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ។
- ទាញយកប្រយោជន៍ចេញពីជំនាញ និងបទពិសោធន៍របស់ឧបជ្ឈាយ៍ ។

៤. សិទ្ធិវិហារិកល្អ គឺជាអ្នករៀនសូត្រ**ពេញមួយជីវិត** ។
នៅពេលដែលឧបជ្ឈាយ៍ជួយសិទ្ធិវិហារិករបស់ខ្លួនឲ្យដឹងកន្លែងដើម្បីទៅរកបានជំនួយ (ឯកសារបោះពុម្ព អ៊ិនធើណេត មនុស្សដទៃទៀត ។ល ។) ពួកគេជួយសិទ្ធិវិហារិកនោះឲ្យក្លាយទៅជាអ្នករៀនសូត្រពេញមួយជីវិត ។ សិទ្ធិវិហារិកមិនគួរពឹងផ្អែកលើឧបជ្ឈាយ៍ទេ ទោះជារយៈពេលខ្លី ឬរយៈពេលវែង ។

៥. សិទ្ធិវិហារិកល្អ មាន**តម្លាភាព** ។
សិទ្ធិវិហារិកល្អ បើកចំហ និងស្មោះត្រង់ជាមួយឧបជ្ឈាយ៍របស់ខ្លួន ។ ពួកគេមិនលាក់បាំងព័ត៌មានសំខាន់ទេ ។ សិទ្ធិវិហារិកដ៏ល្អនឹងស្មោះត្រង់អំពីឱនភាព និងសេចក្តីត្រូវការ ព្រមទាំងប្រាប់បញ្ហាយ៉ាងច្បាស់លាស់ នោះទើបឧបជ្ឈាយ៍អាចធ្វើការវិភាគដ៏ល្អបាន ។

### លក្ខណៈសម្បត្តិរបស់សិទ្ធិវិហារិកអាក្រក់

ចូរសួរសិក្ខាកាមថា សិទ្ធិវិហារិកអាក្រក់ មានលក្ខណៈសម្បត្តិដូចម្តេចខ្លះ ។ ចូរសួរថាតើពួកគេឲ្យយោបល់ឧបជ្ឈាយ៍អាច ឬគួរតែធ្វើអ្វី នៅពេលដែលសិទ្ធិវិហារិកបង្ហាញចេញលក្ខណៈទាំងនេះ ។

១. ពួកគេ**ពឹងផ្អែក**ហួសហេតុតែលើឧបជ្ឈាយ៍របស់ខ្លួនសម្រាប់ចម្លើយ ។
២. ពួកគេមិនមាន**គំនិតផ្តួចផ្តើម**ដើម្បីរកឲ្យឃើញផ្នែកថ្មីៗដែលត្រូវពិភាក្សាគ្នា ។
៣. ពួកគេ**មិនឲ្យតម្លៃ**អ្វីដែលឧបជ្ឈាយ៍របស់ខ្លួននិយាយ ឬឲ្យយោបល់ ។
៤. ពួកគេមិនបាន**វិភាគ**តបៈភាពជាក់ស្តែងនៃស្ថានភាពបច្ចុប្បន្ន និងមើលឃើញកន្លែងដែលពួកគេអាចទៅដល់ទេ ។

### ការព្រមានអំពីការធ្វើជាឧបជ្ឈាយ៍

១. **ឲ្យតម្លៃ:** កុំមើលស្រាលអ្នកដទៃ (កាឡាទី ៥:១៣ អេភេសូរ ៥:២១ រ៉ូម ១២:១០) ។
២. **ធ្វើគំរូ:** កុំធ្វើអន្តរាគមន៍ ។
៣. **លើកទឹកចិត្ត:** កុំបំបាក់ទឹកចិត្ត (១ ធីម៉ូថេ ៥:១១ រ៉ូម ៤:១៣, ១៥:៧ អេភេសូរ ៤:៣២) ។
៤. **បន្ទាបខ្លួន:** កុំឆ្មើងឆ្មៃ (ភីលីព ២:៣) ។
៥. **ស្តាប់:** យឺតនឹងនិយាយ ។
៦. **បញ្ជាក់ច្បាស់:** កុំស្មាន ។
៧. ឲ្យពេលវេលាឲ្យបាន**គ្រប់គ្រាន់** ។ កុំដើរផ្លូវកាត់ ។
៨. **រំឭកឡើងវិញ:** កុំខាននឹងសង់ពួកគេឡើង ។
៩. **ឲ្យធនធាន:** កុំរកមើលអ្វីៗគ្រប់យ៉ាងឲ្យពួកគេ ។
១០. **ផ្តល់ទស្សនៈ:** កុំផ្តល់ចម្លើយដែលងាយស្រួល ។

**ពេញមួយជីវិត – តម្លាភាព – ពឹងផ្អែក – គំនិតផ្តួចផ្តើម – មិនឲ្យតម្លៃ – វិភាគ – ឲ្យតម្លៃ – ធ្វើគំរូ – លើកទឹកចិត្ត – បន្ទាបខ្លួន – ស្តាប់ – បញ្ជាក់ច្បាស់ – គ្រប់គ្រាន់ – រំឭកឡើងវិញ – ធនធាន - ទស្សនៈ**

ចូរអានកាឡាទី ៥:១៣ អេភេសូរ ៥:២១ រ៉ូម ១២:១០, ១ ធីម៉ូថេ ៥:១១ រ៉ូម ៤:១៣, ១៥:៧ អេភេសូរ ៤:៣២ និងភីលីព ២:៣ ។ ចូរពិភាក្សាអំពីរបៀបដែលខគម្ពីរទាំងនេះពាក់ព័ន្ធជាមួយនឹងចំណុចទាំងនេះ ។

## សារៈសំខាន់នៃការទុកចិត្ត និងការរក្សារឿងសម្ងាត់




- ការធ្វើជាឧបជ្ឈាយ៍ត្រូវបានសង់នៅលើមូលដ្ឋានគ្រឹះនៃការទុកចិត្ត និងការរក្សារឿងសម្ងាត់ ។
- បើគ្មានការទុកចិត្ត នោះមិនអាចមានការរក្សារឿងសម្ងាត់បានឡើយ ។ បើគ្មានការរក្សារឿងសម្ងាត់ នោះការទុកចិត្តទាំងអស់ត្រូវបាត់បង់ ។
- ទំនាក់ទំនងឧបជ្ឈាយ៍នឹងមិនមានប្រសិទ្ធភាព ឬជាប់គង់វង្សឡើយ ប្រសិនបើអ្វីដែលបានប្រាប់ជាសម្ងាត់ មិនត្រូវបានរក្សាជាសម្ងាត់ ឬបើសទ្ធិវិហារិកមានអារម្មណ៍ថា រឿងសម្ងាត់ មិនបានរក្សាជាសម្ងាត់ ។
- សូម្បីតែនៅពេលដែលឧបជ្ឈាយ៍រក្សាជាសម្ងាត់ក៏ដោយ ប្រសិនបើសទ្ធិវិហារិករបស់ខ្លួនជឿថាមិនមាន នោះសទ្ធិវិហារិកនឹងឈប់ចែកចាយដោយបើកចំហយ៉ាងលឿន ។
- បើពុំមានតម្លាភាពទេ ទំនាក់ទំនងឧបជ្ឈាយ៍នឹងមិនទៅដល់បញ្ហានៅក្នុងដួងចិត្តឡើយ ។

ចូរសុំសិក្ខាកាមទាំងអស់ឲ្យចែកចាយឧទាហរណ៍អំពីស្ថានភាព ដែលការទុកចិត្តត្រូវបានបាត់បង់ ដោយព្រោះតែខ្វះការរក្សាជាសម្ងាត់ ដោយមិនបាច់ប្រាប់ឈ្មោះ ឬពណ៌នាហេតុការណ៍លម្អិតទេ ។ តើការនោះដោយសារតែការនិយាយដើម? តើឧបជ្ឈាយ៍បានមួលបង្កាច់ស្ថានភាពដែលបានចែកចាយឬ? តើព័ត៌មានដែលត្រូវបានចែកចាយជាសម្ងាត់ នៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ត្រូវបានប្រើនៅក្នុងការអួតពីអំណាច ឬព្យួរនៅពីលើក្បាលរបស់សទ្ធិវិហារិកឬ? តើកង្វះខាតនៃការរក្សាជាសម្ងាត់ មានឥទ្ធិពលដូចម្ដេចមកលើសទ្ធិវិហារិក—និងឧបជ្ឈាយ៍—នៅក្នុងករណីទាំងនេះ?

**សេចក្តីបញ្ចប់**

ចូរសុំអ្នកស្ម័គ្រចិត្តឲ្យស្គាល់ចំណុចគន្លឹះទាំងឡាយដែលបានរៀន ។

តើអ្វីមានឥទ្ធិពលលើលោកអ្នកខ្លាំងបំផុតចេញពីមេរៀននេះ?

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

ដោយផ្អែកលើបញ្ជីអំពីអ្វីដែលធ្វើឲ្យក្លាយជាឧបជ្ឈាយ៍ល្អ និងឧបជ្ឈាយ៍អាក្រក់ តើលោកអ្នកត្រូវអភិវឌ្ឍលើចរិតលក្ខណៈណាខ្លះ?

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

ចូរអធិស្ឋានសម្រាប់ឧបជ្ឈាយ៍ សទ្ធិវិហារិក និងសម្រាប់ការអភិវឌ្ឍន៍ការរក្សារឿងសម្ងាត់ និងការទុកចិត្តនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍របស់សិក្ខាកាម ។

# ម៉ោង ៤
# ការចាប់ផ្តើមទំនាក់ទំនងឧបជ្ឈាយ៍

*«ព្រះយេស៊ូ(វ)ផ្តល់ជាគំរូ យ៉ាងល្អបំផុតអំពីឧបជ្ឈាយ៍»*
*–តេបា & អូស្ទ័រហាយស៍*

## កម្មវត្ថុ

- ដើម្បីពណ៌នាអំពីសេចក្តីតាំងសញ្ញាអំពីការធ្វើជាឧបជ្ឈាយ៍ ។
- ដើម្បីផ្តល់ឧទាហរណ៍អំពីរបៀបវារៈសម្រាប់ពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ។
- ដើម្បីចងក្រងសំណួរដែលឧបជ្ឈាយ៍អាចប្រើបាន ។
- ដើម្បីពន្យល់អំពីសារៈសំខាន់របស់ចំណុចអនុវត្ត ។
- ដើម្បីរៀនរបៀបប្រើកំណត់ត្រាឧបជ្ឈាយ៍ ។

## សេចក្តីសញ្ញាអំពីការធ្វើជាឧបជ្ឈាយ៍

ទំនាក់ទំនងឧបជ្ឈាយ៍មានបីជ្រុង: ព្រះ ឧបជ្ឈាយ៍ និងសទ្ធិវិហារិក ។ នោះគឺជាសេចក្តីតាំងសញ្ញាខាងវិញ្ញាណ ។




## ធាតុផ្សំនៃសេចក្តីសញ្ញាអំពីការធ្វើជាឧបជ្ឈាយ៍

សេចក្តីសញ្ញាអំពីការធ្វើជាឧបជ្ឈាយ៍ កំណត់ច្បាប់គ្រឹះសម្រាប់ទំនាក់ទំនងឧបជ្ឈាយ៍ ។ សេចក្តីសញ្ញា ឆ្លើយតបនឹងសំណួរខាងក្រោម:

១. តើយើងជួបគ្នានៅពេលណា និងនៅកន្លែងណា?
២. តើយើងនឹងជួបគ្នារយៈពេលប៉ុន្មាន?
៣. តើយើងនឹងជួបគ្នាញឹកញាប់ប៉ុនណា?
៤. តើពេលជួបគ្នារបស់យើងនឹងនិយាយអំពីប្រធានបទអ្វីខ្លះ?
៥. តើប្រធានបទអ្វីខ្លះដែលមិនត្រូវនិយាយ?

**ព្រះ – ឧបជ្ឈាយ៍ - សទ្ធិវិហារិក**

៦. តើមានច្បាប់អ្វីខ្លះសម្រាប់ការរក្សារឿងសម្ងាត់?
៧. តើយើងដឹងពេលដែលយើងបានសម្រេចអ្វីដែលយើងបានដាក់ចេញដើម្បីធ្វើយ៉ាងដូចម្ដេច?

*សម្រាប់សិទ្ធិវិហារិកនៅក្នុងការហ្វឹកហ្វឺនរបស់អិមអិនអិម ចំណុចនេះនឹងត្រូវបានពិភាក្សានៅក្នុងម៉ូឌុលចុងក្រោយនៃកម្មវិធីដាំក្រុមជំនុំ ។

វាប្រហែលជាមិនអាចចូលជ្រៅនៅក្នុងការពិភាក្សាអំពីការធ្វើជាឧបជ្ឈាយ៍ដូចដែលឧបជ្ឈាយ៍គិតថាចាំបាច់ជានិច្ចនោះទេ ។ ប្រហែលជាមិនមានការមួយចំនួនដែលសិទ្ធិវិហារិកមិនចង់ចែកចាយទេ ជាពិសេស ប្រសិនបើឧបជ្ឈាយ៍ក៏ជាគ្រូគង្វាលរបស់សិទ្ធិវិហារិកផងដែរនោះ ។

នៅពេលដែលឧបជ្ឈាយ៍ និងសិទ្ធិវិហារិកបានសម្រេចគោលដៅនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍របស់ពួកគេ ពួកគេអាចសម្រេចថាតើពួកគេចង់បន្តជួបគ្នាដែរឬអត់ ។ ប្រសិនបើដូច្នេះ ពួកគេគួរតែបង្កើតសេចក្ដីតាំងសញ្ញាអំពីការធ្វើជាឧបជ្ឈាយ៍ថ្មីទៀត ។

### សំណួរដែលត្រូវសួរមុនចុះហត្ថលេខាលើសេចក្ដីសញ្ញាអំពីការធ្វើជាឧបជ្ឈាយ៍

ចូរអានសំណួរទាំងប្រាំមួយនេះសម្រាប់ឲ្យឧបជ្ឈាយ៍សួរសិទ្ធិវិហារិក និងសួរសិក្ខាកាមថាតើមានសំណួរផ្សេងទៀតដែលពួកគេចង់បន្ថែមដែរឬទេ ។

ខាងក្រោមនេះជាសំណួរមួយចំនួនដែលលោកអ្នកអាចសួរសិទ្ធិវិហារិក ជាសំណួរដែលផ្អែកលើគរុកោសល្យមនុស្សពេញវ័យ ។

| |
|---|
| ១. ហេតុអ្វីបានជាលោកអ្នកចូលរួមនៅក្នុងដំណើរការឧបជ្ឈាយ៍? |
| ២. តើលោកអ្នកចង់រៀនជំនាញ ឬព័ត៌មានអ្វី? |
| ៣. តើលោកអ្នកចង់អភិវឌ្ឍលក្ខណៈអ្វីខ្លះនៅក្នុងរយៈពេលប្រាំខែបន្ទាប់? |
| ៤. តើលោកអ្នកចង់ផ្លាស់ប្ដូរលក្ខណៈអ្វីខ្លះនៅក្នុងខែក្រោយៗ? |
| ៥. តើបទពិសោធន៍មួយចំនួនដែលលោកអ្នកមាន ជាអ្វីខ្លះ ហើយតើព្រះអាចប្រើបទពិសោធន៍ទាំងនោះនៅក្នុងព័ន្ធកិច្ចរបស់លោកអ្នកបានយ៉ាងដូចម្ដេច? |
| ៦. តើនៅពេលបច្ចុប្បន្ននេះលោកអ្នកកំពុងជួបប្រទះការលំបាក ឬបញ្ហាប្រឈមអ្វីខ្លះនៅក្នុងព័ន្ធកិច្ចរបស់លោកអ្នក នៅក្នុងទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះ ឬជាមួយគ្រួសាររបស់លោកអ្នក? |

## របៀបវារៈសម្រាប់ពេលជួបគ្នាជាមួយឧបជ្ឈាយ៍

របៀបវារៈអាចផ្ដល់លំហូរដល់ការបង្កើតពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ។ ទោះបីជាយ៉ាងណាក៏ដោយឧបជ្ឈាយ៍មិនគួរក្លាយជាទាសកររបស់របៀបវារៈទេ ជាពិសេសបើសិនសទ្ធិវិហារិកមានសេចក្ដីត្រូវការបន្ទាន់ ឬដែលនឹកស្មានមិនដល់ ។




## សំណួរបីប្រភេទសម្រាប់ការធ្វើជាឧបជ្ឈាយ៍

ឧបជ្ឈាយ៍គួរតែយកចិត្តទុកដាក់អំពីផ្នែកទាំងបីនៅក្នុងជីវិតរបស់សទ្ធិវិហារិក ។




ជីវិតខាងវិញ្ញាណ – ជីវិតព័ន្ធកិច្ច – ជីវិតគ្រួសារ

១. ជីវិតខាងវិញ្ញាណរបស់សិទ្ធិវិហារិក
២. ទំនាក់ទំនងរបស់គាត់ជាមួយគ្រួសាររបស់គាត់
៣. ជីវិតព័ន្ធកិច្ចរបស់សិទ្ធិវិហារិក

**ជីវិតខាងវិញ្ញាណ**
ទំនាក់ទំនងជានិរន្តរ៍របស់សិទ្ធិវិហារិកជាមួយព្រះគឺជាគ្រឹះសម្រាប់ភាពជោគជ័យនៅក្នុងព័ន្ធកិច្ច ។ ការយកចិត្តទុកដាក់ចំពោះជីវិតខាងវិញ្ញាណត្រូវតែជាអាទិភាព—អ្នកដឹកនាំយ៉ាងច្រើនបានបរាជ័យនៅក្នុងផ្ទះ និងនៅក្នុងព័ន្ធកិច្ច ដោយព្រោះភាពកម្សោយខាងវិញ្ញាណ ។ សំពាធចេញពីការដាំក្រុមជំនុំទាមទារឲ្យមានការដើរយ៉ាងជិតស្និទ្ធជាមួយព្រះ ។ ដោយហេតុនេះ ឧបជ្ឈាយ៍ត្រូវតែដឹងជាពិសេសអំពីអ្វីដែលព្រះកំពុងមានបន្ទូល និងកំពុងធ្វើនៅក្នុងជីវិតសិទ្ធិវិហារិករបស់ពួកគេ ។

ចូរចែកចាយគំរូសំណួរដែលឧបជ្ឈាយ៍អាចសួរសិទ្ធិវិហារិករបស់ពួកគេបានអំពីជីវិតខាងវិញ្ញាណរបស់ពួកគេ ។ ចូរអនុញ្ញាតឲ្យពួកគេដឹងថា គំរូសំណួរទាំងនេះមាននៅក្នុងប្រអប់ឧបករណ៍ដែលមានលើនៅគេហទំព័ររបស់យើង www.multiplicationnetwork.org ។

| សំណួរសម្រាប់ឲ្យឧបជ្ឈាយ៍សួរសិទ្ធិវិហារិករបស់ខ្លួនអំពីជីវិតខាងវិញ្ញាណ: |
|---|
| • តើព្រះកំពុងមានបន្ទូលអ្វីមកលោកអ្នកនៅពេលនេះ? តើលោកអ្នកដឹងការនេះយ៉ាងដូចម្ដេច?<br>• តើព្រះបានបង្រៀនអ្វីដល់លោកអ្នកចាប់តាំងពីពេលជួបគ្នាកាលពីមុនរបស់យើងមក?<br>• តើលោកអ្នកវាយតម្លៃការដើររបស់លោកអ្នកជាមួយព្រះនៅពេលនេះយ៉ាងដូចម្ដេច: ជិតស្និទ្ធ មធ្យម ឬនៅឆ្ងាយ?<br>• តើលោកអ្នកមានពេលស្ងៀមស្ងាត់ប្រចាំថ្ងៃជាមួយព្រះដែរឬទេ? ចូរពណ៌នាអំពីពេលនោះប្រាប់ខ្ញុំ ។<br>• តើលោកអ្នកដាក់បញ្ចូលវិន័យអធិស្ឋាន និងតមអាហារមកក្នុងជីវិតរបស់លោកអ្នកដូចម្ដេច នៅពេលដែលលោកអ្នកដាំក្រុមជំនុំនេះ? |

**កំណត់សម្គាល់:** ប្រសិនបើសិទ្ធិវិហារិកលន់តួអំពើបាបនៅក្នុងជីវិតរបស់ពួកគេ ឧបជ្ឈាយ៍ត្រូវសម្រេចអំពីរបៀបដោះស្រាយបញ្ហានេះ ចេញពីចំណុចរក្សាជាសម្ងាត់ និងនៅក្នុងការប្រឹក្សាយោបល់ដល់សិទ្ធិវិហារិក ដោយមានគោលបំណងស្តារពួកគេឡើងវិញ ។ ឧបជ្ឈាយ៍គួរតែលើកទឹកចិត្តសិទ្ធិវិហារិកឲ្យលន់តួអំពើបាបចំពោះព្រះ លះបោលអំពើបាប និងតបសងវិញ ប្រសិនបើអាចធ្វើបាន ទុកជាសញ្ញាសម្គាល់អំពីការប្រែចិត្ត ។

សំណួរបន្ថែមអំពីជីវិតខាងវិញ្ញាណរបស់សទ្ធិវិហារិកៈ

______________________________________________________________________
______________________________________________________________________
______________________________________________________________________

**ជីវិតគ្រួសារ**

ចូរសួរសិក្ខាកាមថាតើពួកគេមានអារម្មណ៍ស្រួលចិត្តនឹងសួរសំណួរអំពីជីវិតគ្រួសាររបស់សទ្ធិវិហារិករបស់ពួកគេដែរឬអត់ ។ តើពួកគេមានអារម្មណ៍ថា អ្វីខ្លះជាសំណួរត្រឹមត្រូវ ហើយសំណួរអ្វីខ្លះដែលពួកគេមានអារម្មណ៍ថាមិនត្រូវសួរ? តើដែនកំណត់មួយចំនួនដែលឧបជ្ឈាយ៍មិនគួរដើររំលង មានអ្វីខ្លះ?

ចូរចែកសិក្ខាកាមទៅជាក្រុមដែលមានគ្នា ២-៣ នាក់ ហើយសុំឲ្យពួកគេបង្កើតកម្រងសំណួរអំពីជីវិតគ្រួសារ ។ ចូរឲ្យពេលពួកគេប្រហែល ១៥ នាទីសម្រាប់សកម្មភាពនេះ ។ បន្ទាប់មក ចូរសរសេរសំណួរដែលពួកគេមាននៅលើក្ដារខៀន ឬនៅលើផ្ទាំងក្រដាសធំមួយ ។

ឧបជ្ឈាយ៍ត្រូវសួរសំណួរអំពីទំនាក់ទំនងរបស់សទ្ធិវិហារិករបស់ពួកគេជាមួយប្ដី ឬប្រពន្ធ និងកូនរបស់ពួកគេ ។ ប៉ុន្តែឧបជ្ឈាយ៍ត្រូវតែបន្តដោយមានការប្រុងប្រយ័ត្ន និងការពិចារណាល្អិតល្អន់ នៅពេលដែលដោះស្រាយបញ្ហាយ៉ាងស្និទ្ធស្នាល ។ គោលបំណងរបស់ការធ្វើជាឧបជ្ឈាយ៍គឺជួយសទ្ធិវិហារិក មិនមែនធ្វើឲ្យពួកគេឈឺចាប់ទេ ។ សំណួររបស់ឧបជ្ឈាយ៍មិនត្រូវហាក់បីដូចជាចង់ដឹងរឿងផ្ទាល់ខ្លួនទេ ផ្ទុយទៅវិញ ពួកគេត្រូវតែឲ្យសទ្ធិវិហារិករបស់ពួកគេមានឱកាសចែកចាយអំណរនៅក្នុងជីវិតគ្រួសារ និងការលំបាកដែលកំពុងតែកើតមាន ប៉ុន្តែនៅក្នុងបរិយាកាសមួយដែលប្រកបដោយការទុកចិត្ត និងការរក្សារឿងសម្ងាត់ ព្រមទាំងនៅកម្រិតមួយដែលសទ្ធិវិហារិក មានអារម្មណ៍ស្រួលនៅក្នុងចិត្ត ។

| **សំណួរសម្រាប់ឲ្យឧបជ្ឈាយ៍សួរសទ្ធិវិហារិករបស់ខ្លួនអំពីជីវិតគ្រួសារៈ** |
|---|
| • តើលោកអ្នកឲ្យពេលប៉ុន្មានទៅគ្រួសាររបស់លោកអ្នក?<br>• តើលោកអ្នក និងប្ដី ឬប្រពន្ធរបស់លោកអ្នកមានពេលពិសេសរៀងរាល់សប្ដាហ៍ដែរឬទេ ជាពេលដែលលោកអ្នកចេញទៅតែពីរនាក់ដើម្បីជ្យាភ្ជាប់ឡើងវិញ? សូមចែកចាយប្រាប់ខ្ញុំពីអ្វីដែលលោកអ្នកធ្វើ ។<br>• តើកូនរបស់លោកអ្នកមានអារម្មណ៍ដូចម្ដេចអំពីពេលវេលាដែលលោកអ្នកមានសម្រាប់ពួកគេ?<br>• តើលោកអ្នកធ្វើកិច្ចការអ្វីខ្លះដើម្បីធ្វើឲ្យផ្ទះរបស់លោកអ្នកក្លាយទៅជាទីជម្រកដ៏មានសុវត្ថិភាពសម្រាប់គ្រួសាររបស់លោកអ្នក? តើលោកអ្នកការពារផ្ទះរបស់លោកអ្នកកុំឲ្យក្លាយជាផ្ទះសាធារណៈដែលមានការមកលេងជាដរាបពីអ្នកដែលលោកអ្នកកំពុងបម្រើ?<br>• តើលោកអ្នកកំពុងដោះស្រាយបញ្ហាគ្រួសារណាមួយដែលកំពុងរារាំងសមត្ថភាពរបស់លោកអ្នកមិនឲ្យមានប្រសិទ្ធភាពនៅក្នុងការដាំក្រុមជំនុំដែរឬទេ? |

សំណួរបន្ថែមអំពីជីវិតគ្រួសាររបស់សទ្ធិវិហារិក:

___

___

___

**ជីវិតព័ន្ធកិច្ច**

ទោះបីជាគោលដៅចុងក្រោយរបស់ការហ្វឹកហ្វឺននេះគឺជាការធានាថា ក្រុមជំនុំដែលមានសុខភាពល្អត្រូវបានដាំក៏ដោយ សំណួរមុនៗផ្តោតលើការថែរក្សាអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អ ។ ជីវិតខាងវិញ្ញាណ និងជីវិតគ្រួសាររបស់ពួកគេវេញយ៉ាងស្អិតរមួតចូលទៅក្នុងដំណើរការដាំក្រុមជំនុំ ។ នោះគឺជាមូលហេតុដែលម៉ោងនេះនិយាយអំពីផ្នែកទាំងពីរនោះមុន ។ សំណួរអំពីព័ន្ធកិច្ចដាំក្រុមជំនុំស្ថិតនៅកម្រិតទីបី ។ ទោះបីបីយ៉ាងណាក៏ដោយ គំនិត និងចិត្តឆេះឆួលរបស់អ្នកដាំក្រុមជំនុំនឹងនៅឆ្ងាយពីព័ន្ធកិច្ចរបស់ពួកគេ ប្រសិនបើពួកគេមិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះជីវិតខាងវិញ្ញាណ និងជីវិតគ្រួសាររបស់ពួកគេជាមុនទេនោះ ។

ចូរសុំសិក្ខាកាមឲ្យយោបល់អំពីផ្នែកមួយចំនួនរបស់ព័ន្ធកិច្ចដែលឧបជ្ឈាយ៍គួរតែលើកឡើងនៅក្នុងពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ។ ចូរសរសេរផ្នែកទាំងនោះនៅលើក្តារខៀន ឬផ្ទាំងក្រដាសធំមួយសន្លឹក ។

| សំណួរសម្រាប់ឲ្យឧបជ្ឈាយ៍សួរសទ្ធិវិហារិករបស់ខ្លួនអំពីជីវិតព័ន្ធកិច្ច: |
|---|
| • តើលោកអ្នកអាចប្រាប់ខ្ញុំអំពីការទៅលេងនាពេលថ្មីៗនេះ ដែលលោកអ្នកមានជាមួយអ្នកទាក់ទងថ្មីបានដែរឬទេ? តើការទៅលេងនោះប្រព្រឹត្តទៅដូចម្តេច និងហេតុអ្វី?<br>• តើមានការលំបាកដែលលោកអ្នកកំពុងមាននៅពេលឥឡូវនេះនៅក្នុងការដាំក្រុមជំនុំដែរឬទេ? សូមប្រាប់ខ្ញុំអំពីការលំបាកនេះ ។<br>• តើលោកអ្នកបានទៅលេងប៉ុន្មានដង ចាប់តាំងពីការជួបគ្នាលើកមុនរបស់យើងមក ហើយនៅក្នុងចំណោមការទៅលេងទាំងនេះ តើប៉ុន្មានដងជាការទៅលេងបែបថែបំប៉ន?<br>• តើលោកអ្នកកំពុងធ្វើអ្វីដើម្បីស្គាល់តំបន់នោះកាន់តែច្បាស់?<br>• តើលោកអ្នករៀនបានអ្វីថ្មីអំពីតំបន់គោលដៅរបស់លោកអ្នក?<br>• តើលោកអ្នកបានជោគជ័យយ៉ាងណានៅក្នុងការចាប់ផ្តើមក្រុមតូច?<br>• តើមានជម្លោះកើតឡើងដែរឬទេ? ប្រសិនបើមាន តើលោកអ្នកបានដោះស្រាយជម្លោះនោះដូចម្តេច?<br>• តើលោកអ្នកឃើញមនុស្សណានៅក្នុងក្រុមតូចរបស់លោកអ្នកដែលមានសក្តានុពលក្លាយជាអ្នកដឹកនាំដែរឬទេ? ចូរប្រាប់ខ្ញុំអំពីពួកគេ ។<br>• តើលោកអ្នកមានអារម្មណ៍ស្រួលចិត្តយ៉ាងណាជាមួយនឹងជំនឿនដែលក្រុមជំនុំកំពុងត្រូវបានដាំ? |

- តើមានផ្នែកណាមួយនៅក្នុងព័ន្ធកិច្ចដែលលោកអ្នកកំពុងតែឃើញខ្លួនឯងមិនស្រួលចិត្ត ឬត្រូវការជំនួយដែរឬទេ?
- តើលោកអ្នកបានសុំអ្នកណាឲ្យធ្វើជាអ្នកអធិស្ឋានគាំទ្រសម្រាប់លោកអ្នក នៅពេលដែលលោកអ្នកដាំក្រុមជំនុំនេះ? តើលោកអ្នកប្រាប់សំណូមពរអធិស្ឋាន និងការឆ្លើយតបដល់ពួកគេញឹកញាប់ប៉ុនណា?

សំណួរបន្ថែមអំពីជីវិតព័ន្ធកិច្ចរបស់សទ្ធិវិហារិក:

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

តើលោកអ្នកគិតថា ហេតុអ្វីបានជាការហ្វឹកហ្វឺននេះដាក់បញ្ហាអំពីជីវិតខាងវិញ្ញាណ និងគ្រួសារមុនជីវិតព័ន្ធកិច្ច?

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

**ចំណុចអនុវត្ត**

ពេលជួបគ្នាជាមួយឧបជ្ឈាយ៍មិនចប់សព្វគ្រប់ឡើយ បើឧបជ្ឈាយ៍មិនបានសួរសំណួរថា៖ «ដូច្នេះ តើជំហានបន្ទាប់ទៀតរបស់លោកអ្នកធ្វើអ្វីខ្លះ?» ។ សទ្ធិវិហារិកត្រូវតែទទួលបានការជំរុញឲ្យគិតពិចារណា និងកំណត់អ្វីដែលពួកគេនឹងធ្វើបន្ទាប់ទៀត មិនថាការនោះពាក់ព័ន្ធនឹងជីវិតខាងវិញ្ញាណ គ្រួសារ និងព័ន្ធកិច្ចរបស់ពួកគេឡើយ ។

ការដាំក្រុមជំនុំគឺជាវឌ្ឍនៈភាពនៃសកម្មភាព ។ សទ្ធិវិហារិកត្រូវតែពិចារណាអ្វីដែលពួកគេនឹងធ្វើបន្ទាប់ទៀត ដើម្បីដោះស្រាយបញ្ហានៅក្នុងជីវិតរបស់ពួកគេជាមួយព្រះ ពង្រឹងជីវិតគ្រួសាររបស់ពួកគេ និងធ្វើឲ្យក្រុមជំនុំដែលបានដាំរីកចម្រើន ។ នៅពេលដែលបញ្ហាលេចឡើងនៅក្នុងពេលជួបគ្នានេះ បញ្ហាទាំងនោះត្រូវតែដោះស្រាយតាមរបៀបណាមួយ—សទ្ធិវិហារិកត្រូវតែសម្រេចរបៀប និងពេល ។ ការរៀនសូត្រពិតប្រាកដកើតឡើង តែនៅពេលដែលសទ្ធិវិហារិកទទួលយកការទទួលខុសត្រូវសម្រាប់ការរីកចម្រើនរបស់ខ្លួនគេប៉ុណ្ណោះ ។ ការនេះត្រូវបានសម្រេចដោយសារជំហានអនុវត្តជាក់លាក់ ។ ជំហានទាំងនេះក៏ធ្វើជារង្វាស់ដ៏ច្បាស់លាស់ ដែលអាចឲ្យឧបជ្ឈាយ៍ និងសទ្ធិវិហារិកវាស់វែងជាមួយគ្នាអំពីការរីកចម្រើនដែលបានសម្រេច ។

**សំណួរសម្រាប់ឧបជ្ឈាយ៍:**

- តើលោកអ្នកនឹងបាត់ជំហានបន្ទាប់អ្វីខ្លះអំពីស្ថានភាពនេះ?
- តើលោកអ្នកចង់សម្រេចអ្វីនៅចន្លោះពេលឥឡូវនេះ និងពេលក្រោយទៀតដែលយើងជួបគ្នា?

- តើលោកអ្នកមើលឃើញអ្វីជាកិច្ចការបន្ទាប់ដែលលោកអ្នកត្រូវធ្វើអំពីស្ថានភាពនេះ?
- តើលោកអ្នកសង្ឃឹមថានឹងដោះស្រាយជម្លោះរវាង [ឈ្មោះ] និង [ឈ្មោះ] យ៉ាងដូចម្តេច?
- តើលោកអ្នកសង្ឃឹមថានឹងឆ្លងផុតឧបសគ្គនេះយ៉ាងដូចម្តេច?
- តើការបីយ៉ាងដែលលោកអ្នកមានអារម្មណ៍ថា លោកអ្នកត្រូវធ្វើដើម្បីធ្វើឲ្យក្រុមជំនុំដែលបានដារីកចម្រើននៅចន្លោះពេលឥឡូវនេះ និងពេលក្រោយទៀតដែលយើងជួបគ្នា?
- តើលោកអ្នកនឹងធ្វើអ្វីនៅសប្តាហ៍ក្រោយជាមួយ [ឈ្មោះ] ដើម្បីបើកការប្រាស្រ័យទាក់ទង?
- តើលោកអ្នកនឹងបែរទៅរកអ្នកណាដើម្បីទទួលបានជំនួយជាមួយបញ្ហាដែលលោកអ្នកទើបតែបានលើកឡើង?

សំណួរបន្ថែមពាក់ព័ន្ធនឹងចំណុចអនុវត្តៈ

____________________________________________________

# ការប្រើអ្នកជំនាញ

យូរៗម្ដងនៅក្នុងពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ឧបជ្ឈាយ៍ប្រហែលជាយល់ច្បាស់ថា ពួកគេយល់មិនដល់ទេ ។ សទ្ធិវិហារិករបស់ពួកគេប្រហែលជាត្រូវការជំនួនាន ឬឱវាទនៅផ្នែកដែលឧបជ្ឈាយ៍មានអារម្មណ៍ថាអសមត្ថភាព ។ នៅពេលដែលការនេះកើតឡើង ឧបជ្ឈាយ៍ត្រូវតែស្មោះត្រង់អំពីការនេះ ។ យើងមិនមែនជាអ្នកជំនាញគ្រប់ផ្នែកទាំងអស់នៅក្នុងព័ន្ធកិច្ចទេ ។ ឧបជ្ឈាយ៍ល្អទទួលស្គាល់ពេលដែលពួកគេត្រូវណែនាំអ្នកដទៃទៀតដែលអាចជួយសទ្ធិវិហារិករបស់ពួកគេនៅក្នុងផ្នែកនោះបាន—មនុស្សដែលជាអ្នកឯកទេសផ្នែកដែលត្រូវការ ។ នេះអាចជាប្រធានបទសម្រាប់ពេលជួបគ្នាលើកក្រោយជងដែរ ។ ឧបជ្ឈាយ៍អាចសួរសំណួរដូចជា: «តើការជួបគ្នារបស់លោកអ្នកជាមួយ [លោកគ្រូ ម៉ៅ អាន] ទាក់ទងនឹងបញ្ហាដែលលោកអ្នកបានលើកឡើងកាលពីពេលមុននោះយ៉ាងដូចម្ដេចដែរ? តើមានអ្វីដែលលោកអ្នកចង់ចែកចាយដែរឬទេ? » ។

១. ឧបជ្ឈាយ៍ត្រូវទទួលស្គាល់**<u>ការមានដែនកំណត់</u>**របស់ខ្លួន ។
ឧបជ្ឈាយ៍តិចតួចណាស់ដែលមានការហ្វឹកហ្វឺនគ្រប់គ្រាន់ឲ្យធ្វើលើសពីការប្រឹក្សាយោបល់បន្តិចបន្តួច ដូច្នេះហើយ ឧបជ្ឈាយ៍ត្រូវទទួលស្គាល់ការមានដែនកំណត់របស់ពួកគេ ជាពិសេសនៅក្នុងផ្នែកប្រឹក្សាយោបល់ ។ ឧបជ្ឈាយ៍ត្រូវតែស្គាល់ពេលដែលត្រូវណែនាំសទ្ធិវិហារិកទៅរកអ្នកមានវិជ្ជាជីវៈជាអ្នកប្រឹក្សាយោបល់ ។ ការខកខានមិនបានធ្វើដូច្នេះអាចធ្វើបាបសទ្ធិវិហារិក ព្រមទាំងធ្វើឲ្យឧបជ្ឈាយ៍អាចជួបនឹងការប្ដឹងផ្ដល់ជងដែរនៅក្នុងបរិបទមួយចំនួន ។

២. ឧបជ្ឈាយ៍ត្រូវដាក់បញ្ចូល**<u>អ្នកឯកទេស</u>**នៅក្នុងផ្នែកដែលពួកគេមានអារម្មណ៍មិនស្រួលចិត្ត ឬអសមត្ថភាព ។ នេះអនុញ្ញាតឲ្យសទ្ធិវិហារិកពង្រីកបណ្ដាញគាំទ្ររបស់ពួកគេ ។ អ្នកដែលឧបជ្ឈាយ៍ណែនាំអាចត្រឡប់ជាឧបជ្ឈាយ៍បន្ទាប់របស់សទ្ធិវិហារិក នៅពេលដែលទំនាក់ទំនងឧបជ្ឈាយ៍នាពេលបច្ចុប្បន្នបានបញ្ចប់ទៅ ។

## ទិន្នានុប្បវត្តិសម្រាប់ឧបជ្ឈាយ៍

នៅក្នុងទិន្នានុប្បវត្តិសម្រាប់ឧបជ្ឈាយ៍ ឧបជ្ឈាយ៍កត់ត្រាពេលដែលពួកគេបានជួបជាមួយសទ្ធិវិហារិករបស់ពួកគេ អ្វីដែលបានពិភាក្សាគ្នា និងជំហានអនុវត្តអ្វីខ្លះដែលបានឯកភាពគ្នា ។ ឧបជ្ឈាយ៍មិនគួរបំពេញទិន្នានុប្បវត្តិនេះនេះនៅក្នុងអំឡុងពេលជួបគ្នាជាមួយឧបជ្ឈាយ៍ឡើយ ប៉ុន្តែគួរតែភ្លាមៗក្រោយពីការជួបគ្នានោះ ប្រសិនបើអាចធ្វើបាន ។

មុនដល់ពេលជួបគ្នាជាមួយឧបជ្ឈាយ៍លើកក្រោយទៀត ឧបជ្ឈាយ៍គួរតែពិនិត្យមើលឡើងវិញនូវអ្វីដែលបានកើតឡើងនៅក្នុងពេលជួបគ្នាលើកមុន ។ ពួកគេក៏គួរតែយោងទៅរកសំណួរនៅទំព័រទីពីររបស់ទិន្នានុប្បវត្តិសម្រាប់ឧបជ្ឈាយ៍ដែលអាចធ្វើជាយោបល់សម្រាប់អ្វីដែលត្រូវសួរសទ្ធិវិហារិករបស់ពួកគេនៅក្នុងអំឡុងពេលជួបគ្នាដែលនឹងមកដល់ ។ ទិន្នានុប្បវត្តិសម្រាប់ឧបជ្ឈាយ៍ត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែកបន្ទាប់ ។

**ការមានដែនកំណត់ – អ្នកឯកទេស**

**ការបញ្ចប់**

ចូរសុំសិក្ខាកាមឲ្យសរសេរកិច្ចការមួយដែលពួកគេនឹងធ្វើ ជាលទ្ធផលនៃម៉ោងសិក្សានេះ ដែលពួកគេមិនបានគិតដល់ពីមុនមក ។ ចូរអញ្ជើញពួកគេមួយចំនួនតូចឲ្យចែកចាយគំនិតរបស់ពួកគេប្រាប់ក្រុមទាំងមូល ។

ចូរសរសេរកិច្ចការមួយដែលលោកអ្នកនឹងធ្វើ ជាលទ្ធផលនៃម៉ោងសិក្សានេះ ដែលពួកគេមិនបានគិតដល់ពីមុនមក ។

______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________
______________________________________________________________________________

# ទិន្នានុប្បវត្តិសម្រាប់ឧបជ្ឈាយ៍

ឈ្មោះសទ្ធិវិហារិក: ______________________________

កាលបរិច្ឆេទជួបគ្នា: ____ /____ /____ ម៉ោងជួបគ្នា: ____ : ____ ទីកន្លែង: ____________

**សំណួរផ្តួចផ្តើម:** តើលោកអ្នករៀនបានអ្វីនៅក្នុងម៉ូឌុលមុន? តើលោកអ្នកបានអនុវត្តចំណុចនោះយ៉ាងដូចម្តេច?

**សំណួរខាងវិញ្ញាណ** (គំរូសំណួរមាននៅផ្នែកខាងក្រោយនៃទំព័រនេះ)

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

**សំណួរអំពីគ្រួសារ** (គំរូសំណួរមាននៅផ្នែកខាងក្រោយនៃទំព័រនេះ)

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

**សំណួរអំពីព័ន្ធកិច្ច** (គំរូសំណួរមាននៅផ្នែកខាងក្រោយនៃទំព័រនេះ)

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

**ចូរសួរជានិច្ចថា:** តើលោកអ្នកបាននាំយករបាយការណ៍គខគរបស់លោកអ្នកមកឲ្យអ្នកដឹកនាំព័ន្ធកិច្ចរបស់លោកអ្នកដែរឬទេ?

**ជំហានអនុវត្ត:** (ចូរបំពេញផ្នែកនេះជាមួយសទ្ធិវិហារិករបស់លោកអ្នក)

## សំណួរខាងវិញ្ញាណ

- តើព្រះកំពុងមានបន្ទូលអ្វីមកលោកអ្នកនៅពេលនេះ? តើលោកអ្នកដឹងការនេះយ៉ាងដូចម្ដេច?
- តើព្រះបានបង្រៀនអ្វីដល់លោកអ្នកចាប់តាំងពីពេលជួបគ្នាកាលពីមុនរបស់យើងមក?
- តើលោកអ្នកវាយតម្លៃការដើររបស់លោកអ្នកជាមួយព្រះនៅពេលនេះយ៉ាងដូចម្ដេចៈ ជិតស្និទ្ធ មធ្យម ឬនៅឆ្ងាយ?
- តើលោកអ្នកមានពេលស្ងៀមស្ងាត់ប្រចាំថ្ងៃជាមួយព្រះដែរឬទេ? ចូរពណ៌នាអំពីពេលនោះប្រាប់ខ្ញុំ ។
- តើលោកអ្នកដាក់បញ្ចូលវិន័យអធិស្ឋាន និងតមអាហារមកក្នុងជីវិតរបស់លោកអ្នកដូចម្ដេច នៅពេលដែលលោកអ្នកដាំក្រុមជំនុំនេះ?
- តើលោកអ្នកកំពុងចំណាយពេលតែម្នាក់ឯងដើម្បីស្ដាប់ព្រះសូរសៀងរបស់ព្រះដែរឬទេ? ចូរពណ៌នាអំពីការនោះ ។
- ប្រសិនបើលោកអ្នកចង់ចែកចាយ ចូរប្រាប់ខ្ញុំអំពីផ្នែកណាមួយដែលលោកអ្នកកំពុងលំបាកខាងវិញ្ញាណ ។

## សំណួរអំពីគ្រួសារ

- តើលោកអ្នកឲ្យពេលប៉ុន្មានទៅគ្រួសាររបស់លោកអ្នក? តើពេលវេលាប៉ុន្មានភាគរយសម្រាប់តែគ្រួសាររបស់លោកអ្នក?
- តើលោកអ្នក និងប្ដី ឬប្រពន្ធរបស់លោកអ្នកមានពេលពិសេសរៀងរាល់សប្ដាហ៍ដែរឬទេ ជាពេលដែលលោកអ្នកចេញទៅតែពីរនាក់ដើម្បីជ្រោភ្ជាប់ឡើងវិញ? សូមចែកចាយប្រាប់ខ្ញុំពីអ្វីដែលលោកអ្នកធ្វើ ។
- តើកូនរបស់លោកអ្នកមានអារម្មណ៍ដូចម្ដេចអំពីពេលវេលាដែលលោកអ្នកមានសម្រាប់ពួកគេ?
- តើលោកអ្នកធ្វើកិច្ចការអ្វីខ្លះដើម្បីធ្វើឲ្យផ្ទះរបស់លោកអ្នកក្លាយទៅជាទីជម្រកដ៏មានសុវត្ថិភាពសម្រាប់គ្រួសាររបស់លោកអ្នក? តើលោកអ្នកការពារផ្ទះរបស់លោកអ្នកកុំឲ្យក្លាយជាផ្ទះសាធារណៈដែលមានការមកលេងជាដរាបពីអ្នកដែលលោកអ្នកកំពុងបម្រើយ៉ាងដូចម្ដេច?
- តើលោកអ្នកកំពុងដោះស្រាយបញ្ហាគ្រួសារណាមួយដែលកំពុងរារាំងសមត្ថភាពរបស់លោកអ្នកមិនឲ្យមានប្រសិទ្ធភាពនៅក្នុងការដាំក្រុមជំនុំដែរឬទេ?

## សំណួរអំពីព័ន្ធកិច្ច

- តើលោកអ្នកអាចប្រាប់ខ្ញុំអំពីការទៅលេងនាពេលថ្មីៗនេះ ដែលលោកអ្នកមានជាមួយអ្នកទាក់ទងថ្មីបានដែរឬទេ?
- តើមានការលំបាកដែលលោកអ្នកកំពុងមាននៅពេលឥឡូវនេះនៅក្នុងការដាំក្រុមជំនុំដែរឬទេ?
- តើលោកអ្នកបានទៅលេងប៉ុន្មានដង ចាប់តាំងពីការជួបគ្នាលើកមុនរបស់យើងមក ហើយនៅក្នុងចំណោមការទៅលេងទាំងនេះ តើប៉ុន្មានដងជាការទៅលេងបែបថែបំប៉ន?
- តើលោកអ្នកកំពុងធ្វើអ្វីដើម្បីស្គាល់តំបន់នោះកាន់តែច្បាស់?
- តើលោកអ្នករៀនបានអ្វីថ្មីអំពីតំបន់គោលដៅរបស់លោកអ្នក?

- តើមានជម្លោះកើតឡើងដែរឬទេ? ប្រសិនបើមាន តើលោកអ្នកបានដោះស្រាយជម្លោះនោះដូចម្ដេច?
- តើលោកអ្នកឃើញមនុស្សណានៅក្នុងក្រុមតូចរបស់លោកអ្នកដែលមានសក្តានុពលក្លាយជាអ្នកដឹកនាំដែរឬទេ? ចូរប្រាប់ខ្ញុំអំពីពួកគេ ។
- តើលោកអ្នកមានអារម្មណ៍ស្រួលចិត្តយ៉ាងណាជាមួយនឹងល្បឿនដែលក្រុមជំនុំកំពុងត្រូវបានដាំ?
- តើមានផ្នែកណាមួយនៅក្នុងព័ន្ធកិច្ចដែលលោកអ្នកកំពុងតែឃើញខ្លួនឯងមិនស្រួលចិត្ត ឬត្រូវការជំនួយដែរឬទេ?
- តើលោកអ្នកបានសុំអ្នកណាឲ្យធ្វើជាអ្នកអធិស្ឋានគាំទ្រសម្រាប់លោកអ្នក នៅពេលដែលលោកអ្នកដាំក្រុមជំនុំនេះ? តើលោកអ្នកប្រាប់សំណូមពរអធិស្ឋាន និងការឆ្លើយតបដល់ពួកគេញឹកញាប់ប៉ុនណា?

**ចំណុចសកម្មភាព**

- តើលោកអ្នកសង្ឃឹមថានឹងឆ្លងផុតឧបសគ្គនេះយ៉ាងដូចម្ដេច?
- តើលោកអ្នកនឹងបែរទៅរកអ្នកណាដើម្បីទទួលបានជំនួយជាមួយបញ្ហាដែលលោកអ្នកទើបតែបានលើកឡើង?
- តើលោកអ្នកចង់សម្រេចអ្វីនៅចន្លោះពេលឥឡូវនេះ និងពេលក្រោយទៀតដែលយើងជួបគ្នា?

តើលោកអ្នកមើលឃើញអ្វីជាកិច្ចការបន្ទាប់ដែលលោកអ្នកត្រូវធ្វើអំពីស្ថានភាពនេះ?

# សេណារីយ៉ូសម្រាប់ពេលជុំគ្នាជាមួយឧបជ្ឈាយ៍

## គោលបំណង

លំហាត់នេះមានគោលដៅផ្តល់ឲ្យសិក្ខាកាមមានឱកាសហាត់ធ្វើពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ។ យើងផ្តល់ជូនសេណារីយ៉ូជៀងគ្នាបី ។ សេណារីយ៉ូនីមួយៗគួរតែចំណាយពេលដប់នាទីបានហើយ ។ សេណារីយ៉ូទាំងអស់ត្រូវការឧបជ្ឈាយ៍ និងសទ្ធិវិហារិក ។ ក្រោយពីពណ៌នាសេណារីយ៉ូប្រាប់ឧបជ្ឈាយ៍ និងសទ្ធិវិហារិកដោយសម្ងាត់រួចហើយ ចូរទុកពេលឲ្យពួកគេប៉ុន្មាននាទីដើម្បីរៀនចំ មុនពេលដែលសម្តែងសេណារីយ៉ូនោះ នៅមុខមនុស្សដទៃទៀត ។ ក្រោយពី «ពេលជួបគ្នា»នេះរួចហើយ ចូរសួរសិក្ខាកាមដទៃទៀតអំពីរបៀបដែលពួកគេវាយតម្លៃប្រសិទ្ធភាពរបស់ឧបជ្ឈាយ៍ ។ តើគាត់ធ្វើអ្វីបានល្អ? តើគាត់អាចធ្វើបានកាន់តែប្រសើរជាងនេះដោយរបៀបណា?

## យោបល់

ចូរយកចិត្តទុកដាក់ជាពិសេសចំពោះភាគរយនៃពេលវេលាដែលឧបជ្ឈាយ៍និយាយ ។ ភាគរយនោះគួរតែតិច ។ លើសពីនេះទៀត ទំនាក់ទំនងរបស់ឧបជ្ឈាយ៍គួរតែសួរឲ្យបានច្រើន ជំនួសឲ្យការផ្តល់គំនិត ឬយោបល់របស់ខ្លួន ។ ឧបជ្ឈាយ៍គួរតែ:

១. សួរសំណួរដើម្បីបញ្ជាក់ច្បាស់អំពីស្ថានភាព ។
២. និយាយឡើងវិញអ្វីដែលគេស្តាប់ឮពីសទ្ធិវិហារិករបស់គេ ដើម្បីប្រាកដថា គេយល់អំពីស្ថានភាព ។
៣. សួរសំណួរដែលនឹងជួយសទ្ធិវិហារិករកមើលជម្រើស ឬចម្លើយផ្សេងៗសម្រាប់បញ្ហា ។
៤. បង្ហាញភាពអាណិតអាសូរដល់សទ្ធិវិហារិក ឬបង្ហាញការចាប់អារម្មណ៍ចំពោះអ្វីដែលគេកំពុងតែនិយាយ ។

កំណត់សម្គាល់: បុរសគួរតែធ្វើជាឧបជ្ឈាយ៍ដល់បុរស ហើយស្ត្រីគួរតែធ្វើជាឧបជ្ឈាយ៍ដល់ស្ត្រី ។

សេណារីយ៉ូទី ១

*សទ្ធិវិហារិកមកជួបឧបជ្ឈាយ៍របស់ខ្លួនទាំងព្រួយបារម្ភ និងភ័យខ្លាច ។ សមាជិកពីរនាក់នៅក្នុងក្រុមតូចកាលពីសប្តាហ៍មុនបានទាស់សម្តីគ្នាយ៉ាងខ្លាំង ។ សទ្ធិវិហារិកខ្លាចថា បើការឈ្លោះប្រកែកគ្នានៅតែបន្តកើតមាន វាអាចបំផ្លាញក្រុមតូច និងការងារទាំងអស់ដែលមានដូចជាការបង្កើតទំនាក់ទំនង ការបង្កើតក្រុម និងការចាប់ផ្តើមចែកចាយដំណឹងល្អជាមួយពួកគេ ។ គាត់ខ្លាចថា ភាពអវិជ្ជមានកំពុងតែមានឥទ្ធិពលមិនត្រឹមតែលើអ្នកទាំងពីរដែលទាស់គ្នាប៉ុណ្ណោះទេ ថែមទាំងលើក្រុមទាំងមូលទៀតផង ។*

**សេណារីយ៉ូទី ៣**
*ឧបជ្ឈាយ៍សួរអំពីជីវិតខាងវិញ្ញាណរបស់សទ្ធិវិហារិក ។ សទ្ធិវិហារិកចែកចាយថា គាត់រវល់យ៉ាងខ្លាំងជាមួយនឹងក្រុមជំនុំ ហើយជីវិតថ្វាយបង្គំផ្ទាល់ខ្លួនរបស់គាត់បានរងគ្រោះ ។ ជាលទ្ធផល គាត់មិនមានអារម្មណ៍ជិតស្និទ្ធខ្លាំងជាជាមួយព្រះទេ ។*

**សេណារីយ៉ូទី ២**
*នៅពេលដែលឧបជ្ឈាយ៍សួរអំពីគ្រួសាររបស់អ្នកដាំក្រុមជំនុំ សទ្ធិវិហារិកសារភាពថា ប្រពន្ធរបស់គាត់មិនឯកភាពជាមួយគាត់ថា ពួកគេគួរតែដាំក្រុមជំនុំតទៀតទេ ។ ឧបជ្ឈាយ៍ចង់ជួយអ្នកដាំក្រុមជំនុំរកមើលមូលហេតុ និងរបៀបផ្លាស់ប្តូរគំនិតរបស់ប្រពន្ធគាត់ ប្រសិនបើអាចធ្វើបាន ។*

# របាយការណ៍ដាំក្រុមជំនុំកខគ
របាយការណ៍ប្រចាំខែ

## ព័ត៌មានទូទៅ

| | | | | |
|---|---|---|---|---|
| របាយការណ៍ខែ | | បានជួបប្រជុំជាមួយគ្រូឧបជ្ឈា | បាទ/ចាស | ទេ |

| | |
|---|---|
| ឈ្មោះអ្នកដាំក្រុមជំនុំ | |
| តំបន់របស់អ្នកដាំក្រុមជំនុំ | |
| អ្នកសម្របសម្រួលតំបន់ | |

## បុគ្គល

| | គោលដៅ ប្រចាំខែ | លទ្ធផល ប្រចាំខែ |
|---|---|---|
| អ្នកថ្មីដែលត្រូវទាក់ទង<br>អ្នកដែលត្រូវបានទាក់ទងនៅក្នុងបរិបទដាំក្រុមជំនុំ ដើម្បីប្រាប់ដំណឹងល្អ | | |
| ការប្រែចិត្តថ្មី<br>អ្នកដើរតាមព្រះយេស៊ូ | | |
| អ្នកថ្មីដែលបានទទួលបុណ្យជ្រមុជទឹក<br>អ្នកដែលបានទទួលពិធីបុណ្យជ្រមុជទឹក | | |
| អ្នកដឹកនាំថ្មីដែលកំពុងទទួលការហ្វឹកហ្វឺន<br>អ្នកដែលអ្នកដាំក្រុមជំនុំកំពុងហ្វឹកហ្វឺនឲ្យធ្វើជាអ្នកដឹកនាំ | | |

## ក្រុមតូចៈ ជាអប្បបរិមា សិស្សថ្មីពីរនាក់ និងអ្នកដឹកនាំម្នាក់

| | គោលដៅ ប្រចាំខែ | លទ្ធផល ប្រចាំខែ |
|---|---|---|
| ក្រុមតូចថ្មី<br>ក្រុមដែលបានចាប់ផ្តើមខែនេះ | | |
| អ្នកចូលរួមថ្មីនៅក្នុងក្រុមតូច<br>មនុស្សថ្មីដែលចូលរួមក្រុមតូចនៅខែនេះ | | |
| អ្នកដឹកនាំថ្មីដែលមានមួយក្រុម<br>អ្នកដឹកនាំថ្មីដែលមានមួយក្រុមនៅក្រោមការត្រួតពិនិត្យមើលរបស់អ្នកដាំពួកជំនុំ | | |

## សំណូមពរអធិស្ឋាន (តម្រូវឲ្យសរសេរយ៉ាងតិចពេញមួយប្រឡោះនេះ)

១ ______

២ ______

៣ ______

## ទីបន្ទាល់

______

______

______

______

______

______

ព័ន្ធកិច្ចបណ្តាញពហុគុណ | កខគ របស់អ្នកដាំក្រុមជំនុំ

# កំណត់សម្គាល់ពីពួកអ្នកនិពន្ធ

កំណត់សម្គាល់បែបពន្យល់ និងព័ត៌មានលម្អិតបន្ថែមមកពីមគ្គុទេសន៍របស់អ្នកហ្វឹកហ្វឺនដើម ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងសំណៅនេះ ត្រូវបានរកឃើញនៅក្នុងឧបសម្ព័ន្ធនេះ ។ ក្រោយពីការសាកល្បងជាក់ស្តែងជាច្រើន ខ្លឹមសារត្រូវបានបង្រួម ហើយលំដាប់លំដោយត្រូវបានផ្លាស់ប្តូរបន្តិច ដើម្បីផ្តល់ភាពលំហូរកាន់តែអស្ចារ្យ និងដាក់ការបង្រៀនតាមលំដាប់លំដោយដែលកាន់តែត្រឹមត្រូវ ។ ផ្នែក«កំណត់សម្គាល់មកពីអ្នកនិពន្ធផ្សេងៗ»អាចត្រូវបានប្រើដើម្បីសិក្សាលម្អិតបែមទៀតអំពីប្រធានបទមួយចំនួន ប្រសិនបើមានពេល ។

## ឧទាហរណ៍នៅក្នុងព្រះគម្ពីរអំពីដំណើរការឧបជ្ឈាយ៍

ជាមួយនឹងសិក្ខាកាម ចូររំឭកឡើងវិញនូវធាតុសំខាន់ៗនៅក្នុងនិយមន័យរបស់លោក គ្លីនតុន និងលោក ស្តិនលី អំពីការធ្វើជាឧបជ្ឈាយ៍: (១) ការធ្វើជាឧបជ្ឈាយ៍គឺជាបទពិសោធន៍ទំនាក់ទំនង (២) ឧបជ្ឈាយ៍មានបទពិសោធន៍ដើម្បីចែករម្លែក (៣) មានអ្វីផ្ទេរឲ្យ (៤) ឧបជ្ឈាយ៍សម្របសម្រួលឲ្យមានការអភិវឌ្ឍន៍ និង (៥) ឧបជ្ឈាយ៍ពង្រឹង[1] ។ ចូរប្រើធាតុទាំងនេះធ្វើជាក្របខណ្ឌ ដើម្បីពិនិត្យមើលដំណើរការឧបជ្ឈាយ៍នៅក្នុងឧទាហរណ៍ក្នុងព្រះគម្ពីរនីមួយៗដែលមកក្រោយ ។ ឧទាហរណ៍នីមួយៗដែលកាន់តែពេញលេញត្រូវបានផ្តល់ឲ្យនៅក្នុងសៀវភៅដែលមានចំណងជើងថា *ហេតុអ្វីធ្វើជាឧបជ្ឈាយ៍ដល់អ្នកដាំក្រុមជំនុំ?* ត្រូវបានរកឃើញនៅក្នុងកញ្ចប់ឧបករណ៍សម្រាប់ការធ្វើជាឧបជ្ឈាយ៍ ។

## គ្រឹះខាងទេវសាស្ត្រសម្រាប់ការធ្វើជាឧបជ្ឈាយ៍

ផ្នែកនេះត្រូវបានចែកចេញជាបី ។ នៅក្នុងផ្នែកទីមួយ សិក្ខាកាមនឹងពិនិត្យមើលរបៀបដែលព្រះក្នុងនាមជាព្រះត្រីឯកផ្តល់មូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងរបស់មនុស្ស ។ ផ្នែកទីពីរពណ៌នាអំពីការដាក់បញ្ចូលគោលការណ៍នេះទៅក្នុងការបង្កើតមនុស្សរបស់ព្រះ ។ ផ្នែកទីបីស្វែងយល់អំពីការយាងមកប្រសូតជាមនុស្សរបស់ព្រះយេស៊ូ និងព័ន្ធកិច្ចរបស់ព្រះអង្គជាគំរូសម្រាប់ការដែលយើងប្រើលក្ខណៈទាំងនេះនៅក្នុងការធ្វើជាឧបជ្ឈាយ៍ដល់អ្នកដទៃទៀត ។

## មូលដ្ឋានគ្រឹះនៅក្នុងលក្ខណៈនៃព្រះត្រីឯក

នៅក្នុងផ្នែកនេះ លោកអ្នកនឹងជួយសិក្ខាកាមឲ្យយល់អំពីរបៀបដែលលក្ខណៈរបស់ព្រះត្រីឯកពាក់ព័ន្ធនឹងភារកិច្ចរបស់យើងក្នុងការធ្វើជាឧបជ្ឈាយ៍ដល់អ្នកដាំក្រុមជំនុំថ្មី ។ ទីមួយ ចូរពន្យល់ថា នេះគឺជាការតំណាងដ៏ត្រឹមត្រូវឲ្យរបៀបដែលព្រះបានបើកសម្តែងអង្គទ្រង់ឲ្យយើងស្គាល់ ។

[1] Stanley and Clinton, Connecting, 12.

ទោះបីជាពាក្យ ព្រះត្រីឯក មិនត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរក៏ដោយ គោលគំនិតអំពីលក្ខណៈត្រីឯករបស់ព្រះ អាចត្រូវបានសង្កេតឃើញតាមរយៈការសិក្សាបទគម្ពីរផ្សេងៗជាច្រើន ។ ក្រុមជំនុំបានជ្រើសរើសយកពាក្យនេះ ដើម្បីពន្យល់អំពីរបៀបដែលព្រះបានបើកសម្តែងអង្គទ្រង់ជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។

ទីពីរ ចូរពន្យល់ថា ទំនាក់ទំនងនៅក្នុងព្រះត្រីឯកកើតចេញពីព្រះបីអង្គដែលរួមគ្នាទាំងស្រុង ដែលអង្គនីមួយស្មើគ្នា គង់នៅអស់កល្បជានិច្ចដូចគ្នា និងមិនអាចបំបែកបាន ។ ចូរអនុវត្តការពណ៌នាអំពីព្រះត្រីឯកនេះទៅក្នុងការធ្វើជាឧបជ្ឈាយ៍តាមរបៀបខាងក្រោម ។

- ទីមួយ ព្រះទ្រង់ជា**សេចក្តីស្រឡាញ់** ។ ផ្នែកគន្លឹះនៃលក្ខណៈរបស់ព្រះគឺជាសេចក្តីស្រឡាញ់ដែលលះបង់ជីវិត ។
- ទីពីរ ព្រះត្រីឯកទ្រង់គង់នៅក្នុង**សហគមន៍**ដ៏នៅអស់កល្ប ដែលបង្ហាញចេញលក្ខណៈជាសេចក្តីស្រឡាញ់ និងការរួមគ្នា ។
- ទីបី ព្រះទ្រង់មានសមត្ថភាព**ទំនាក់ទំនង**ទាំងនៅក្នុងព្រះត្រីឯក ទាំងជាមួយស្នាព្រះហស្តរបស់ព្រះអង្គ ។
- ទីបួន ព្រះទ្រង់**យកព្រះហឫទ័យទុកដាក់ចំពោះ**មនុស្ស និងរបស់សព្វសារពើទាំងអស់ ។

លក្ខណៈទាំងនេះរបស់ព្រះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងមនុស្សដែលព្រះអង្គបានបង្កើត ។

**សកម្មភាព:**
ចូរសុំសិក្ខាកាមឲ្យផ្តល់ឧទាហរណ៍អំពីរបៀបដែលពួកគេបានឃើញលក្ខណៈរបស់ព្រះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងការបង្កើតលោក ។ តើផ្នែកទាំងនេះនៃលក្ខណៈរបស់ព្រះអាចពាក់ព័ន្ធនឹងការធ្វើជាឧបជ្ឈាយ៍របស់យើងយ៉ាងដូចម្តេច?

## មូលដ្ឋានគ្រឹះនៅក្នុងការបង្កើតលោករបស់ព្រះ

លក្ខណៈ និងចរិតរបស់ព្រះ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងសកម្មភាពដែលទ្រង់បង្កើតលោក ។ សេចក្តីស្រឡាញ់របស់ព្រះអង្គ និងសមត្ថភាពរបស់ព្រះអង្គសម្រាប់ទំនាក់ទំនង បានជំរុញព្រះអង្គឲ្យបង្កើតសាកលលោកធ្វើជាវត្ថុជាទីស្រឡាញ់ និងជាទីយកព្រះហឫទ័យទុកដាក់របស់ព្រះអង្គ ។ ព្រះអង្គបានបង្កើតរបស់សព្វសារពើដែលមានចេញពីគ្មានអ្វីសោះសម្រាប់ថ្វាយជាសិរីល្អ និងជាទីសព្វព្រះហឫទ័យដល់ព្រះអង្គ ។ ស្នាព្រះហស្តបង្ហាញប្រាប់ការផ្តោតព្រះហឫទ័យសប្បុរសរបស់ព្រះទៅខាងក្រៅ ។ ព្រះអង្គធ្វើសម្រាប់ប្រយោជន៍របស់អ្នកដទៃទៀត ។ ដោយសង្កត់ធ្ងន់លើលក្ខណៈនេះ ព្រះអង្គបានបង្កើតមនុស្សមកឲ្យដូចជារូបព្រះអង្គ និងមានភាពដូចព្រះអង្គ—មានសមត្ថភាពស្រឡាញ់ រស់នៅក្នុងសហគមន៍ និងមានទំនាក់ទំនងជាមួយគ្នា ។

ដូច្នេះហើយ ព្រះបានបង្កើតមនុស្សសម្រាប់សហគមន៍ និងទំនាក់ទំនង ។ «ភាពត្រីឯក»របស់ព្រះ និងអ្វីៗទាំងអស់ដែលការនោះប្រាប់ដោយប្រយោល ផ្តល់ជាគំរូសម្រាប់ទំនាក់ទំនងរបស់មនុស្ស ។ ព្រះមិនត្រឹមតែបង្កើតប៉ុណ្ណោះ—ព្រះអង្គមានទំនាក់ទំនងជាមួយស្នាព្រះហស្តដែលព្រះអង្គបានបង្កើតទៀតផង ។

មនុស្សត្រូវបានព្រះបង្កើតមកឲ្យមានលក្ខណៈពិសេសជាច្រើនៈ

១. ពួកគេត្រូវបានបង្កើតមកដើម្បី**ស្រឡាញ់:**
- ដើម្បីស្រឡាញ់ព្រះ
- ដើម្បីស្រឡាញ់អ្នកជិតខាងខ្លួន

២. មនុស្សត្រូវបានបង្កើតមកសម្រាប់**សហគមន៍:**
- រស់នៅដោយមានសេចក្តីស្រឡាញ់ និងស្មោះភាពជាមួយមនុស្សដទៃទៀត ដោយធ្វើជាគំរូអំពីការរួមគ្នារបស់ព្រះត្រីឯក ។
- សហគមន៍គឺជាការបង្ហាញចេញពេញលេញពីទំនាក់ទំនងប្រកបដោយសេចក្តីស្រឡាញ់ ។

៣. មនុស្សត្រូវបានបង្កើតមកសម្រាប់**ទំនាក់ទំនង:**
- ជាមួយព្រះអាទិកររបស់ពួកគេ
- ជាមួយពិភពលោកដែលព្រះបានបង្កើតមក ។ ទំនាក់ទំនងដែលព្រះបានប្រទានឲ្យនេះរួមបញ្ចូលទាំងការទទួលខុសត្រូវគ្រប់គ្រង និងមើលថែពិភពលោកដែលព្រះបានបង្កើតមក
- ជាមួយមនុស្សដទៃទៀត

៤. មនុស្សត្រូវបានបង្កើតមកឲ្យមានសមត្ថភាព និងការទទួលខុសត្រូវឲ្យ**យកចិត្តទុកដាក់**ចំពោះមនុស្សដទៃទៀត និងរបស់សព្វសារពើដែលបានបង្កើតមក មិនមែនគ្រាន់តែខ្លួនឯងប៉ុណ្ណោះទេ:
- ការផ្តោតអារម្មណ៍នៅក្នុងការបង្កើតលោករបស់ព្រះគឺឆ្ពោះទៅខាងក្រៅ ឆ្ពោះទៅរកមនុស្សដទៃទៀត ។

**សកម្មភាព:**
តើការបង្កើតមកឲ្យដូចជារូបអង្គព្រះ និងមានភាពដូចជាព្រះ មានឥទ្ធិពលលើរបៀបដែលយើងមានទំនាក់ទំនងជាមួយមនុស្សដទៃទៀតដូចម្តេច?

យើងត្រឡប់ដូចជារូបរបស់ព្រះនៅក្នុងព្រះយេស៊ូគ្រិស្តកាន់តែច្រើនឡើង យើងក៏កាន់តែឆ្លុះបញ្ចាំងឲ្យឃើញសេចក្តីស្រឡាញ់របស់ព្រះអង្គ និងសមត្ថភាពរស់នៅក្នុងសហគមន៍របស់ព្រះអង្គ ។ តើវានឹងមើលទៅមានលក្ខណៈយ៉ាងដូចម្តេច ប្រសិនបើរូបរបស់ព្រះបង្ហាញឲ្យឃើញនៅក្នុងមនុស្សនៅក្នុងព័ន្ធកិច្ចរបស់គេ? (ឧទាហរណ៍មួយចំនួន: ភាពអត់

ធ្មត់ជាមួយមនុស្សដែលពិបាក ការអត់ទោសសម្រាប់សមាជិកក្រុមជំនុំដែលបានធ្វើខុសនឹងបងប្អូននៅក្នុងព្រះគ្រិស្ត ការប្រាប់សេចក្តីពិតដោយនៅក្នុងសេចក្តីស្រឡាញ់) ។

## មូលដ្ឋានគ្រឹះក្នុងការយាងមកប្រសូតជាមនុស្ស

សកម្មភាព:
ចូរជ្រើសរើសសិក្ខាកាមជៀងៗឲ្យអានបទគម្ពីរទាំងប្រាំនេះ: យ៉ូហាន ៣:១៦ ម៉ាថាយ ២០:២៨ ម៉ាកុស ១០:៤៥ យ៉ូហាន ១០:១១ ភីលីព ២:៥-១១ ។ ក្រោយពីអានបទគម្ពីរនីមួយៗរួចហើយ ចូរសុំសិក្ខាកាមជៀងទៀតឲ្យពន្យល់អំពីអ្វីដែលបទគម្ពីរនីមួយៗប្រាប់យើងអំពីការយាងមកប្រសូតជាមនុស្ស ។ តើព្រះយេស៊ូអនុវត្តការនេះយ៉ាងដូចម្តេចនៅក្នុងសេចក្តីបង្រៀនរបស់ព្រះអង្គអំពីភាពជាអ្នកធំនៅក្នុងព្រះរាជ្យរបស់ព្រះ? តើបទគម្ពីរទាំងនោះអនុវត្តការនេះមកក្នុងការធ្វើជាឧបដ្ឋាយ៍យ៉ាងដូចម្តេច?

ព្រះបានយាងមក**រស់នៅ**ជាមួយ**មនុស្ស**ក្នុងសណ្ឋានដែលភ្នែកអាចមើលឃើញ តាមរយៈការយាងមកប្រសូតជាមនុស្ស ។ ព្រះយេស៊ូដែលបានប្រសូតពី**ស្ត្រីក្រមុំព្រហ្មចារីយ៍ម៉ារី** គឺជា**អេម៉ាញូអែល ព្រះ**ដែលគង់នៅជាមួយ**យើង** ។ ព្រះអង្គត្រូវបានចាត់មកក្នុងពិភពលោកនេះដោយព្រោះសេចក្តីស្រឡាញ់របស់ព្រះ (យ៉ូហាន ៣:១៦) ។ ព្រះអង្គបានយាងមកដើម្បីបង្ហាញ**ព្រះវរបិតា**ឲ្យយើងស្គាល់ ។ ទោះបីជាព្រះយេស៊ូគឺជាព្រះដែលបានយាងមកប្រសូតជាមនុស្សក៏ដោយ ព្រះអង្គបានប្រាប់យើងថា ព្រះអង្គបានយាងមកដើម្បីបម្រើគេ មិនមែនឲ្យគេបម្រើព្រះអង្គទេ (ម៉ាថាយ ២០:២៨ ម៉ាកុស ១០:៤៥ យ៉ូហាន ១០:១១ ភីលីព ២:៥-១០) ។

ដោយការមកឯយើងក្នុងសណ្ឋានជាមនុស្ស ព្រះយេស៊ូបានបង្ហាញរបៀបដែលព្រះចង់ឲ្យយើងប្រើសមត្ថភាពដែលព្រះអង្គបានប្រទានឲ្យយើងក្នុងនាមជាមនុស្ស—**ស្រឡាញ់** មាន**ទំនាក់ទំនង** សង់**សហគមន៍** និងបម្រើ**អ្នកដទៃទៀត** សម្រាប់ជាប្រយោជន៍ដល់ព្រះរាជ្យរបស់ព្រះ ។ ព្រះអង្គបានសម្រេចការនេះ ដោយចូលទៅក្នុងទំនាក់ទំនង និងបង្កើតសហគមន៍ជាមួយសិស្សរបស់ព្រះអង្គ ។ លោកម៉ាកុសប្រាប់យើងថា ចេញពីក្នុងចំណោមអ្នកដើរតាមព្រះអង្គជាច្រើន ព្រះយេស៊ូបានជ្រើសរើសមនុស្សដប់ពីរនាក់ «ដោយតែងតាំងពួកគេឲ្យធ្វើជាសាវក» ដោយមានគោលបំណងពីរ ។ ទីមួយ «ដើម្បីឲ្យគេនៅជាមួយព្រះអង្គ» និង «ដើម្បីចាត់គេឲ្យចេញទៅប្រកាស និងមានអំណាចដេញអារក្សផង» (ម៉ាកុស ៣:១៤ – ១៥) ។ នេះគឺជាអាទិភាពដែលត្រូវបានឲ្យដល់ការមាន**ទំនាក់ទំនង**ជាមួយព្រះអង្គ[2] ។ ដោយដឹងពីពេលវេលាមានកំណត់ដែលព្រះអង្គមានដើម្បីបម្រើពួកគេ អ្នកគង្វាលល្អបានចំណាយពេលព្រះអង្គភាគច្រើនធ្វើជាឧបដ្ឋាយ៍ដល់អ្នកទាំងដប់ពីរ: បង្រៀន បង្ហាញប្រាប់ និងពង្រឹងពួកគេឲ្យធ្វើកិច្ចការរបស់ព្រះអង្គក្រោយពីព្រះអង្គចាកចេញទៅ ។ ជាមួយព្រះបន្ទូលចុងក្រោយរបស់ព្រះអង្គ ព្រះយេស៊ូបានបង្គាប់ពួកគេ

[2] This concept is fully developed in *The Training of the Twelve* by A. B. Bruce (1971) and *The Master Plan of Evangelism* by Robert E. Coleman (1963).

ឲ្យ**ធ្វើជាឧបជ្ឈាយ៍**ដល់អ្នកដទៃទៀត ដូចដែលព្រះអង្គបានធ្វើជាឧបជ្ឈាយ៍ដល់ពួកគេដែរ (ម៉ាថាយ ២៨:១៩-២០ យ៉ូហាន ២០:២១) ។

## និយមន័យ « *ការធ្វើជាឧបជ្ឈាយ៍*»

ចូរពន្យល់ថា ការប្រើពាក្យ ឧបជ្ឈាយ៍ និងការធ្វើជាឧបជ្ឈាយ៍នៅក្នុងជំនួញ និងការអប់រំ ផ្តល់ឲ្យយើងមានការយល់ដឹងទូទៅអំពីពាក្យទាំងនេះ ។ លោកអ្នកប្រហែលជាសួរថា ដូច្នេះ ហេតុអ្វីចាំបាច់ឲ្យនិយមន័យគោលគំនិតនេះនៅត្រង់នេះ? ចូរផ្តល់យោបល់ចម្លើយខាងក្រោម:

១. និយមន័យដ៏ត្រឹមត្រូវបញ្ជាក់ច្បាស់អំពីគោលគំនិតនេះ និងផ្តល់រូបភាពដ៏ច្បាស់លាស់នៅក្នុងគំនិតអំពីដំណើរការនេះ មនុស្សដែលពាក់ព័ន្ធ និងតួនាទីរបស់ពួកគេ ។
២. ដោយសារការស្គាល់គោលដៅយ៉ាងជាក់លាក់ គំនិតប៉ាន់ស្មានដែលមិនត្រឹមត្រូវត្រូវបានជំនួសដោយគោលគំនិតវិជ្ជមានវិញ ។
៣. និយមន័យត្រឹមត្រូវផ្តល់មធ្យោបាយច្បាស់លាស់សម្រាប់វាស់ស្ទង់ការប្រព្រឹត្តិដោយសិក្ខាកាមនៅគ្រប់ដំណាក់កាលទាំងអស់របស់ដំណើរការឧបជ្ឈាយ៍ ។

និយមន័យខាងក្រោមសម្រាប់ការធ្វើជាឧបជ្ឈាយ៍មានចាប់ពីសាមញ្ញដល់ស្មុគស្មាញ ។ ចូររំឮកនិយមន័យនីមួយៗឡើងវិញ ហើយពិចារណាការប្រាប់ដោយប្រយោលរបស់គោលគំនិតនីមួយៗដែលបានបង្ហាញប្រាប់ ។ ចូរអញ្ជើញសិក្ខាកាមឲ្យគូសបន្ទាប់ពីក្រោមផ្នែកគន្លឹះរបស់ការធ្វើជាឧបជ្ឈាយ៍ដែលពួកគេរកឃើញនៅក្នុងនិយមន័យ បន្ទាប់មក ចូរសុំពួកគេឲ្យចែកចាយអ្វីដែលពួកគេបានគូសបន្ទាត់ពីក្រោម ។

## និយមន័យសាមញ្ញ

យើងចាប់ផ្តើមជាមួយនិយមន័យដ៏សាមញ្ញនេះ: ការធ្វើជាឧបជ្ឈាយ៍ គឺជា**ទំនាក់ទំនង**ដោយ**ចេតនា** និង **មានរយៈពេលយូរអង្វែង** ដែលតាមរយៈនោះ មនុស្សម្នាក់ផ្ទេរ **បទពិសោធន៍ ចំណេះដឹង** និង**ការយល់ដឹង** ដើម្បីអភិវឌ្ឍសមត្ថភាព និងជំនាញនៅក្នុង**មនុស្សម្នាក់ទៀត** ។

អ្នកនិពន្ធ ប៉ុល ស្តិនលី និង រ៉ូប៊ើត ជេ. គ្លីនតុន ពណ៌នាអំពីការធ្វើជាឧបជ្ឈាថាជា«បទពិសោធន៍ទំនាក់ទំនងដែលក្នុងនោះ មនុស្សម្នាក់**ពង្រឹង**មនុស្សម្នាក់ទៀត ដោយចែករំលែក**ធនធាន**ដែលព្រះបានប្រទានឲ្យ»[3] ។ ពួកគេពង្រីកនិយមន័យនោះ ដោយបន្ថែម**ធាតុផ្សំ**ជាច្រើនដែលត្រូវបានដាក់បញ្ចូលនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ។

[3] Stanley and Clinton, *Connecting*, 33.

«ឧបជ្ឈាយ៍គឺជាដំណើរការទំនាក់ទំនងដែលក្នុងនោះឧបជ្ឈាយ៍ដែលចេះ ឬមានបទពិសោធន៍អ្វីមួយ ផ្ទេរការនោះ (ធនធានដីជាប្រាជ្ញា ព័ត៌មាន បទពិសោធន៍ ទំនុកចិត្ត ការយល់ដឹង ទំនាក់ទំនង ឋានៈ ។ល ។) ទៅឲ្យសិទ្ធិវិហារិក នៅពេលដែលសមរម្យ និងតាមរបៀបដែលសមរម្យ ដូច្នេះហើយ ការនោះសម្របសម្រួលឲ្យមានការអភិវឌ្ឍន៍ ឬការពង្រឹង»[4] ។

**សកម្មភាព:**

- ចូរសុំសិក្ខាកាមឲ្យចែកចាយអ្វីដែលពួកគេបានកត់សម្គាល់ ។ ចូរសរសេរគំនិត ឬឃ្លាគន្លឹះនៅលើក្តារខៀន ឬផ្ទាំងក្រដាសធំមួយសន្លឹក ។
- ចូរសុំសិក្ខាកាមម្នាក់ឲ្យពន្យល់អត្ថន័យ ឬចែកចាយឧទាហរណ៍អំពីឃ្លាគន្លឹះដែលពួកគេបានគូសបន្ទាត់ពីក្រោម ចូរប្រាកដថា ពួកគេលើកឡើងចំណុចខាងក្រោម:

**គោលគំនិតគន្លឹះ**

(១) ឧបជ្ឈាយ៍គឺជាដំណើរការទំនាក់ទំនង (២) ឧបជ្ឈាយ៍មានបទពិសោធន៍ដើម្បីចែករំលែក (៣) មានអ្វីផ្ទេរឲ្យ (៤) ឧបជ្ឈាយ៍សម្របសម្រួលឲ្យមានការអភិវឌ្ឍន៍ (៥) ឧបជ្ឈាយ៍ពង្រឹង[5] ។

បន្ទាប់មក ចូរសុំសិក្ខាកាមឲ្យអាននិយមន័យទីពីរ និងរកភាពស្រដៀងគ្នាទៅនឹងនិយមន័យមុន ព្រមទាំងគំនិតថ្មីៗ ។ និយមន័យនេះបានមកពីលោក អូស្ទ័រហាយស៍ និង តេចា នៅក្នុងសៀវភៅរបស់ពួកគេដែលមានចំណងជើងថា *ភាពស្ទាត់ជំនាញនៅក្នុងការធ្វើជាឧបជ្ឈាយ៍* ។

«សម្រាប់ចេតនា និងគោលបំណងទាំងអស់...ការធ្វើជាឧបជ្ឈាយ៍គឺជាសកម្មភាពជួយមនុស្សម្នាក់ទៀតឲ្យរីកចម្រើននៅក្នុងជំនាញ អត្តចរិត និងចំណេះដឹងរបស់គេនៅផ្នែកណាមួយនៃជីវិត ។ ជាធម្មតា ការធ្វើជាឧបជ្ឈាយ៍ប្រាប់ដោយប្រយោលថា ម្នាក់ក្នុងចំណោមអ្នកទាំងពីរមានបទពិសោធន៍ច្រើនជាង មានចំណេះដឹងច្រើនជាង ដូច្នេះហើយមានសេចក្តីដែលស័ក្តិសមនឹងផ្ទេរទៅឲ្យអ្នកដែលក្មេងជាង មានបទពិសោធន៍តិចជាង និងមានចំណេះដឹងទាបជាង ។ ប្រព័ន្ធផ្គត់ផ្គង់សម្រាប់«ការផ្ទេរ»យ៉ាងដូច្នេះ គឺជាអ្វីដែលយើងកំពុងហៅថាការធ្វើជាឧបជ្ឈាយ៍ (២០១២:៣)[6] ។

**សកម្មភាព:**

ចូរសុំសិក្ខាកាមណាម្នាក់ដែលមានបទពិសោធន៍ជាមួយទំនាក់ទំនងឧបជ្ឈាយ៍បែបផ្លូវការឲ្យប្រាប់ពីរបៀបដែលបទពិសោធន៍របស់ពួកគេប្រៀបធៀបជាមួយនិយមន័យរបស់អ្នកនិពន្ធទាំងនេះ ។ ចូរឲ្យក្រុមប្រៀបធៀបនិយមន័យ ។

---

[4] *Ibid*, 40.

[5] *Ibid*, 40

[6] Osterhouse and Teja, *Masterful Mentoring*, 3

លោកអ្នកប្រហែលជាចង់ប្រើសំណួរទាំងនេះដើម្បីដឹកនាំ និងផ្ដោតអារម្មណ៍នៅក្នុងការពិភាក្សា:

- តើនិយមន័យទាំងនេះស្រដៀងគ្នាយ៉ាងដូចម្ដេច?
- តើនិយមន័យទាំងនេះមានគំនិតរួមអ្វីខ្លះ?
- តើនិយមន័យទីពីរផ្ដល់គំនិតថ្មីៗអ្វីខ្លះអំពីការធ្វើជាឧបជ្ឈាយ៍?

## និយមន័យ « សទ្ធិវិហារិក»

ចូរពន្យល់ប្រាប់សិក្ខាកាមថា មុនឆ្នាំ ១៩៧៨ ពាក្យ អ្នកនៅក្រោមអាណាព្យាបាល និងអ្នកហាត់ការ ត្រូវបានប្រើជាទូទៅដើម្បីពណ៌នាអំពីអ្នកទីពីរនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍[7] ។ ពាក្យនីមួយៗក្នុងចំណោមពាក្យទាំងនេះបង្ហាញប្រាប់អត្ថន័យនៃការពឹងផ្អែក ការគ្រប់គ្រង ឬការការពារពីឧបជ្ឈាយ៍ដែលជួយឲ្យយល់អំពីគោលគំនិតពាក់ព័ន្ធនឹងព័ន្ធកិច្ចដាំក្រុមជំនុំ ។ នោះគឺជាមូលហេតុដែលយើងបានជ្រើសរើសពាក្យ «សទ្ធិវិហារិក» ជាពាក្យអសាធារណៈ ដើម្បីពណ៌នាអំពីអ្នកទីពីរនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ។ ចូររំឭកឡើងវិញនូវនិយមន័យខាងក្រោមអំពីសទ្ធិវិហារិកចេញពី *ភាពស្ទាត់ជំនាញនៅក្នុងការធ្វើជាឧបជ្ឈាយ៍* បន្ទាប់មក ចូរប្រើឃ្លាគន្លឹះខាងក្រោម ដើម្បីជួយសិក្ខាកាមយល់អំពីលក្ខណៈរបស់សទ្ធិវិហារិក ។

សទ្ធិវិហារិកគឺជាសិស្សពេញវ័យជងដែរ ។ ក្នុងនាមជាសិស្សពេញវ័យ គេមានតួនាទីជាក់លាក់ដែលត្រូវបំពេញ ដែលផ្សេងពីតួនាទីរបស់អ្នកនៅក្រោមអាណាព្យាបាល (អ្នកនៅក្រោមការការពារ) ឬកុមារដែលត្រូវការឲ្យគេបញ្ចុកអាហារ ។ «ស្នូលរបស់ទំនាក់ទំនងឧបជ្ឈាយ៍ដែលប្រកបដោយប្រសិទ្ធភាពត្រូវបានដឹកនាំដោយសទ្ធិវិហារិក មិនមែនឧបជ្ឈាយ៍ទេ» ។ និយាយបានម្យ៉ាងទៀតថា ពាក្យ «សទ្ធិវិហារិក» ប្រាប់ពីរបៀបផ្សេងនៅក្នុងការមើលមកដំណើរការឧបជ្ឈាយ៍ ។ សទ្ធិវិហារិកមិនមែនជាអ្នកចូលរួមដែលអកម្មនៅក្នុងដំណើរការនេះទេ ប៉ុន្តែជាអ្នកចូលរួមដែលសកម្ម ។ សទ្ធិវិហារិកគឺជា«អ្នកដែលខិតខំប្រឹងប្រែងដើម្បីវាយតម្លៃ យកដាក់ក្នុងខ្លួន និងប្រើចំណេះដឹង ជំនាញ ការយល់ដឹង ទស្សនៈ ឬប្រាជ្ញាដែលបានផ្ដល់ឲ្យនោះយ៉ាងមានប្រសិទ្ធភាព...ដែលស្វះស្វែងរកជំនួយ និងប្រើជំនួយនោះយ៉ាងស័ក្តិសមសម្រាប់គោលបំណងអភិវឌ្ឍន៍នៅត្រង់កន្លែងណាដែលត្រូវការ» ។ សទ្ធិវិហារិកមិនមែនជាអ្នកត្រូវបានបង្កាត់ឲ្យដូចមនុស្សម្នាក់ផ្សេងទៀតទេ ផ្ទុយទៅវិញ គេគឺជាបុគ្គលដែលត្រូវបានជួយជារបហូតមក ដើម្បីអភិវឌ្ឍលក្ខណៈពិសេសដាច់ដោយឡែករបស់គេ ។

១. សទ្ធិវិហារិកគឺជាសិស្សពេញវ័យដែលសកម្ម ដែលទទួលស្គាល់សេចក្ដីត្រូវការចង់បានការយល់ដឹង**បន្ថែម** និងដំបូន្មាននៅក្នុងការអភិវឌ្ឍន៍ជំនាញ និងចំណេះដឹងនៅក្នុងការធ្វើព័ន្ធកិច្ច ។
២. សទ្ធិវិហារិកគឺជា«សិស្សពេញវ័យដែលព្រមទទួលយកការធ្វើដំណើរជួយដល់ការអភិវឌ្ឍន៍ខ្លួន» [8] ។

---

[7] *Ibid*, 8.

[8] Daloz, Effective *Teaching and Mentoring*, 206.

៣. សទ្ធិវិហារិកគឺជាអ្នកចូលរួមដែលសកម្ម មិនមែនអកម្មឡើយនៅក្នុងដំណើរការនេះ ។
៤. សទ្ធិវិហារិកខិតខំប្រឹងប្រែងដើម្បី**វាយតម្លៃ យកដាក់ក្នុងខ្លួន** និង**ប្រើ**ចំណេះដឹង ជំនាញ ការយល់ដឹង ទស្សនៈ ឬប្រាជ្ញាដែលបានផ្តល់ឲ្យនោះយ៉ាងមានប្រសិទ្ធភាព ។
៥. សទ្ធិវិហារិក**ស្វះស្វែងរកជំនួយ** និងប្រើជំនួយនោះយ៉ាងស័ក្តិសមសម្រាប់គោលបំណងអភិវឌ្ឍន៍នៅត្រង់កន្លែងណាដែលត្រូវការ ។
៦. សទ្ធិវិហារិក គឺជាបុគ្គលដែលត្រូវបានជួយរហូតមក ដើម្បីអភិវឌ្ឍ**លក្ខណៈពិសេសដាច់ដោយឡែក**របស់ខ្លួន ។
៧. ទំនាក់ទំនងឧបជ្ឈាយ៍ដែលមានប្រសិទ្ធភាព ត្រូវបានដឹកនាំដោយ**សទ្ធិវិហារិក** មិនមែនជាឧបជ្ឈាយ៍ទេ ។

**សកម្មភាព:**
ចូរឲ្យសិក្ខាកាមបំបែកទៅជាក្រុមតូច ។ ចូរបែងចែកអំណាននៃការពណ៌នារបស់អូស្ទើរហាយស៍ និងតេបា អំពីសទ្ធិវិហារិកដែលបានផ្តល់ឲ្យខាងលើ ហើយចូរឲ្យសិក្ខាកាមពិភាក្សាអំពីរបៀបដែលគំនូរពណ៌នានេះ ឆ្លុះការយល់ដឹងរបស់យើងអំពីអត្ថន័យនៃការធ្វើជាឧបជ្ឈាយ៍ ដោយធ្វើកិច្ចការខាងក្រោម:

- ចូរប្រើពាក្យផ្ទាល់ខ្លួនរបស់លោកអ្នករៀបរាប់ឡើងវិញលក្ខណៈរបស់សទ្ធិវិហារិកដែលបានកត់ត្រាខាងលើ ។ តើមានលក្ខណៈណាមួយដែលលោកអ្នកចង់ពន្យល់ដែរឬទេ?
- ប្រសិនបើទំនាក់ទំនងត្រូវបានដឹកនាំដោយសទ្ធិវិហារិក តើឧបជ្ឈាយ៍មានតួនាទីអ្វី?

## សិស្ស ឧបជ្ឈាយ៍ គ្រូបង្វឹក

នៅត្រង់ចំណុចនេះ វាប្រហែលជាចាំបាច់ដែលត្រូវតែបញ្ជាក់ឲ្យច្បាស់អំពីគោលគំនិតមួយចំនួនដែលអាចភាន់ច្រឡំនៅក្នុងការពិភាក្សាដ៏ពេញនិយមអំពីការធ្វើជាឧបជ្ឈាយ៍ ។ នៅក្នុងបញ្ញត្តិចុងក្រោយរបស់ព្រះយេស៊ូ ព្រះអង្គបានបង្គាប់អ្នកដើរតាមព្រះអង្គឲ្យបង្កើតសិស្សនៅគ្រប់ទាំងសាសន៍ ។ តើការបង្កើតសិស្ស និងការធ្វើជាឧបជ្ឈាយ៍មានន័យតែមួយ និងសម្រេចគោលដៅតែមួយដែរឬទេ? អ្នកនិពន្ធមួយចំនួនចាត់ទុកការបង្កើតសិស្សជាដំណើរពេញមួយជីវិតដែលនាំឲ្យរីកចម្រើនខាងវិញ្ញាណ ខណៈដែលអ្នកនិពន្ធខ្លះទៀត ចាត់ទុកការបង្កើតសិស្សជាការហ្វឹកហ្វឺនដំបូងក្នុងការរស់នៅជាគ្រិស្តបរិស័ទ អ្នកខ្លះទៀតបានយោងទៅរកការធ្វើជាឧបជ្ឈាយ៍ ថាជាការបង្កើតសិស្សកម្រិតខ្ពស់[9] ។ តើការបង្កើតសិស្សជំនួសដោយការធ្វើជាឧបជ្ឈាយ៍នៅត្រង់ចំណុចណា? តើការធ្វើជាឧបជ្ឈាយ៍ ខុសពីគោលគំនិតពាក់ព័ន្ធអំពីការបង្កើតសិស្ស និងការបង្វឹកយ៉ាងដូចម្តេច?

**សកម្មភាព:** ប្រសិនបើលោកអ្នកបានទាញយកសៀវភៅរួចហើយ ចូររំឭកឡើងវិញអំពីការខុសប្លែកគ្នារវាងពាក្យទាំងនេះនៅក្នុងសេចក្តីផ្តើមរបស់ *ភាពស្ទាត់ជំនាញក្នុងការធ្វើជាឧបជ្ឈាយ៍* ។ ចូរឲ្យសិស្សពិភាក្សាពាក្យទាំងនេះ ហើយ

[9] Brown, *Mentoring for Ministry*, 48

ញែកចេញរវាងប្រភេទព័ន្ធកិច្ចដែលចាំបាច់នៅតាមកម្រិតនីមួយៗនៃការអភិវឌ្ឍន៍អ្នកដឹកនាំ ។ ចូរឲ្យសិក្ខាកាមប្រាប់ឧទាហរណ៍អំពីអ្វីដែលមនុស្សប្រហែលជាត្រូវរៀននៅក្នុងការហ្វឹកហ្វឺនទាំងបីប្រភេទដែលបានរៀបរាប់ខាងលើ ។

## របៀបរៀន

**ការស្ដាប់:** អ្នកស្ដាប់ ឬអ្នករៀនតាមពាក្យនិយាយ គេរៀនបានល្អនៅពេលដែលព័ត៌មានត្រូវបានផ្ដល់មកតាមទម្រង់ជាសំឡេង ។ ពួកគេចងចាំ និងស្រូបបានច្រើនសម្រាប់ការបង្រៀន និងការពិភាក្សា ។ ពួកគេប្រហែលជាអានឮៗ ឬប្រើម៉ាស៊ីនថតសំឡេងដើម្បីចាក់ស្ដាប់ឡើងវិញជាមធ្យោបាយពង្រឹងការរៀនសូត្រ[10] ។

**ការមើល:** នៅពេលដែលព័ត៌មានត្រូវបានអាន ឬមើលឃើញ អ្នករៀនតាមចក្ខុវិញ្ញាណធ្វើបានយ៉ាងល្អ ។ ពួកគេចងចាំបានច្រើនបំផុតចេញពីហ្គ្រាហ្វិច រូបភាព និងរូបពន្យល់ ។ ជាញឹកញាប់ ពួកគេចូលចិត្តអង្គុយនៅជួរខាងមុខដើម្បីមើលឃើញអ្វីៗទាំងអស់ ។ ពួកគេបកស្រាយភាសាកាយវិការរបស់អ្នកនិយាយជាផ្នែកមួយនៃបទពិសោធន៍រៀនសូត្ររបស់ពួកគេ ។

**ការប៉ះ** អ្នករៀនតាមការប៉ះពាល់ ក៏ត្រូវបានហៅថាអ្នករៀនដោយកាយវិញ្ញាណ ។ ពួកគេគឺជាអ្នករៀនបែបរុករកដែលសមត្ថភាពរៀនរបស់គេ ត្រូវបានបង្កើនឡើងតាមរយៈការប៉ះពាល់ និងការពិសោធន៍ ប៉ុន្តែជាអ្នកដែលជួបប្រទះការលំបាកនៅក្នុងការរៀនដោយអាន ឬស្ដាប់ ។ ពួកគេរីកចម្រើនជាមួយវិធីសាស្ត្ររៀន«អនុវត្តផ្ទាល់» ដូចជាការពិសោធន៍ផ្នែកគីមីវិទ្យា ឬល្ខោន ។ ជាញឹកញាប់ ពួកគេនឹងគូររូប ឬប្រើសកម្មភាពស្រដៀងគ្នាដទៃទៀត ដើម្បីជំរុញការយល់ដឹង ខណៈពេលដែលកំពុងស្ដាប់មេរៀន ។

**បរិដ្ឋានជុំវិញ:** អ្នករៀនផ្អែកលើបរិដ្ឋានត្រូវគ្រប់គ្រងលើមជ្ឈដ្ឋានជុំវិញខ្លួន ។ ជាសុខភាពដែលព័ទ្ធជុំវិញ ពន្លឺ និងកម្រិតសីតុណ្ហភាពត្រឹមត្រូវបង្កើតសមត្ថភាពរបស់អ្នករៀនផ្អែកលើបរិដ្ឋានដើម្បីវិភាគ និងទទួលបានព័ត៌មានថ្មី ។

## ការប៉ាន់ស្មានគ្រឹះនៅក្នុងការរៀនរបស់មនុស្សពេញវ័យ[11]

ចូរពន្យល់ប្រាប់សិក្ខាកាមថា គោលគំនិតអំពីគរុកោសល្យសម្រាប់មនុស្សពេញវ័យបានកើតចេញពីការសិក្សារបស់លោកម៉ាល់ខុន ណូលេស និងសហការីរបស់លោក ។ ពួកគេបានផ្អែកកម្មវិធីអប់រំសម្រាប់មនុស្សពេញវ័យលើគំនិតប៉ាន់ស្មានគ្រឹះបួនខាងក្រោម ដ៏ជាគំនិតជាក់ស្ដែងដែលធ្វើជាគ្រឹះសម្រាប់វិធីសាស្ត្ររបស់ពួកគេនៅក្នុងការអប់រំសម្រាប់មនុស្សពេញវ័យ ។ ចូរណែនាំសិក្ខាកាមឲ្យស្គាល់គំនិតប៉ាន់ស្មានទាំងនេះ ។

---

[10] Two-thirds of the world are auditory learners.

[11] Adapted from Malcolm Knowles, *The Adult Learner: A Neglected Species* (1978): 56–71.

១. នៅពេលដែលមនុស្សពេញវ័យ ពួកគេមានបទពិសោធន៍ជាមួយការផ្លាស់ប្តូរសមត្ថភាពជ្រើសរើសរបស់ពួកគេ ។ នៅក្នុងទារកភាព និងកុមារភាព ការឈ្វេងយល់ពឹងអាងទាំងស្រុងលើអ្នកដទៃ ។ ភាពពេញវ័យបង្កើតអារម្មណ៍ដឹងថាត្រូវឯករាជ្យ និងស្វ័យដឹកនាំ ។ មនុស្សពេញវ័យធ្វើការជ្រើសរើស និងទទួលយកការទទួលខុសត្រូវសម្រាប់ពួកគេ ។ នៅត្រង់ចំណុចនេះ មនុស្សត្រូវបានចាត់ទុកថាពេញវ័យទៅតាមចិត្តសាស្ត្រ ។
២. ការចូលទៅក្នុងភាពពេញវ័យបង្កើនការជួបប្រទះនឹងបទពិសោធន៍ថ្មី និងផ្សេងៗ ។ បទពិសោធន៍ពេញមួយជីវិតដែលមនុស្សពេញវ័យនាំមកក្នុងដំណើរការរៀនសូត្របង្កើនសមត្ថភាពរបស់អ្នករៀនសូត្រយ៉ាងមានប្រសិទ្ធភាពដើម្បីផ្សារភ្ជាប់ និងទទួលបានប្រយោជន៍ចេញពីព្រឹត្តិការណ៍រៀនសូត្រថ្មីៗ ។ បណ្តុំ ឬកម្រងបទពិសោធន៍មានតម្លៃខ្លាំងណាស់សម្រាប់អ្នករៀនសូត្រដែលពេញវ័យ ។ ដូច្នេះ វិធីសាស្ត្របង្រៀនបែបបុរាណបើកផ្លូវឲ្យមានការចូលរួមកាន់តែច្រើនពីវិធីសាស្ត្រពិសោធន៍ជាក់ស្តែង ដែលលើកទឹកចិត្តឲ្យមានការអនុវត្តន៍ ការទំនាក់ទំនង និងការវិភាគបទពិសោធន៍ពីអ្នករៀនសូត្រ ។ នេះប្រាប់ដោយប្រយោលថា បទពិសោធន៍រៀនសូត្រមានលក្ខណៈទ្វេទិស ជាជាងឯកទិស ។
៣. នៅពេលដែលមនុស្សពេញវ័យ សំពាធឲ្យសិក្សាបែបទ្រឹស្តីត្រូវបានជំនួសដោយបំណងប្រាថ្នា និងការបណ្តាលចិត្តឲ្យរៀនផ្អែកលើសេចក្តីត្រូវការចង់មានជំនាញថ្មី និងសមត្ថភាពថ្មី ។ អ្នករៀនសូត្រត្រូវការសេចក្តីទាំងនេះ ដើម្បីធ្វើបានល្អនៅក្នុងភារកិច្ចថ្មីរបស់គេនៅក្នុងសង្គម ។ វាជាការសំខាន់ណាស់ដែលបទពិសោធន៍រៀនថ្មីត្រូវស្របជាមួយនឹងការអភិវឌ្ឍន៍ដែលត្រូវការ និងដែលផ្តោតលើភារកិច្ច ។
៤. ការអប់រំបែបបុរាណផ្តោតលើមុខវិជ្ជា ។ គ្រូពណ៌នាប្រាប់អំពីវគ្គសិក្សា និងមេរៀនដែលសិស្សត្រូវរៀនសម្រាប់ការប្រើប្រាស់ដែលអាចមាននៅពេលអនាគត ។ មនុស្សពេញវ័យចូលទៅក្នុងឱកាសអប់រំជាការឆ្លើយតបទៅនឹងសេចក្តីត្រូវការឲ្យមានសមត្ថភាពថ្មីនៅក្នុងផ្នែកជាក់លាក់ណាមួយដែលមានការខ្វះខាត ។ ការតម្រង់ទិសរបស់ពួកគេ ផ្តោតទៅលើបញ្ហា ឬផ្តោតទៅលើជីវិត ។ មានអារម្មណ៍បន្ទាន់នៅក្នុងការរៀនសូត្ររបស់មនុស្សពេញវ័យ—អ្វីដែលបានរៀនថ្ងៃនេះត្រូវអនុវត្តថ្ងៃស្អែក មិនមែននៅពេលអនាគតវែងឆ្ងាយទេ ។

## គុណសម្បត្តិនៃការធ្វើជាឧបជ្ឈាយ៍ដល់សិស្សពេញវ័យ[12]

គោលការណ៍ទាំងប្រាំពីរដែលផ្អែកលើគំនិតប៉ាន់ស្មានគ្រឹះត្រូវបានកត់ត្រានៅខាងក្រោម ។ គោលការណ៍នីមួយៗនឹងជួយសិក្ខាកាមឲ្យយល់អំពីលក្ខណៈសម្បត្តិរបស់សទ្ធិវិហារិក និងដើម្បីសម្របសម្រួលដល់ដំណើរការរៀនសូត្រ ។

### គោលការណ៍ទីមួយៈ

អ្នករៀនសូត្រដែលពេញវ័យត្រូវដឹងអំពី**មូលហេតុ** ។

[12] Adapted and condensed from The Adult Learner by Malcolm Knowles, Elwood Holton, and Richard Swanson (1990): 57–63.

ពិភពលោកតែងផ្លាស់ប្តូរជានិច្ច ធ្វើឲ្យសទ្ធិវិហារិកជួបនឹងកាលៈទេសៈថ្មីៗដែលទាមទារឲ្យមានការរៀនសូត្របន្ថែម ។ ក្នុងនាមជាមនុស្សពេញវ័យ ពួកគេនឹងចង់ដឹងអំពីមូលហេតុដែលពួកគេត្រូវរៀនអ្វីមួយ មុនពេលដែលពួកគេជ្រើសរើសចូលទៅក្នុងបទពិសោធន៍រៀនសូត្រថ្មីដែលនឹងបញ្ជ្រៀតចូលទៅក្នុងកាលវិភាគដ៏មមាញឹករបស់ពួកគេរួចទៅហើយ ។

**គុណសម្បត្តិ:** សទ្ធិវិហារិកចូលទៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ដោយមានការយល់ដឹងអំពីមូលហេតុដែលបទពិសោធន៍នេះចាំបាច់ ។

**សកម្មភាព:** ចូរសួរថា តើមានសិក្ខាកាមប៉ុន្មាននាក់សួរសំណួរថា៖ «ហេតុអ្វីបានជាខ្ញុំចង់រៀនការនេះ?» នៅពេលដែលពួកគេមកចូលរួមស្ថានភាពរៀនសូត្រថ្មី ។ តើការឆ្លើយសំណួរនោះជួយដល់ដំណើរការរៀនសូត្រយ៉ាងដូចម្តេច? តើការនោះសម្របសម្រួលដល់ទំនាក់ទំនងឧបជ្ឈាយ៍យ៉ាងដូចម្តេច?

នៅពេលដែលសិក្ខាកាមចាប់ផ្តើមធ្វើការជាមួយសទ្ធិវិហារិក សទ្ធិវិហារិកគួរតែស្គាល់មូលហេតុដែលពួកគេចង់ចម្រើនសមត្ថភាពដាំក្រុមជំនុំរបស់ពួកគេ ។ តើការបណ្តាលចិត្តរបស់ពួកគេអាចជាអ្វី?

**គោលការណ៍ទីពីរ:** សិស្សពេញវ័យ **មានភាពម្ចាស់ការ** និង**ស្វ័យដឹកនាំ** ។
មនុស្សពេញវ័យមើលឃើញខ្លួនគេមានស្វ័យដឹកនាំ ។ សទ្ធិវិហារិកនឹងមានគោលគំនិតខ្លួនឯងអំពីការទទួលខុសត្រូវសម្រាប់ការសម្រេចចិត្តរបស់ពួកគេ និងការដឹកនាំជីវិតរបស់ពួកគេ ។ នេះមានន័យថា ការប៉ុនប៉ងដាក់គំនិត ឬគោលគំនិតទៅលើសិស្សពេញវ័យទំនងជាជួបនឹងការប្រឆាំង ។ សិស្សពេញវ័យចូលចិត្តឲ្យគេគោរព និងចាត់ទុកខ្លួនថាជាដៃគូស្មើភាពនៅក្នុងបទពិសោធន៍រៀនសូត្រ ។

**គុណសម្បត្តិ:** សទ្ធិវិហារិកបានជ្រើសរើសដំណើរការប្រព្រឹត្តនេះជាជម្រើសដ៏ល្អបំផុតសម្រាប់ទទួលបានចំណេះដឹងដែលត្រូវការនៅពេលនេះ ។ នេះប្រាប់ដោយប្រយោលថា ទំនាក់ទំនងរវាងឧបជ្ឈាយ៍–សទ្ធិវិហារិក គឺជាទំនាក់ទំនងរវាងសហការីដែលរួមគ្នាសម្រេចគោលដៅរួម ដែលក្នុងនោះដៃគូម្នាក់មានបទពិសោធន៍ច្រើនជាងណែនាំដៃគូម្នាក់ទៀត ។

**សកម្មភាព:** ចូរសួរសិក្ខាកាមថា ជម្រើសវិជ្ជមាននេះនឹងមានឥទ្ធិពលយ៉ាងដូចម្តេចមកលើបទពិសោធន៍នៃការធ្វើជាឧបជ្ឈាយ៍ ។ ដោយឆ្លុះបញ្ចាំងនឹងការនេះ តើឧបជ្ឈាយ៍អាចធ្វើឲ្យប្រាកដបានយ៉ាងដូចម្តេចថា សទ្ធិវិហារិកទទួលបានជំនាញដែលត្រូវការសម្រាប់ព័ន្ធកិច្ច ដោយមិនបំពានលើភាពម្ចាស់ការ និងស្វ័យដឹកនាំរបស់គេ? តើមានចំណុចអវិជ្ជមានណាមួយដែរឬទេ ពាក់ព័ន្ធនឹងលក្ខណៈមួយនេះនៃការរៀនសូត្ររបស់មនុស្សពេញវ័យ? ប្រសិនបើមាន តើការនេះគួរតែត្រូវបានដោះស្រាយដូចម្តេច?

វាជាការសំខាន់ណាស់ដែលឧបជ្ឈាយ៍សុំសិទ្ធិវិហារិករបស់ពួកគេរកឲ្យឃើញអ្វីដែលពួកគេចង់រៀនបំផុត ជំនាញអ្វីដែលពួកគេចង់អភិវឌ្ឍ និងអត្តចរិតអ្វីខ្លះដែលពួកគេចង់កែប្រែ ។ ការផ្ដល់ឲ្យសិទ្ធិវិហារិកនូវបញ្ជីដែលមានជម្រើសផ្សេងៗ នោះអាចមានប្រយោជន៍ ។

**គោលការណ៍ទីបីៈ** សិស្សពេញវ័យ មានឃ្លាំង **បទពិសោធន៍** ដែលគេឆ្លងកាត់កន្លងមក ។
បទពិសោធន៍កាលពីមុនរបស់សិស្សផ្ដល់ធនធានដ៏សម្បូរបែបសម្រាប់ការរៀនសូត្រ ។ មនុស្សពេញវ័យមកចូលរួមសកម្មភាពរៀនសូត្រដោយនាំមកជាមួយនូវបទពិសោធន៍ល្អៗយ៉ាងច្រើនខុសពីកុមារ ។

**គុណសម្បត្តិៈ** បទពិសោធន៍របស់សិស្សពេញវ័យផ្ដល់គ្រឹះចំណេះដឹង ដែលគេអាចអនុវត្តទៅក្នុងកាលៈទេសៈបច្ចុប្បន្នបាន ។ បទពិសោធន៍ដែលប្រមូលបានក្នុងជីវិតជួយឲ្យសិស្សពេញវ័យអាចវាយតម្លៃ និងទទួលយកបទពិសោធន៍ និងព័ត៌មានថ្មីបាន ។ តាមរបៀបនេះ បទពិសោធន៍កាលពីមុនគឺជាឈ្នាន់នាំទៅរកការបំផ្លាស់បំប្រែរបស់សិទ្ធិវិហារិក ។

**សកម្មភាពៈ** ចូរសុំសិក្ខាកាមម្នាក់ ឬពីរនាក់ឲ្យប្រាប់អំពីរបៀបដែលបទពិសោធន៍ក្រៅព័ន្ធកិច្ច បានជួយពួកគេដោះស្រាយបញ្ហានៅក្នុងព័ន្ធកិច្ច ឬបានផ្លាស់ប្ដូរវិធីសាស្ត្រដោះស្រាយជាមួយមនុស្សរបស់ពួកគេនៅក្នុងព័ន្ធកិច្ច ។

វាមានប្រយោជន៍ដែលសិទ្ធិវិហារិកឆ្លុះបញ្ចាំងអំពីបទពិសោធន៍កាលពីមុននៅក្នុងជីវិត (ទាំងជោគជ័យ ទាំងបរាជ័យ) រៀនចេញពីបទពិសោធន៍ទាំងនោះ ចូរអរព្រះគុណដល់ព្រះសម្រាប់បទពិសោធន៍ទាំងនោះ ហើយសុំព្រះឲ្យប្រើបទពិសោធន៍ទាំងនោះដើម្បីឲ្យពរដល់អ្នកដទៃទៀតនៅពេលអនាគត ។

**គោលការណ៍ទីបួនៈ** សិស្សពេញវ័យ **ផ្ដោតលើបញ្ហា** ។
នៅពេលដែលមនុស្សពេញវ័យជួបប្រទះស្ថានភាពថ្មី ដែលពួកគេមិនអាចរកឃើញដំណោះស្រាយនៅក្នុងបទពិសោធន៍កាលពីមុនរបស់ពួកគេ ពួកគេផ្ដោតអារម្មណ៍លើការរកមើលរបៀបថ្មីៗ ដើម្បីដោះស្រាយការលំបាកនោះ ។ ការកែលម្អដំណើរការឧបជ្ឈាយ៍ដើម្បីដោះស្រាយបញ្ហា ដោយមានការយកចិត្តទុកដាក់ចំពោះសិទ្ធិវិហារិក នឹងបង្កើនតម្លៃរបស់ដំណើរការឧបជ្ឈាយ៍សម្រាប់ពួកគេ ។

**គុណសម្បត្តិៈ** បញ្ហា និងស្ថានភាពនៅក្នុងព័ន្ធកិច្ចផ្ដល់ការផ្ដោតអារម្មណ៍សម្រាប់បទពិសោធន៍រៀនសូត្រ ។ ឧបជ្ឈាយ៍ និងសិទ្ធិវិហារិកស្វែងរកដំណោះស្រាយជាក់ស្ដែង ជាជាងស្វែងយល់ទ្រឹស្ដីដែលប្រហែលជាត្រូវ ឬប្រហែលជាមិនត្រូវនឹងបញ្ហាបច្ចុប្បន្ន ។

**សកម្មភាពៈ** ចូរសុំសិក្ខាកាមឲ្យឆ្លុះបញ្ចាំងអំពីរបៀបដែលបទពិសោធន៍ផ្ទាល់ខ្លួនគេអាចជាឧបករណ៍សម្រាប់ជួយសិទ្ធិវិហារិករបស់ពួកគេស្វែងរកដំណោះស្រាយជាក់ស្ដែងសម្រាប់បញ្ហាដែលមានស្រាប់ ។

**គោលការណ៍ទីប្រាំៈ** អ្នករៀនសូត្រដែលពេញវ័យ **ត្រៀមខ្លួនរួចជាស្រេចដើម្បីរៀន** ។

ជាធម្មតា មនុស្សពេញវ័យត្រៀមខ្លួនរួចជាស្រេចដើម្បីរៀន ជាការឆ្លើយតបចំពោះស្ថានភាពដែលពួកគេមិនបាន ត្រៀមខ្លួន ។ ការនេះផ្តល់ជាមពលដែលត្រូវការដើម្បីរៀន និងអភិវឌ្ឍជំនាញថ្មីដែលជួយពួកគេឲ្យអាចដោះស្រាយ កាលៈទេសៈទាំងនោះយ៉ាងមានប្រសិទ្ធភាព ។

**គុណសម្បត្តិ:** សទ្ធិវិហារិកចូលទៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ដោយស្វែងរកចម្លើយសម្រាប់បញ្ហាដែលពួកគេបានរក ឃើញរួចទៅហើយ ។

**សកម្មភាព:** ចូរពន្យល់ថា សម្រាប់សទ្ធិវិហារិក នេះមានន័យថា បទពិសោធន៍រៀនសូត្រពាក់ព័ន្ធនឹងស្ថានភាពជីវិតពិត ប្រាកដ ដែលពួកគេខំប្រឹងប្រែងអភិវឌ្ឍជំនាញថ្មី និងសមត្ថភាពថ្មីដែលត្រូវការនៅក្នុងព័ន្ធកិច្ចរបស់ពួកគេ ឬការ ទទួលខុសត្រូវខាងសង្គមរបស់ពួកគេ ។ ចូរសួរសិក្ខាកាមអំពីរបៀបដែលធ្វើឲ្យភារកិច្ចនៃការធ្វើជាឧបជ្ឈាយ៍កាន់តែ ងាយស្រួល ។

**គោលការណ៍ទីប្រាំមួយ:** សិស្សពេញវ័យ**ផ្តោតលើជីវិត** ។

សម្រាប់សទ្ធិវិហារិក ការអប់រំគឺជាដំណើរការអភិវឌ្ឍកម្រិតសមត្ថភាពដើម្បីឈានទៅការសម្រេចសក្តានុពលពេញ លេញរបស់ពួកគេ ។ នេះផ្ទុយនឹងការតម្រង់ទិសដែលផ្តោតលើមុខវិជ្ជានៅក្នុងការរៀនសូត្របែបបុរាណ ។

**គុណសម្បត្តិ:** ក្នុងនាមជាសិស្សពេញវ័យ សទ្ធិវិហារិកផ្តោតលើភារកិច្ច ឬផ្តោតលើបញ្ហានៅក្នុងការតម្រង់ទិសរៀន សូត្ររបស់ពួកគេ ។ ពួកគេស្វែងរកចម្លើយសម្រាប់តថ:ភាពបច្ចុប្បន្ន ។ មានធាតុបន្ទាន់ជានិច្ច—អ្វីដែលបានរៀនថ្ងៃ នេះត្រូវតែអាចអនុវត្តបាននៅក្នុងស្ថានភាពបច្ចុប្បន្ន ។

**សកម្មភាព:** ចូរអនុញ្ញាតឲ្យសិក្ខាកាមម្នាក់ ឬពីរនាក់ផ្តល់យោបល់អំពីរបៀបដែលការអនុវត្តន៍គោលការណ៍នេះផ្លាស់ប្តូរ គោលគំនិតរបស់ពួកគេអំពីការធ្វើជាឧបជ្ឈាយ៍ ។

**គោលការណ៍ទីប្រាំពីរ:** សិស្សពេញវ័យ**ស្វ័យបណ្តាលចិត្ត** ។

នេះមានន័យថា ការបណ្តាលចិត្តរបស់សទ្ធិវិហារិកគឺមកពីខាងក្នុង ជាជាងមកពីខាងក្រៅ ។ ការរៀនសូត្រត្រូវបានឲ្យ តម្លៃនៅខាងក្នុងចិត្ត ដោយឆ្លុះបញ្ចាំងនឹងការឲ្យតម្លៃខ្លួន គុណភាពរបស់ជីវិត ភាពស្កប់ចិត្តនៅក្នុងការងារ និង/ឬ អារម្មណ៍ជោគជ័យ ។

**គុណសម្បត្តិ:** សទ្ធិវិហារិកប្រហែលជាឆ្លើយតបចំពោះប្រភេទនៃការបណ្តាលចិត្តពីខាងក្រៅមួយចំនួន ប៉ុន្តែអ្នកដែល បណ្តាលចិត្តដ៏មានឥទ្ធិពលបំផុតគឺជាសំពាធនៅខាងក្នុងដើម្បីសម្រេចគោលដៅរបស់ខ្លួន ។ ឧបជ្ឈាយ៍មិនត្រូវធ្វើជា អ្នកបណ្តាលចិត្តទេ ។

**សេចក្តីសង្ខេបគោលការណ៍ទាំងប្រាំពីរ**

នៅពេលដែលរៀបចំការហ្វឹកហ្វឺននេះ ចូរចងចាំសំណួរខាងក្រោមអំពីអ្វីដែលគោលការណ៍នីមួយៗបង្រៀនយើងអំពីសទ្ធិវិហារិកៈ (១) តើព័ត៌មាននេះផ្តល់សេចក្តីណែនាំសម្រាប់ដំណើរការឧបជ្ឈាយ៍ដូចម្តេច? (២) តើសិក្ខាកាមគួរតែទទួលយកព័ត៌មាននេះទៅក្នុងវិធីសាស្ត្រធ្វើជាឧបជ្ឈាយ៍របស់ពួកគេដូចម្តេច?

**សកម្មភាព:**
ចូរសួរសិក្ខាកាមអំពីរបៀបដែលអ្វីដែលពួកគេបានរៀនអំពីគរុកោសល្យសម្រាប់មនុស្សពេញវ័យ (ការជួយមនុស្សពេញវ័យរៀន) នឹងផ្លាស់ប្តូរវិធីសាស្ត្រធ្វើជាឧបជ្ឈាយ៍របស់ពួកគេ ។ ចូរឲ្យសិក្ខាកាមម្នាក់ៗរកអ្វីមួយឲ្យឃើញ ជាពិសេសចេញពីគោលការណ៍ទាំងប្រាំពីរនេះដែលគេចង់នឹកចាំ នៅពេលដែលកំពុងធ្វើការជាមួយសទ្ធិវិហារិក ។

## លក្ខណៈសម្បត្តិរបស់ឧបជ្ឈាយ៍ល្អ

**សកម្មភាព:**
ចូរចាប់ផ្តើមម៉ោងនេះ ដោយសុំអ្នកនៅក្នុងក្រុមឲ្យគិតត្រឡប់ទៅក្រោយវិញនៅក្នុងជីវិតរបស់ពួកគេទៅរកពេលមួយដែលមានអ្នកធ្វើជាឧបជ្ឈាយ៍ដល់ពួកគេ ។ តើបុគ្គលនេះជាឧបជ្ឈាយ៍ដ៏ល្អដែរឬទេ? ប្រសិនបើល្អ តើអ្វីបានធ្វើឲ្យបុគ្គលនេះក្លាយទៅជាឧបជ្ឈាយ៍ដ៏ល្អ? តើពួកគេគិតថា លក្ខណៈសម្បត្តិរបស់ឧបជ្ឈាយ៍ល្អមានអ្វីខ្លះ?

ឧបជ្ឈាយ៍ដ៏ល្អមានលក្ខណៈសម្បត្តិរួមដែលគួរឲ្យកត់សម្គាល់ជាច្រើន ។ នៅពេលដែលលោកអ្នកពិនិត្យមើលលក្ខណៈសម្បត្តិមួយចំនួននៅក្នុងចំណោមលក្ខណៈសម្បត្តិទាំងនេះ ចូរឲ្យសិក្ខាកាមឆ្លុះបញ្ចាំងលក្ខណៈសម្បត្តិទាំងនោះ ហើយសម្រេចថាតើពួកគេមានអារម្មណ៍ថា ពួកគេមានលក្ខណៈសម្បត្តិចាំបាច់ទាំងនេះដែរឬអត់ តាមការវាយតម្លៃផ្ទាល់ខ្លួនរបស់ពួកគេ ។

### ១. ឧបជ្ឈាយ៍ល្អ គឺជា**អ្នកស្តាប់ល្អ** ។

សុភាសិតមួយរបស់អេស្ប៉ាញនិយាយយ៉ាងនេះថា: «យើងត្រូវបានបង្កើតមកឲ្យមានត្រចៀកពីរ និងមាត់មួយប៉ុណ្ណោះ ។ ដូច្នេះហើយ យើងត្រូវស្តាប់ឲ្យបានច្រើនជាងយើងនិយាយពីរដង» ។ ឧបជ្ឈាយ៍ដ៏ល្អស្តាប់ច្រើនជាងនិយាយ ។ នៅពេលដែលពួកគេនិយាយ ពួកគេសួរសំណួរដើម្បីស្តាប់ឮចម្លើយពីសទ្ធិវិហារិករបស់ពួកគេ ។

អ្នកខ្លះបានហៅការស្តាប់បែបនេះថាការស្តាប់បែបអះអាង ។ អ្នកខ្លះទៀតហៅថាការស្តាប់បែបសកម្ម ។ នៅក្នុងការប្រើគុណនាមទាំងនេះ មានការសង្កត់ធ្ងន់ទៅលើអ្វីមួយដែលសកម្ម ។ នេះមិនមែនជាការស្តាប់បែបអកម្មដែលយើងកំពុងធ្វើការសន្ទនា ប៉ុន្តែមិនបានយកចិត្តទុកដាក់ចំពោះការឆ្លើយតបពីដៃគូរបស់យើងទេ ។ នៅក្នុងការស្តាប់បែបអកម្ម គំនិតរបស់យើងរសាត់អណ្តែតទៅរកអ្វីផ្សេង ឬទៅរកអ្វីដែលយើងចង់និយាយបន្ទាប់ទៀត ។ ប៉ុន្តែនៅក្នុងការស្តាប់បែបអះអាង ឬបែបសកម្ម យើងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះអ្វីដែលអ្នកដទៃទៀតកំពុងនិយាយ ។ យើងអានការប្រាស្រ័យទាក់ទងមិនតាមពាក្យសម្តីច្រើនដូចជាការប្រាស្រ័យទាក់ទងតាមពាក្យសម្តីរបស់ពួកគេដែរ ហើយប៉ុនប៉ងយល់អ្វីដែលពួកគេចង់មានន័យ មិនមែនគ្រាន់តែអ្វីដែលពួកគេកំពុងនិយាយទេ ។ អ្នកជំនាញខាងឧបជ្ឈាយ៍

ម្នាក់បានហៅការស្តាប់បែបនេះថា «ការចូលរួមយ៉ាងសកម្មជាមួយពិភពរបស់សិស្ស ហើយប៉ុនប៉ងមានបទពិសោធន៍ជាមួយការនោះចេញពីខាងក្នុងមក»[13] ។

**សកម្មភាព:**

១. ជាមួយអ្នកស្ម័គ្រចិត្តម្នាក់ពីក្នុងក្រុម ចូរធ្វើគំរូអំពីការស្តាប់អកម្ម និងការស្តាប់សកម្ម ។ ចូរឲ្យអ្នកស្ម័គ្រចិត្តនោះប្រាប់លោកអ្នកអំពីអ្វីដែលពួកគេបានធ្វើកាលពីសប្តាហ៍មុន ខណៈពេលនោះ លោកអ្នកបង្ហាញចេញការស្តាប់អកម្ម ដោយផ្លាស់ប្តូរប្រធានបទ និងមិនយកចិត្តទុកដាក់ចំពោះអ្វីដែលអ្នកស្ម័គ្រចិត្តនោះកំពុងប្រាប់លោកអ្នក រួចនិយាយអំពីអ្វីដែលលោកអ្នកបានធ្វើកាលពីចុងសប្តាហ៍ ។ បន្ទាប់មកទៀត ចូរធ្វើគំរូការស្តាប់សកម្ម ដោយឲ្យអ្នកស្ម័គ្រចិត្តនោះប្រាប់លោកអ្នកអំពីអ្វីដែលពួកគេនឹងធ្វើនៅថ្ងៃនេះ និងនៅថ្ងៃស្អែក សួរសំណួរទៅគេ ដើម្បីបញ្ជាក់ច្បាស់ពីអ្វីដែលគេកំពុងនិយាយ សួរគេអំពីរបៀបដែលគេយល់អំពីស្ថានភាព ឬសួរអំពីអារម្មណ៍ដែលគេមានអំពីអ្វីៗ ។ ចូរផ្តោតអារម្មណ៍លើការយល់ឲ្យកាន់តែច្បាស់អំពីអ្វីដែលអ្នកស្ម័គ្រចិត្តនោះកំពុងព្យាយាមប្រាប់ ។
២. ចូរសួរសិក្ខាកាមថាតើពួកគេធ្លាប់នៅក្នុងស្ថានភាពដែលពួកគេអាចដាក់ចេញផែនការដោយខ្លួនឯង ដើម្បីដោះស្រាយបញ្ហា ដោយគ្រាន់តែនិយាយអំពីស្ថានភាពរបស់ពួកគេប្រាប់អ្នកផ្សេងទៀតដែរឬអត់ ។ ចូរឲ្យសិក្ខាកាមចែកចាយបទពិសោធន៍របស់ពួកគេជាមួយមនុស្សម្នាក់ ឬពីរនាក់ដែលអង្គុយនៅជិតពួកគេ ។ ចូរទុកពេលឲ្យចែកចាយបានច្រើននាទី ។

ចូរពន្យល់ថា ក្រៅពីជួយយើងឲ្យយល់អំពីស្ថានភាពចេញពីទស្សនៈរបស់សិទ្ធិវិហារិករបស់យើងហើយនោះ ការធ្វើជាអ្នកស្តាប់ដ៏ល្អក៏ជួយសិទ្ធិវិហារិកឲ្យអាចត្រឡប់ជាអ្នកដោះស្រាយបញ្ហាបានផងដែរ ពេលដែលពួកគេនិយាយប្រាប់អំពីគំនិតរបស់ពួកគេ និងវាយតម្លៃដំណោះស្រាយដែលអាចមាន ។ ប្រសិនបើឧបជ្ឈាយ៍យកចិត្តទុកដាក់នឹងការនិយាយខ្លាំងជាងការស្តាប់ នោះសិទ្ធិវិហារិករបស់ពួកគេមិនអាចមានការរកឃើញទាំងនេះដោយខ្លួនឯងបានទេ ។ ការរកឃើញដោយខ្លួនឯងតែងតែមានតម្លៃខ្លាំងជាងដំណោះស្រាយដែលអ្នកផ្សេងទៀតផ្តល់ឲ្យ ។

២. ឧបជ្ឈាយ៍ដ៏ល្អដោះស្រាយកាលៈទេសៈ«**ត្រូវចំពេល**»នៅក្នុងជីវិត ។

នៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ យើងកំពុងដោះស្រាយជាមួយការល្អ និងការអាក្រក់នៅក្នុងជីវិត ជាមួយកាលៈទេសៈដែលសិទ្ធិវិហារិកកំពុងជួបប្រទះនៅពេលបច្ចុប្បន្ននេះ ។ ដូចជានៅក្នុងបរិបទផ្នែកអប់រំ «ការរៀនសូត្រត្រូវចំពេល»—គឺការចែកចាយអំពីអ្វីមួយនៅពេល«ដែលអាចបង្រៀនបាន»[14] មានប្រសិទ្ធភាពជាងការបង្រៀនដែលហាក់បីដូចជាមិនពាក់ព័ន្ធនឹងតថៈភាពជាក់ស្តែងនៅពេលបច្ចុប្បន្នរបស់សិទ្ធិវិហារិក ។ ចូររំឭកសិក្ខាកាមថា លក្ខណៈមួយក្នុងចំណោមលក្ខណៈរបស់សិស្សពេញវ័យគឺថា ពួកគេចង់ឲ្យអាចអនុវត្តភ្លាមៗអ្វីដែលពួកគេកំពុងរៀន ។ សេចក្តីតែមួយ

[13] Daloz, *Effective Teaching and Mentoring*, 205.

[14] Havighurst, *Developmental Tasks and Education*, page unknown.

នេះពិតដូចគ្នានៅក្នុង**ការ**ធ្វើជាឧបជ្ឈាយ៍ ។ **ការ**ធ្វើជាឧបជ្ឈាយ៍ត្រូវតែផ្លុះបញ្ចាំងតថ:ភាពបច្ចុប្បន្ន មិនមែនស្ថានភាពដែលនៅឆ្ងាយទេ លើកលែងតែនិយាយអំពីនិមិត្តដែលមានលក្ខណៈផ្តោតលើអនាគត ។ ទោះបីយ៉ាងណាក៏ដោយ មានស្ថានភាពបច្ចុប្បន្នដែលអាចត្រូវបានពិភាក្សា ។ អ្នកឯកទេសខាងឧបជ្ឈាយ៍ម្នាក់សរសេរថា៖ «ឧបជ្ឈាយ៍ដ៏ល្អជួយធ្វើឲ្យសេចក្តីសន្យាអំពីអនាគតកាលនៅនឹងថ្កល់»[15] ។

**សកម្មភាព:** ចូរសុំសិក្ខាកាមជាច្រើនដែលមានបទពិសោធន៍ជាមួយនឹង**ការ**រៀនត្រូវចំពេល ឲ្យចែកចាយអំពី**ការ**នេះប្រាប់ក្រុម ។ ចូរស្វែងយល់បន្ថែមជាមួយនឹងសំណួរផ្សេងៗទៀត ដូចជាសំណួរទាំងនេះ:

- តើ**ការ**រៀនរបស់លោកអ្នកនៅក្នុងករណីនេះខុសពីបទពិសោធន៍រៀនមួយចំនួនទៀតរបស់លោកអ្នកយ៉ាងដូចម្តេច?
- តើលោកអ្នកគិតថា ក្នុងនាមជាមនុស្សពេញវ័យ យើងរៀនបានច្រើន និងចាប់បាន**ការ**រៀននោះ នៅពេលដែលវាត្រូវចំពេលដែរឬទេ?
- តើលោកអ្នកមើលឃើញខ្លួនឯងអនុវត្ត**ការ**រៀននេះទៅក្នុង**ការ**ធ្វើជាឧបជ្ឈាយ៍របស់លោកអ្នកនៅពេលអនាគតយ៉ាងដូចម្តេច?

៣. ឧបជ្ឈាយ៍ដ៏ល្អគឺប្រៀបបីដូចជា**ឆ្នប** ។

**សកម្មភាព:**
ចូរសួរសិក្ខាកាមថា តើឆ្នបមានតួនាទីជាអ្វី

បន្ទាប់មក ចូរពន្យល់ថា ឧបជ្ឈាយ៍ធ្វើដូចជាឆ្នប ដោយជួយ«មនុស្សដទៃទៀត»សម្រាលចេញគំនិតថ្មី ជំនាញថ្មី **ការ**ប្រៀបធៀបថ្មី និងវិធីថ្មីនៅក្នុង**ការ**ធ្វើជា និងធ្វើ ។ ពួកគេជួយអ្នករៀនសូត្រនៅក្នុង**ការ**សម្រាលចេញគំនិត និមិត្ត និងគោលដៅរបស់ខ្លួនគេផ្ទាល់»[16] ។ ចូរឲ្យសិក្ខាកាមមានឱកាសពន្យល់អំពីមូលហេតុដែលសទ្ធិវិហារិកត្រូវតែមានគំនិតថ្មីៗ និមិត្តថ្មីៗ និងគោលដៅថ្មីៗ ។

៤. ឧបជ្ឈាយ៍ដ៏ល្អជួយសទ្ធិវិហារិកមើលឃើញ**ជម្រើសផ្សេងៗ** ។

នៅពេលដែលប្រឈមមុខជាមួយនឹងស្ថានភាពដ៏លំបាក មនុស្សអាច«ជាប់គាំង» ហើយមើលឃើញដំណោះស្រាយតែមួយ លទ្ធផលតែមួយ និងដំណើរសកម្មភាពតែមួយប៉ុណ្ណោះ ។ នៅពេលដែលសទ្ធិវិហារិកពិភាក្សាបញ្ហាជាមួយឧបជ្ឈាយ៍របស់ពួកគេ ឧបជ្ឈាយ៍អាចជួយពួកគេមើលឃើញជម្រើសដទៃទៀត ។ ពួកគេចាប់ផ្តើមមើលឃើញថា អាចមានដំណោះស្រាយដែលពួកគេមិនបានពិចារណា ហើយពួកគេត្រូវបានណែនាំឲ្យគិតជ្រៅ និងបែបផ្សេង ។ **ការ**បំផុស

[15] Sharon D. Parks, *Big Questions, Worthy Dreams: Mentoring Emerging Adults in Their Search for Meaning, Purpose, and Faith*, 1st ed. (San Francisco: Jossey-Bass Inc., 2000): 128.

[16] Vogel, "Reckoning with the Spiritual Lives of Adult Learners," 24.

គំនិតថ្មីៗអាចកើតឡើងបាន ។ ការដែលមនុស្សបាច់ពីរនាក់ឡើងសហការគ្នាដោះស្រាយស្ថានភាពមួយនោះអាចនាំមកនូវគំនិតឆ្នៃប្រឌិត និងវិធីថ្មីៗនៅក្នុងការគិត ឬធ្វើកិច្ចការផ្សេងៗ ។

**សកម្មភាព:**

- ប្រសិនបើអាចធ្វើបាន ចូរឲ្យឧទាហរណ៍មួយចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកអ្នក ដែលលោកអ្នកត្រូវបានណែនាំឲ្យមើលឃើញជម្រើសផ្សេងៗ ។ បន្ទាប់មក ចូរសុំសិក្ខាកាមឲ្យចែកចាយឧទាហរណ៍ផ្ទាល់ខ្លួនគេមួយចំនួនអំពីការនេះ ។
- ចូរសុំសិក្ខាកាមឲ្យរកឃើញប្រភេទស្ថានភាពដែលសទ្ធិវិហារិកប្រហែលជាត្រូវការជំនួយ ដើម្បីមើលឃើញជម្រើសផ្សេងៗ ។
- ចូរឲ្យសិក្ខាកាមផ្តល់យោបល់អំពីវិធីជួយសទ្ធិវិហារិកពិចារណាដំណោះស្រាយផ្សេងៗ ដូចជាឲ្យសទ្ធិវិហារិកធ្វើបញ្ជីកត់ត្រាជម្រើសយ៉ាងតិចណាស់បីសម្រាប់ដោះស្រាយបញ្ហាមួយ ។ ឧបជ្ឈាយ៍អាចជួយសទ្ធិវិហារិកស្វែងយល់អំពីលទ្ធផលដែលអាចកើតមានរបស់ជម្រើសនីមួយៗ ដោយសួរថា៖ «ប្រសិនបើអ្នកធ្វើកិច្ចការនេះ តើនឹងមានអ្វីកើតឡើង? » ។

៥. ឧបជ្ឈាយ៍ដ៏ល្អគឺជា**អ្នកលើកទឹកចិត្ត** ។

យើងត្រូវការអ្នកដែលជឿលើយើង ។ យើងត្រូវការបាណាបាសដែលអាចលើកទឹកចិត្តយើង នៅពេលដែលយើងបាក់ទឹកចិត្ត និងមានអារម្មណ៍ដូចជាបរាជ័យនៅក្នុងព័ន្ធកិច្ច ។

**សកម្មភាព:**

តើនរណាបានលើកទឹកចិត្តលោកអ្នកនៅក្នុងការដើរខាងវិញ្ញាណរបស់លោកអ្នក? ប្រសិនបើលោកអ្នកអាចប្រាប់ឈ្មោះអ្នកនោះបាន ចូរប្រាប់សិក្ខាកាមអំពីបុគ្គលនេះ និងរបៀបដែលពួកគេបានលើកទឹកចិត្តលោកអ្នក ។ បន្ទាប់មក ចូរចែកសិក្ខាកាមទៅជាក្រុមតូចដែលមានគ្នា ៣–៥ នាក់ និងឲ្យពេលពួកគេចែកចាយអំពី«អ្នកលើកទឹកចិត្ត»ពួកគេដល់គ្នាទៅវិញទៅមក ។ ចូរសុំសិក្ខាកាមម្នាក់ ឬពីរនាក់ឲ្យចែកចាយប្រាប់ក្រុមទាំងមូល ។

៦. ឧបជ្ឈាយ៍ដ៏ល្អគឺជា**អ្នកគិតបែបត្រិះរិះពិចារណា** ។

ក្នុងនាមជាឧបជ្ឈាយ៍ យើងត្រូវជួយសទ្ធិវិហារិកឲ្យគិតបែបត្រិះរិះពិចារណា និងបែបវិភាគ—បញ្ហាជាច្រើនមិនស្រួលសម្រេចថាខុស ឬត្រូវទេ ។ នៅពេលដែលឧបជ្ឈាយ៍ឈោងចាប់ដំណោះស្រាយ ពួកគេត្រូវវិភាគស្ថានភាពបច្ចុប្បន្ន ដើម្បីជួយសទ្ធិវិហារិករបស់ពួកគេឆ្លងផុតស្ថានភាពនោះ ។ ឧបជ្ឈាយ៍ដ៏ល្អជួយសទ្ធិវិហារិកឲ្យ...

- រកឲ្យឃើញព័ត៌មានសំខាន់អំពីស្ថានភាព រួមទាំងប្រវត្តិ (នេះដាក់បញ្ចូលការយល់ដឹងអំពីភាពស្វាហាប់នៃការដាំក្រុមជំនុំ) ។
- ចូរឆ្លុះបញ្ចាំងអំពីស្ថានភាពដោយឥតលម្អៀង ។

- ចូររកឲ្យឃើញគំនិតប៉ាន់ស្មានរបស់ខ្លួនគេផ្ទាល់ ។
- ចូរពិចារណាទស្សនៈរបស់មនុស្សដទៃទៀត ។
- ចូរពិចារណាឥទ្ធិពលរបស់បរិបទខាងវប្បធម៌មកលើមនុស្សដែលពួកគេបម្រើ ។

**សកម្មភាព:**

ចូរឲ្យពេលសិក្ខាកាម ៥ នាទី ដើម្បីឆ្លុះបញ្ចាំងរៀងខ្លួនអំពីលក្ខណៈសម្បត្តិទាំងនេះ ។ បន្ទាប់មក ចូរសុំពួកគេឲ្យបែកទៅជាក្រុមដែលមានគ្នា ២ ឬ ៣ នាក់ ដោយប្រើពេល ១០–១៥ នាទី ចែកចាយប្រាប់គ្នាទៅវិញទៅមកអំពីលក្ខណៈណាខ្លះដែលពួកគេមាន និងលក្ខណៈណាខ្លះដែលពួកគេមានអារម្មណ៍ថាត្រូវអភិវឌ្ឍ ដើម្បីក្លាយជាឧបជ្ឈាយ៍ដ៏ល្អ ។

## អ្វីដែលត្រូវចៀសវាង

ផ្នែកនេះអាចត្រូវបានហៅថា «លក្ខណៈសម្បត្តិរបស់ឧបជ្ឈាយ៍ដែលអាក្រក់» ។ ចូរពិនិត្យមើលបញ្ជីខាងក្រោមឡើងវិញដោយសង្ខេបជាមួយនឹងសិក្ខាកាម ដោយកុំចំណាយពេលច្រើនពេកលើបញ្ជីនេះ លើកលែងតែមាននរណាម្នាក់នៅក្នុងក្រុមចង់ចូលជ្រៅជាងនេះ (កំណត់សម្គាល់: សម្រាប់ការពណ៌នាពេញលេញអំពីលក្ខណៈនិមួយៗក្នុងចំណោមលក្ខណៈទាំងនេះ សូមមើលជំពូក ៧ នៅក្នុងសៀវភៅដែលមានចំណងជើងថា ភាពស្ទាត់ជំនាញនៅក្នុងការធ្វើជាឧបជ្ឈាយ៍[17]) ។

ឲ្យដំបូន្មានបែបសេរីខ្លាំងពេក

- ការរិះគន់: ការរិះគន់ដែលបំផ្លាញការស្ទួរចង់ដឹង ។
- ជួយសង្គ្រោះ: យើងរៀនចេញពីកំហុសរបស់យើង ច្រើនជាងយើងរៀននៅពេលដែលយើងមិនទាន់មានកំហុស ។
- សង់របាំងដែលមិនចាំបាច់: ជាញឹកញាប់ ក្នុងនាមជាឧបជ្ឈាយ៍ យើងខ្លាចថា សិទ្ធិវិហារិករបស់យើងនឹងរំលងយើង ដូច្នេះយើងដាក់របាំងដោយអចេតនារារាំងដល់ការរីកចម្រើនតទៅទៀតរបស់ពួកគេ ។
- ព្រងើយកន្តើយនឹងពាក្យ «ហេតុអ្វី» ។ ជានិច្ចកាល តែងមានមូលហេតុនៅពីក្រោយគ្រប់ការទាំងអស់ ។
- មិនឲ្យតម្លៃ: វាអាក្រក់ខ្លាំងណាស់ដែលមិនទទួលយកអ្វីដែលសិទ្ធិវិហារិកប្រាប់យើង ។ អ្វីដែលអាចជាភ្នំសម្រាប់គាត់ មិនមែនជាអ្វីសោះសម្រាប់យើង ប៉ុន្តែការខកខានមិនបានដោះស្រាយជាមួយភ្នំនោះ គឺមិនឲ្យតម្លៃសិទ្ធិវិហារិក ។

អាកប្បកិរិយាទាំងប្រាំមួយនេះអាចត្រូវបានរកឃើញនៅក្នុងឧបជ្ឈាយ៍«ដែលនាំឲ្យពុល» ។ ពួកគេកាត់បន្ថយការរៀនដែលអាចកើតឡើងនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ មុនពេលដែលចាប់ផ្តើមផង ។

[17] Osterhouse and Teja, *Masterful Mentoring*.

**សកម្មភាពៈ**

១. ចូរឲ្យសិក្ខាកាមពណ៌នាអំពីអាកប្បកិរិយាខាងលើតាមពាក្យរបស់ខ្លួន ។
២. ចូរសុំសិក្ខាកាមឲ្យរកឃើញអាកប្បកិរិយាណាខ្លះដែលពួកគេកំពុងមានគ្រោះថ្នាក់បំផុត នៅក្នុងការបង្ហាញចេញ និងហេតុអ្វី ។ ចូរពិភាក្សាអំពីរបៀបដែលឧបដ្ឋាយ៍អាចចៀសវាង ឬ«បោះបោល»អាកប្បកិរិយាទាំងនេះបាន ។

## សេចក្តីត្រូវការរបស់សទ្ធិវិហារិក

នៅក្នុងម៉ោងនេះ យើងនឹងពិភាក្សាអំពីសេចក្តីត្រូវការពីរប្រភេទរបស់សទ្ធិវិហារិកៈ **សេចក្តីត្រូវការផ្នែកទំនាក់ទំនង** និង**សេចក្តីត្រូវការផ្នែករៀនសូត្រ** ។

**សេចក្តីត្រូវការផ្នែកទំនាក់ទំនង**

សេចក្តីត្រូវការផ្នែកទំនាក់ទំនងរបស់សទ្ធិវិហារិកមានបីផ្នែកធំៗៈ ការដើររបស់ពួកគេជាមួយព្រះ ទំនាក់ទំនងរបស់ពួកគេជាមួយគ្រួសារ និងទំនាក់ទំនងរបស់ពួកគេជាមួយព័ន្ធកិច្ចដាំក្រុមជំនុំ ។

លំដាប់លំដោយអាទិភាពរបស់សទ្ធិវិហារិក គួរតែជីវិតខាងវិញ្ញាណរបស់ពួកគេជាទីមួយ ជីវិតគ្រួសាររបស់ពួកគេជាទីពីរ និងព័ន្ធកិច្ចរបស់ពួកគេចុងក្រោយបង្អស់ ។ តើរបៀបដែលយើងចំណាយពេល លុយ និងធនធានប្រាប់អំពីអាទិភាពរបស់យើងដូចម្តេច? តើរបៀបដែលយើងដោះស្រាយបញ្ហា និងធ្វើការសម្រេចចិត្ត ឆ្លុះបញ្ចាំងឲ្យឃើញពីអាទិភាពរបស់យើងដោយវិធីណា?

**សកម្មភាពៈ**

ចូរសុំសិក្ខាកាមឲ្យផ្តល់យោបល់អំពីផ្នែកដែលសទ្ធិវិហារិកប្រហែលជាត្រូវការការណែនាំ ។ ចូរចែកសិក្ខាកាមទៅជាក្រុមដែលមានគ្នា ២-៤ នាក់ និងឲ្យពេលក្រុមប្រហែល ១០ នាទី ដើម្បីពិភាក្សាការនេះ និងកត់ត្រាគំនិតរបស់ពួកគេ ។

បន្ទាប់មក ចូរសុំក្រុមឲ្យចែកចាយចម្លើយមួយចំនួនរបស់ពួកគេជាមួយសិស្សទាំងអស់ ។ ចូរសរសេរយោបល់ទាំងនោះនៅលើក្តារខៀន ឬផ្ទាំងក្រដាសធំមួយសន្លឹក ។ បន្ទាប់មក ជាក្រុម ចូរកំណត់ថា ចម្លើយណាខ្លះក្នុងចំណោមចម្លើយទាំងនេះពាក់ព័ន្ធនឹងផ្នែកព្រះ គ្រួសារ និង/ឬ ព័ន្ធកិច្ច ។ ចូរដាក់អក្សរ ព្រ នៅពីមុខចម្លើយដែលនិយាយអំពីសេចក្តីត្រូវការរបស់យើងសម្រាប់ទំនាក់ទំនងជាមួយព្រះ គ សម្រាប់គ្រួសារ និង ព សម្រាប់ព័ន្ធកិច្ច ។ ចូរសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការដាក់ព្រះជាទីមួយ គ្រួសារទីពីរ និងព័ន្ធកិច្ចនៅក្រោយ ។

**សកម្មភាពៈ**

១. `ចូរសួរសិក្ខាកាមថាហេតុអ្វីបានជាសំខាន់ ដែលសទ្ធិវិហារិកត្រូវកំណត់លំដាប់លំដោយអាទិភាពរបស់ពួកគេដោយដាក់ព្រះជាទីមួយ គ្រួសារទីពីរ និងព័ន្ធកិច្ចក្រោយគេ ។

២. ចូរសុំសិក្ខាកាមឲ្យចំណាយពេលពីរបីនាទីផ្ទះបញ្ជាំងដោយស្ងៀមស្ងាត់អំពីជីវិតរបស់ពួកគេ និងស្តាប់អ្វីដែលព្រះកំពុងមានបន្ទូលមកកាន់ពួកគេអំពីអាទិភាពផ្ទាល់ខ្លួនរបស់ពួកគេ ។ តើពួកគេពិតជាដាក់ព្រះទីមួយ គ្រួសារទីពីរ និងព័ន្ធកិច្ចទីបីមែនឬ? ចូរអញ្ជើញពួកគេឲ្យគិតអំពីភស្តុតាងសម្រាប់អាទិភាពរបស់ពួកគេ ។ តើរបៀបដែលយើងចំណាយពេល លុយ និងធនធានប្រាប់អំពីអាទិភាពរបស់យើងយ៉ាងដូចម្តេច? តើរបៀបដែលយើងដោះស្រាយបញ្ហា និងធ្វើការសម្រេចចិត្តឆ្លុះបញ្ជាំងឲ្យឃើញពីអាទិភាពរបស់យើងយ៉ាងដូចម្តេច?

៣. ចូរអញ្ជើញសិក្ខាកាមឲ្យចែកចាយប្រាប់ដៃគូអំពីអ្វីដែលពួកគេបានរកឃើញអំពីអាទិភាពរបស់ខ្លួន និងរកឲ្យឃើញអ្វីដែលពួកគេត្រូវធ្វើ ដើម្បីរក្សាអាទិភាពរបស់ពួកគេឲ្យនៅតែត្រឹមត្រូវ ឬការផ្លាស់ប្តូរមួយដែលពួកគេត្រូវធ្វើ ដើម្បីកែសម្រួលអាទិភាពរបស់ពួកគេ ។

**សេចក្តីត្រូវការផ្នែករៀនសូត្រ:**

សេចក្តីត្រូវការផ្នែករៀនសូត្ររបស់សទ្ធិវិហារិក ក៏មានបីជងដែរ: ចំណេះដឹង ការយល់ដឹង និងជំនាញ ។ និយាយបានម្យ៉ាងទៀតថា សទ្ធិវិហារិកក្នុងនាមជាអ្នករៀនសូត្រត្រូវការចំណេះដឹងជាមូលដ្ឋានគ្រឹះមួយចំនួន ។ ពួកគេត្រូវយល់អំពីតម្លៃរបស់ការរៀនសូត្រនោះ និងអនុវត្តការរៀនសូត្រនោះនៅកន្លែងណាដែលអាចធ្វើបាន ។ ជាចុងក្រោយពួកគេត្រូវអភិវឌ្ឍជំនាញព័ន្ធកិច្ចរបស់ពួកគេ ។ ឧបជ្ឈាយ៍អាចជួយសទ្ធិវិហារិកនៅក្នុងផ្នែកទាំងបីនេះបាន ។

**សកម្មភាព:**

ចូរសុំក្រុមឲ្យកត់ត្រាយ៉ាងតិចឲ្យបានឧទាហរណ៍ពីរអំពីសេចក្តីត្រូវការនីមួយៗនៅក្នុងចំណោមសេចក្តីត្រូវការផ្នែករៀនសូត្រទាំងនេះរបស់សទ្ធិវិហារិក ។ ចូរកត់ត្រាឧទាហរណ៍ទាំងនោះនៅលើក្តារខៀន ឬនៅលើផ្ទាំងក្រដាសធំមួយ ។ នៅក្នុងផ្នែកចំណេះដឹង សេចក្តីត្រូវការផ្នែករៀនសូត្រនឹងត្រូវបានកំណត់ភាគច្រើនដោយការហ្វឹកហ្វឺនដែលពួកគេកំពុងឆ្លងកាត់នៅក្នុងម៉ូឌុល ។ អំពីការយល់ដឹង ឧទាហរណ៍ តើពួកគេឲ្យតម្លៃអំពីសេចក្តីត្រូវការឲ្យមាននិមិត្ត ឬសរសេរសេចក្តីថ្លែងការណ៍បេសកកម្មយ៉ាងដូចម្តេច? រីឯជំនាញវិញ តើពួកគេអាចប្រាប់និមិត្តរបស់ខ្លួនដល់អ្នកដទៃតាមរបៀបមួយដែលច្បាស់លាស់ដែរឬទេ? តើពួកគេអាច«លក់និមិត្ត»ដល់មនុស្សមួយក្រុមបានដែរឬទេ?

## ការទុកចិត្ត និងរឿងសម្ងាត់

ទំនាក់ទំនងឧបជ្ឈាយ៍ត្រូវបានសង់ឡើងនៅលើការទុកចិត្ត និងការរក្សារឿងសម្ងាត់ ។ ប្រសិនបើបាត់គុណតម្លៃណាមួយ ក្នុងចំណោមគុណតម្លៃទាំងពីរនេះ នោះទំនាក់ទំនងនឹងរាក់កំផែល ហើយជារឿងបរាជ័យអាក្រក់បំផុត ។

**សកម្មភាព:** ចូរសួរសិក្ខាកាមថា តើពាក្យ ទុកចិត្ត និងរឿងសម្ងាត់ មានន័យដូចម្តេចចំពោះពួកគេ ។ បន្ទាប់មក ចូរសួរពួកគេអំពីមូលហេតុដែលចំណុចទាំងពីរនេះសំខាន់ចំពោះទំនាក់ទំនងឧបជ្ឈាយ៍ដែលមានសុខភាពល្អ ។

នៅក្នុងមេរៀននេះ យើងនឹងពិភាក្សាមុនគេបង្អស់អំពីកិច្ចការដែលត្រូវធ្វើ និងកិច្ចការដែលមិនត្រូវធ្វើនៅក្នុងផ្នែកទំនាក់ទំនង និងផ្នែកជំនាញដែលនឹងជួយសង់ការទុកចិត្ត និងទំនុកចិត្តនៅក្នុងទំនាក់ទំនងឧបជ្ឈាយ៍ ។ ក្រោយមកយើងនឹងពិភាក្សាអំពីរឿងសម្ងាត់ ។

# កិច្ចការដែលត្រូវធ្វើ និងដែលមិនត្រូវធ្វើនៅក្នុងទំនាក់ទំនង

## ១. គោរព: កុំមើលងាយ

ឧបជ្ឈាយ៍ត្រូវគោរពសិទ្ធិវិហារិករបស់ខ្លួន ដោយអនុញ្ញាតឲ្យពួកគេស្មោះត្រង់ និងមានតម្លាភាព ទាំងមិនមានការភ័យខ្លាចថាត្រូវបានមើលងាយឡើយ ។ ឧបជ្ឈាយ៍ត្រូវយកចិត្តទុកដាក់ចំពោះអារម្មណ៍របស់សិទ្ធិវិហារិក បទពិសោធន៍ និងការខិតខំប្រឹងប្រែងរបស់ពួកគេ ព្រមទាំងបញ្ជាក់អ្វីដែលល្អ រួចកែតម្រង់ដោយសុភាព និងដោយគោរព ។

## ២. ឲ្យតម្លៃ: កុំបន្ថោក

គ្រប់គ្នាចង់ទទួលបានការឲ្យតម្លៃជាមនុស្ស ។ ឧបជ្ឈាយ៍មិនត្រូវដឹកនាំត្រួតត្រាលើសិទ្ធិវិហារិករបស់ខ្លួន ក៏មិនគួរចង្អុលម្រាមដៃដាក់សិទ្ធិវិហារិកអំពីផ្នែកទាំងឡាយដែលត្រូវការការអភិវឌ្ឍន៍ដែរ ផ្ទុយទៅវិញ ពួកគេត្រូវឲ្យតម្លៃសិទ្ធិវិហារិករបស់ពួកគេជាមនុស្ស ។

### សកម្មភាព:

ចូរឲ្យសិក្ខាកាមមើលកាឡាទី ៥:១៣ អេភេសូរ ៥:២១ និងរ៉ូម ១២:១០ ហើយពិភាក្សាអំពីរបៀបដែលខគម្ពីរទាំងនេះពាក់ព័ន្ធនឹងចំណុចនេះ ។

## ៣. ធ្វើគំរូ: កុំជ្រៀតជ្រែក

ព្រះយេស៊ូបានធ្វើគំរូអំពីព័ន្ធកិច្ច និងអត្តចរិតសម្រាប់ពួកសិស្សរបស់ព្រះអង្គ ហើយឧបជ្ឈាយ៍ ក៏ត្រូវធ្វើដូចគ្នា ។ ពួកគេក៏ត្រូវចៀសវាងការជ្រៀតជ្រែក ចូលក្នុងកិច្ចការរបស់សិទ្ធិវិហារិក ក្នុងផ្នែកដែលពួកគេមិនបានអញ្ជើញឲ្យជួយនោះដែរ ។

## ៤. បញ្ជាក់អះអាង: កុំចោទប្រកាន់

ចូរទទួលស្គាល់ពេលដែលសិទ្ធិវិហារិកធ្វើអ្វីមួយបានល្អ និងបញ្ជាក់អះអាងសកម្មភាពរបស់ពួកគេ ។

### សកម្មភាព:

ចូរឲ្យសិក្ខាកាមអានព្វបទគម្ពីរដូចតទៅ: រ៉ូម ១៤:១៣ រ៉ូម ១៥:៧ និងអេភេសូរ ៤:៣២ ។ ចូរសុំពួកគេឲ្យពន្យល់អំពីរបៀបដែលបទគម្ពីរទាំងនេះពាក់ព័ន្ធនឹងការបញ្ជាក់អះអាង មិនមែនការចោទប្រកាន់ ។

## ៥. លើកទឹកចិត្ត: កុំបំបាក់ទឹកចិត្ត

ចូររំឭកសិក្ខាកាមថា ឧបជ្ឈាយ៍អាចជាជំនួយ ឬជាឧបសគ្គដល់សិទ្ធិវិហារិករបស់ពួកគេ ។

### សកម្មភាព:

ចូរអាន ១ ថែស្សាឡូនីច ៥:១១ ជាមួយសិក្ខាកាម ។ ចូរសុំសិក្ខាកាមឲ្យគិតរកបទគម្ពីរពាក់ព័ន្ធដទៃទៀត ។

### ៦. ជំរុញចិត្តៈ កុំបន្ទោក

ឧបជ្ឈាយ៍គួរតែប្រាប់សទ្ធិវិហារិករបស់ពួកគេថា «អ្នកអាចធ្វើកិច្ចការនេះបាន!» ឲ្យបានញឹកញាប់ច្រើន ជាជាងប្រាប់ពួកគេថា «ហ៊ឺ...មើលទៅអ្នកដូចជាមិនអាចទៅរួច» ។

### សកម្មភាពៈ

ចូរសួរថាតើសិក្ខាកាមធ្លាប់ស្គាល់អ្នកមើលស្រាលខ្លួនឯងដែរឬអត់ ជាអ្នកដែលតែងតែទម្លាក់ខ្លួនឯងចុះ ឬប្រាប់ដោយប្រយោលថា ពួកគេនឹងបរាជ័យគ្រប់កិច្ចការដែលពួកគេធ្វើ ។ តើការនេះមានអារម្មណ៍យ៉ាងដូចម្ដេច? តើ«ជំបូន្មាន» នេះបានលើកទឹកចិត្តពួកគេឲ្យសាកល្បង ឬតើជំបូន្មាននេះបានបំបាក់ទឹកចិត្តពួកគេ? តើមានអ្វីកើតឡើង នៅពេលដែលមនុស្សត្រូវបានទម្លាក់ចុះជាជរាប?

### ៧. អធិស្ឋានៈ កុំធ្វើជាអាណាព្យាបាល

លោកប៉ុលប្រាប់គ្រិស្តបរិស័ទនៅក្រុងភីលីពថាៈ «ចូរបាត់ទុកគេប្រសើរជាងខ្លួន» (ភីលីព ២:៣) ។ ធ្វើជាអាណាព្យាបាល មានន័យថាធ្វើជាអ្នកមានអំណាចជាង ឬប្រព្រឹត្តចំពោះមនុស្សម្នាក់ទៀត តាមរបៀបដែលមានអំណាចជាង ។ នោះជាទំនោរដែលគិតថាខ្លួនឯងប្រសើរជាងអ្នកដទៃ ។

### សកម្មភាពៈ

ចូរសួរសិក្ខាកាមអំពីរបៀបដែលការអធិស្ឋានអាចការពារឧបជ្ឈាយ៍មិនឲ្យក្លាយជាអាណាព្យាបាលចំពោះសទ្ធិវិហារិករបស់ពួកគេ ។

## កិច្ចការជំនាញដែលត្រូវធ្វើ និងដែលមិនត្រូវធ្វើ

### ១. ស្ដាប់ៈ កុំនិយាយ

ចូរចងចាំថា មនុស្សមានត្រចៀកពីរ និងមាត់តែមួយប៉ុណ្ណោះ ។ តើការនោះប្រាប់យ៉ាងដូចម្ដេចអំពីទំនាក់ទំនងឧបជ្ឈាយ៍?

### សកម្មភាពៈ

ចូរសួរសិក្ខាកាមថា ការអប់រំរបស់ពួកគេរៀនបានច្រើនប៉ុន្មានជាមួយនឹងគ្រូដែលនិយាយម្នាក់ឯងរហូត ។ តើពួកគេត្រូវបានលើកទឹកចិត្តឲ្យគិតដោយខ្លួនឯង ឬគ្រាន់តែថាតាមអ្វីដែលគ្រូបាននិយាយ? តើនេះគឺជាការរៀនពិតប្រាកដ ឬតើនេះគឺជា«ការប្រាប់»ដោយគ្មានលទ្ធផលយូរអង្វែង?

### ២. សួរៈ កុំប្រាប់

តើឧបជ្ឈាយ៍អាចសង្កេតដឹងអ្វីដែលសទ្ធិវិហារិករបស់ពួកគេត្រូវការបានយ៉ាងដូចម្តេច ប្រសិនបើសទ្ធិវិហារិកគ្រាន់តែស្តាប់ឧបជ្ឈាយ៍និយាយនោះ? ឧបជ្ឈាយ៍គួរតែសួរសំណួរឲ្យបានច្រើនជាងពួកគេឲ្យចម្លើយ ។ ការរកឃើញដោយខ្លួនឯងកើតឡើង នៅពេលដែលឧបជ្ឈាយ៍សួរសំណួរដល់សទ្ធិវិហារិករបស់ពួកគេ មិនមែនប្រាប់ពួកគេពីអ្វីដែលត្រូវគិតឬធ្វើទេ ។

### ៣. បញ្ជាក់ឲ្យច្បាស់: កុំស្មាន

ឧបជ្ឈាយ៍គួរតែប្រាកដថា ពួកគេយល់អំពីអ្វីដែលសទ្ធិវិហារិករបស់ពួកគេត្រូវការ និងអ្វីដែលសទ្ធិវិហារិកកំពុងសូម ។ បើមិនដូច្នោះទេ ឧបជ្ឈាយ៍ប្រហែលជាឲ្យចម្លើយដែលមានស្រាប់សម្រាប់ស្ថានភាពដែលខុស ដោយផ្តល់ប្រាជ្ញាដែលសទ្ធិវិហារិកមិនត្រូវការ ។

### ៤. ដងយកចេញ: កុំចាក់ចូល

ឧបជ្ឈាយ៍គួរតែដងយកព័ត៌មានដែលត្រូវការដើម្បីជួយចេញពីសទ្ធិវិហារិករបស់ពួកគេ ។ ពួកគេមិនគួរចាក់ព័ត៌មានទៅក្នុងសទ្ធិវិហារិករបស់ពួកគេទេ ។

### សកម្មភាព:

- ចូរសួរសិក្ខាកាមអំពីមូលហេតុដែលមនុស្សគិតថាងាយស្រួលចាក់ព័ត៌មានចូលទៅក្នុងក្បាលរបស់មនុស្សម្នាក់ផ្សេងទៀត ។ តើឧបជ្ឈាយ៍គិតថា ដោយដើរផ្លូវកាត់ សទ្ធិវិហារិកនឹងរៀនបានកាន់តែច្រើន និងកាន់តែលឿនឬ?
- ចូរសួរថាតើមានសិក្ខាកាមណាម្នាក់ធ្លាប់នាំយកសំណួរទៅជួបអ្នកជំនាញកុំព្យូទ័រដែរឬអត់ ។ ប្រហែលជាពួកគេចង់រៀនរបៀបធ្វើប្រតិបត្តិការមួយ ដូចជាការបញ្ជូនឯកសារទៅម៉ាស៊ីនបោះពុម្ព ។ ប៉ុន្តែអ្នកជំនាញនោះបានគ្រប់គ្រងកុំព្យូទ័រ ហើយចុះប៊ូតុងនេះប៊ូតុងនោះយ៉ាងលឿន រហូតដល់ឯកសារចាប់ផ្តើមបោះពុម្ព ។ សិក្ខាកាមនោះបានអង្គុយនៅទីនោះចំហមាត់ ដោយមិនបានចេះរបៀបបោះពុម្ពឯកសារច្រើនជាងពេលមុនគាត់សុំអ្នកជំនាញឲ្យជួយទេ ។ តើអ្នករៀនសូត្រនេះអាចរៀនបានប្រសើរជាងនេះយ៉ាងដូចម្តេច? តើអ្នកជំនាញកុំព្យូទ័រអាចធ្វើបានវិញ? តើឧទាហរណ៍នេះ អាចអនុវត្តចំពោះគោលគំនិត«ការដងចេញ»បានយ៉ាងដូចម្តេច?

**៥. មានរបៀបវារៈ។** កុំចូលទៅម៉ោងសិក្សាការធ្វើជាឧបជ្ឈាយ៍ ដោយមិនមានផែនការសកម្មភាពឡើយ ។ របៀបវារៈជួយមនុស្សឲ្យបន្តនៅលើផ្លូវត្រូវ ។ របៀបវារៈ អាចរាប់បញ្ចូលចំណុចដូចខាងក្រោម:

- ចូរឲ្យសទ្ធិវិហារិកអធិស្ឋាន ដោយសុំយាងព្រះវត្តមានរបស់ព្រះ និងការដឹកនាំពីព្រះអង្គនៅក្នុងការជុំគ្នានោះ ។ ចូរអធិស្ឋាននៅពេលណាដែលចាំបាច់នៅក្នុងដំណើរការនៃការជួបគ្នា ។ យើងមិនអាចអធិស្ឋានបានច្រើនពេកទេ!
- ចូរសួរអំពីការខ្វល់ខ្វាយដែលសទ្ធិវិហារិកមាន—ទោះបីជានេះមានន័យថាមិនលើកឡើងអំពីចំណុចដទៃទៀតនៅក្នុងរបៀបវារៈក៏ដោយ ។
- ចូរពិនិត្យមើលចំណុច ចេញពីពេលជួបគ្នាលើកមុន ។ ចូររំឭក និងពង្រឹងឡើងវិញការរៀនពីមុន ។ ចូរពិនិត្យមើលការរីកចម្រើនរបស់សទ្ធិវិហារិកលើចំណុចអនុវត្តចេញពីពេលជួបគ្នាលើកមុន ។
- បង្ហាញប្រាប់គំនិតថ្មីដែលលោកអ្នកចង់ចែកចាយ ។

- ចូរឲ្យសិទ្ធិវិហារិករកមើលចំណុចអនុវត្តដើម្បីសម្រេចជាលទ្ធផលនៃពេលជួបគ្នានេះ ។
- ចូរអធិស្ឋានសម្រាប់សិទ្ធិវិហារិក សម្រាប់អ្វីៗដែលបានលេចឡើងនៅក្នុងអំឡុងពេលនៃការជួបគ្នា និងសម្រាប់ចំណុចអនុវត្តដែលសិទ្ធិវិហារិកនឹងសម្រេច ។

របៀបវារៈអាចធ្វើឲ្យអ្វីៗដំណើរការទៅមុខដោយរលូននៅក្នុងពេលជួបគ្នាជាមួយឧបជ្ឈាយ៍ ។ ទោះបីយ៉ាងណាក៏ដោយ ឧបជ្ឈាយ៍មិនគួរក្លាយជាទាសកររបស់របៀបវារៈទេ ជាពិសេសប្រសិនបើសិទ្ធិវិហារិកមានសេចក្តីត្រូវការបន្ទាន់ ឬដែលនឹកស្មានមិនដល់ ។

## ៦. ឲ្យពេលវេលាឲ្យៈ កុំធ្វើផ្លូវកាត់

ឧបជ្ឈាយ៍ត្រូវតែមានយល់ព្រមវិនិយោគពេលវេលាដែលចាំបាច់ ដើម្បីបង្កើតទំនាក់ទំនងឧបជ្ឈាយ៍ ។ ពួកគេមិនគួរព្យាយាមដើរផ្លូវកាត់ទេ ។ ដើម្បីអភិវឌ្ឍការទុកចិត្ត និងការរក្សារឿងសម្ងាត់ នោះត្រូវការពេលវេលា—ការនេះមិនមែនកើតឡើងភ្លាមៗបានទេ ។

## ៧. នាំផ្លូវៈ កុំចាក់ពីក្រោយ

ឧបជ្ឈាយ៍ គឺជាមគ្គុទេសន៍—ពួកគេមិនមែនយកជន្លួញចាក់រុញសិទ្ធិវិហារិកទេ «ជួយមនុស្សដទៃទៀតនៅក្នុងការសម្រាលចេញគំនិតថ្មី ជំនាញថ្មី ការប្រៀបធៀបថ្មី និងវិធីថ្មីនៅក្នុងជីវិត និងការងារ»[18] ។

## ៨. រំឭកឡើងវិញៈ កុំខាននឹងពង្រឹង

រាល់ពេលដែលឧបជ្ឈាយ៍ និងសិទ្ធិវិហារិកជួបគ្នា ពួកគេគួររំឭកឡើងវិញអំពីការរៀនកាលពីមុន និងការរីកចម្រើន ។ ការពង្រឹងគឺជាឧបករណ៍បង្រៀនបទដ្ឋានមួយដែលអាចជួយសិទ្ធិវិហារិកចងចាំគោលគំនិតថ្មីៗ អនុវត្តអ្វីថ្មីដែលបានរៀន និងបង្កើតរបៀបមួយ ។

## ៩. ធ្វើជាធនធានៈ កុំស្រាវជ្រាវ

ឧបជ្ឈាយ៍គួរតែធ្វើជាធនធាន ព្រមទាំងចង្អុលបង្ហាញប្រាប់សិទ្ធិវិហារិកទៅរកធនធានដទៃទៀត ។ ឧបជ្ឈាយ៍មិនគួរធ្វើការស្រាវជ្រាវដោយខ្លួនឯងទេ ។ សិទ្ធិវិហារិករបស់ពួកគេគឺជាអ្នករៀនសូត្រដែលពេញវ័យ និងមានសមត្ថភាពស្វ័យដឹកនាំបាន ។

## សកម្មភាពៈ

ចូរសុំសិក្ខាកាមឲ្យធ្វើបញ្ជីកត់ត្រាធនធានដែលអាចមានសម្រាប់សិទ្ធិវិហារិក ។ ធនធានយ៉ាងដូច្នេះរួមមានមនុស្ស សៀវភៅ ទិន្នានុប្បវត្ត ភាពយន្ត ព័ត៌មានជាសំឡេង គេហទំព័រ និងប្លក់ ។

---

18 Vogel, “Reckoning with the Spiritual Lives of Adult Learners,” 24.

**១០. ផ្តល់ទស្សនៈ: កុំផ្តល់ចម្លើយភ្លាម។**

ឧបជ្ឈាយ៍គួរតែជួយសិទ្ធិវិហារិករបស់ខ្លួនឲ្យមើលឃើញលទ្ធភាពដែលអាចកើតមាន បើកទ្វារថ្មីៗ និងមើលឃើញឱកាសថ្មីៗ ។ ទោះបីយ៉ាងណាក៏ដោយ នេះមិនមែនមានន័យថា ពួកគេគួរតែផ្តល់ចម្លើយភ្លាមៗទេ ។